ក្រសួងអប់រំ យុវជន និងកីឡា

**Ministry of Education, Youth and Sport**

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ការយល់ដឹងពីវិធីសាស្ត្រនៃការអានភាសាអង់គ្លេស របស់សិស្សនៅកម្រិតមធ្យមសិក្សាទុតិយភូមិ ក្នុងខេត្តតាកែវ

# AN UNDERSTANDING OF ENGLISH READING STRATEGIES FOR UPPER SECONDARY SCHOOL STUDENTS IN TAKEO PROVINCE


ដោយ / By

**ទិព្វ សារី / TIP SARY**


ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៧

ឯកទេស៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០១៩-២០២០

# ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ការយល់ដឹងពីវិធីសាស្ត្រនៃការអានភាសាអង់គ្លេស របស់សិស្សនៅកម្រិតមធ្យមសិក្សាទុតិយភូមិ ក្នុងខេត្តតាកែវ

# AN UNDERSTANDING OF ENGLISH READING STRATEGIES FOR UPPER SECONDARY SCHOOL STUDENTS IN TAKEO PROVINCE

ដោយ / By

ទិព្វ សារី / TIP SARY

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៧

ឯកទេស៖ ការគ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០១៨-២០២០

គ្រូដឹកនាំបន្ទោល ៖ លោកបណ្ឌិត នួច វីរ៉ា

គ្រូដឹកនាំរង ៖ លោក ម៉ន មុនិន្ទ

# សេចក្ដីប្រកាសអះអាងរបស់បេក្ខជន

នាងខ្ញុំសូមបញ្ជាក់ថា និក្ខេបបទស្រាវជ្រាវដែលមានចំណងជើងថា «**ការយល់ដឹងពីវិធីសាស្ត្រនៃការអានភាសាអង់គ្លេសរបស់សិស្សនៅកម្រិតមធ្យមសិក្សាទុតិយភូមិក្នុងខេត្តតាកែវ**» សម្រាប់បំពេញលក្ខខណ្ឌសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ ពិតជាស្នាដៃរបស់នាងខ្ញុំទាំងស្រុង។ ស្នាដៃនេះពុំទាន់បានប្រើប្រាស់ដើម្បីបំពេញលក្ខខណ្ឌសិក្សាសម្រាប់ទទួលសញ្ញាបត្រនៅវិទ្យាស្ថាននេះ ឬសាកលវិទ្យាល័យណា ឬវិទ្យាស្ថានថ្នាក់ស្មើណាមួយនៅឡើយទេ។ ពុំមានសេចក្ដីដកស្រង់ ឬខ្លឹមសារអ្វីមួយត្រូវបានប្រើប្រាស់ក្នុងអត្ថបទស្រាវជ្រាវនេះ ដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ ឬចុះបញ្ជីឯកសារយោងឡើយ។ និក្ខេបបទស្រាវជ្រាវខាងលើនេះពិតជាត្រូវបានស្រាវជ្រាវ និងចងក្រងដោយនាងខ្ញុំពិតប្រាកដមែន។

ថ្ងៃសៅរ៍ ៨កើត ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២០

**ហត្ថលេខា**

**ឌិព្វ សារី**

# លិខិតបញ្ជាក់

លោកបណ្ឌិត **នួន វីរ៉ា** ជាគ្រូដឹកនាំបង្គោល

លោក **ម៉ន មុនិន្ទ** ជាគ្រូដឹកនាំរង

## សូមបញ្ជាក់ និងទទួលស្គាល់ថា

លោកស្រី **ឌិញ សារី** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី ៧ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវ «**ការយល់ដឹងពីវិធីសាស្ត្រនៃការអានតាសារអង់គ្លេសរបស់សិស្សនៅកម្រិតមធ្យមសិក្សាទុតិយភូមិក្នុងខេត្តតាកែវ** » ពិតប្រាកដមែន។

ថ្ងៃសៅរ៍ ៨កើត ខែកត្តិក ឆ្នាំជូត ឯកស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២០

.......................................

**លោកបណ្ឌិត នួន វីរ៉ា**

នាយករងនៃវិទ្យាស្ថានជាតិអប់រំ

.....................................

**លោក ម៉ន មុនិន្ទ**

ប្រធានដេប៉ាតឺម៉ង់គ្រប់គ្រង និងផែនការ

# លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ:** ៥៧០៤/២៧ **អយក.**ឧទក

(**ការសម្ងាត់**)

**លិខិតឧទ្ទេសនាម**

យោង ៖ -លិខិតលេខ២៩៥៥ អយក.វជអ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២០។

-បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ និងទី៨ ឆ្នាំសិក្សា២០១៩-២០២០ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៩។

បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារសារណា** ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៧ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី២៤-២៥ ខែតុលា ឆ្នាំ២០២០ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | | |
|---|---|---|---|
| ១-ឯ.ឧបណ្ឌិត | សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២-ឯកឧត្តមបណ្ឌិត | ម៉ុក សារ៉ុម | អគ្គ.អប់រំ | អនុប្រធាន |
| ៣- ឯកឧត្តម | នៀ សុផន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ៤-លោក | ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥-លោកបណ្ឌិត | នូវ វ៉ាក | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៦-លោកស្រី | ប៊ុន សុផានី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៧-លោក | ថៃ ហេង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-លោកបណ្ឌិត | នី វង្សា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៩-លោក | ម៉ន មុនិន្ទ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១០-លោក | ចាប រតនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១១-លោកបណ្ឌិត | ឈាង សង្វាត | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១២-លោកបណ្ឌិត | អាន រ៉ូប្រាវ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣-លោកស្រី | នូ ចន្ទី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៤-លោក | សៀង វាសនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារសារណា របស់និស្សិតពីថ្ងៃទី២៤-២៥ ខែតុលា ឆ្នាំ២០២០ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ ចន្ទ ៣ កើត ខែ កត្តិក ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ២០២០
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**
- -អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- -ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន"
- -គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"
- -សាមីខ្លួន "ដើម្បីអនុវត្ត"
- -កាលប្បវត្តិ -ឯកសារ វជអ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

# សេចក្តីថ្លែងអំណរគុណ

ជាដំបូងនាងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ក្រសួងអប់រំ យុវជន និងកីឡា និងវិទ្យាស្ថានជាតិអប់រំ ដែលបានរៀបចំការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំនាពេលកន្លងមក។

បន្ទាប់មក នាងខ្ញុំសូមគោរពថ្លែងអំណរគុណដល់គណៈកម្មការគ្រប់គ្រងការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៃវិទ្យាស្ថានជាតិអប់រំ ព្រមទាំងលោកសាស្ត្រាចារ្យទាំងអស់ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការបង្ហាត់បង្រៀន និងពន្យល់ណែនាំដល់យើងខ្ញុំទាំងអស់គ្នា។ ជាពិសេសនាងខ្ញុំសូមថ្លែងអំណរគុណទៅដល់ **លោកបណ្ឌិត នួច ទីរ៉ា** និង **លោក ម៉ន មុនិន្ទ** ដែលតែងតែយកចិត្តទុកដាក់លះបង់កម្លាំងកាយ កម្លាំងចិត្ត និងពេលវេលាដ៏មានតម្លៃក្នុងការពន្យល់ ណែនាំ ផ្តល់យោបល់កែលម្អដល់នាងខ្ញុំក្នុងការសរសេរនិក្ខេបបទនេះរហូតទទួលបានជោគជ័យ។ ជាមួយគ្នានេះដែរ នាងខ្ញុំក៏សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ **លោកបណ្ឌិត ឈាង សទ្ធាត** ដែលបានលះបង់ពេលវេលាដ៏មានតម្លៃ និងមមារញឹកបំផុតដើម្បីផ្តល់ការណែនាំខាងបច្ចេក ទេសលើការពិភាក្សា និងបច្ចេកទេសផ្សេងទៀតមួយចំនួនធំដល់នាងខ្ញុំ ទើបនាងខ្ញុំអាចសម្រេចជោគជ័យលើការសរសេរសារណានេះបាន។ នាងខ្ញុំក៏សូមថ្លែងអំណរគុណទៅដល់មិត្តរួមជំនាន់ទី៧នេះ ព្រមទាំងសិស្សច្បងជំនាន់មុនៗទាំងអស់ ដែលបានចែករំលែករាល់បទពិសោធក៏ដូចជាចំណេះដឹងផ្សេងៗក្នុងការជួយសម្រួលដល់ដំណើរការស្រាវជ្រាវនិក្ខេបបទរបស់នាងខ្ញុំ។

បន្ទាប់មកទៀត នាងខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅបំផុតដល់ លោកឪពុក និងអ្នកម្តាយរបស់នាងខ្ញុំដែលបានផ្តល់កំណើត និងចិញ្ចឹមបីបាច់នាងខ្ញុំរហូតដល់ធំ ព្រមទាំងលះបង់គ្រប់បែបយ៉ាងដើម្បីឱ្យនាងខ្ញុំទទួលបានជោគជ័យដូចថ្ងៃនេះ។ ជាមួយគ្នានេះដែរ នាងខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងខ្លាំងដល់ឧត្តមស្វាមី និងកូនៗជាទីស្រឡាញ់របស់នាងខ្ញុំដែលតែងតែគាំទ្រ លើកទឹកចិត្ត តស៊ូពុះពារការលំបាកទាំងឡាយដើម្បីឱ្យនាងខ្ញុំមានឱកាសមកបន្តការសិក្សា រហូតបានបញ្ចប់ការសិក្សាបរិញ្ញាបត្រជាន់ខ្ពស់

ផ្នែកគ្រប់គ្រងអប់រំនេះដោយជោគជ័យ។ ទន្ទឹមនឹងនេះ នាងខ្ញុំក៏សូមថ្លែងអំណរគុណផងដែរដល់បងប្អូនរបស់នាងខ្ញុំដែលបានជួយសម្រួលដល់ការសិក្សារៀនសូត្ររបស់នាងខ្ញុំ ក៏ដូចជាលោកនាយក នាយិកា លោកគ្រូ អ្នកគ្រូ ព្រមទាំងសិស្សានុសិស្សទាំងអស់ដែលបានសហការយ៉ាងរីករាយ ក្នុងការផ្តល់ព័ត៌មានយ៉ាងលម្អិត និងគ្រប់ជ្រុងជ្រោយសម្រាប់ការសិក្សាស្រាវជ្រាវនិក្ខេបបទនេះឱ្យបញ្ចប់បានដោយជោគជ័យគួរជាទីមោទនៈ។

ជាទីបញ្ចប់ នាងខ្ញុំសូមគោរពជូនពរដល់ ឯកឧត្តមបណ្ឌិត បណ្ឌិត សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ មិត្តភ័ក្តិ និងសិស្សានុសិស្សទាំងអស់ក៏ដូចជាក្រុមគ្រួសាររបស់នាងខ្ញុំ សូមឱ្យជួបប្រទះតែសេចក្តីសុខគ្រប់ប្រការ មានសុខភាពល្អ និងសម្រេចបានជោគជ័យគ្រប់ភារកិច្ច ព្រមទាំងទទួលបាននូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈកុំបីឃ្លៀងឃ្លាតឡើយ។

សូមអរគុណ!

# មូលន័យសង្ខេប

ការសិក្សាទៅលើប្រធានបទ ការយល់ដឹងពីវិធីសាស្ត្រនៃការអានភាសាអង់គ្លេសរបស់សិស្សនៅកម្រិតមធ្យមសិក្សាទុតិយភូមិក្នុងខេត្តតាកែវនេះមានគោលបំណងដើម្បី (១) រកឱ្យឃើញកម្រិតនៃការយល់ដឹងរបស់សិស្ស ក្នុងការប្រើប្រាស់វិធីសាស្ត្រលើបំណិនអានភាសាអង់គ្លេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិក្នុងខេត្តតាកែវ និង(២)សិក្សាប្រៀបធៀបពីកម្រិតនៃការយល់ដឹងរបស់សិស្សនៅក្នុងខេត្តតាកែវចំពោះបំណិនអានជាភាសាអង់គ្លេសដោយចែកទៅតាមភេទ ចំនួនឆ្នាំដែលរៀនភាសា និងចំនួនម៉ោងដែលសិស្សបានអានភាសាអង់គ្លេស។ ភាគសំណាកគឺ លោកគ្រូ អ្នកគ្រូ ដែលបង្រៀនភាសាអង់គ្លេសថ្នាក់ទី១០ ថ្នាក់ទី១១ និងថ្នាក់ទី១២ ចំនួន១៥នាក់ និងសិស្សានុសិស្សថ្នាក់ទី១០ ថ្នាក់ទី១១ និងថ្នាក់ទី១២ ចំនួន១៣១នាក់ មកពីវិទ្យាល័យចំនួន ៨ ក្នុងខេត្តតាកែវក្នុងឆ្នាំសិក្សា២០១៩-២០២០។ ការស្រាវជ្រាវនេះប្រើប្រាស់វិធីសាស្ត្របែបបរិមាណវិស័យ និងគុណវិស័យ ហើយឧបករណ៍សម្រាប់ស្រាវជ្រាវជាកម្រងសំណួរបំពេញ និងកម្រងសំណួរសម្ភាសន៍ ដែលត្រូវបានរៀបចំឡើងដោយអ្នកស្រាវជ្រាវ ព្រមទាំងមានការត្រួតពិនិត្យពីសាស្ត្រាចារ្យដឹកនាំ។ ទិន្នន័យដែលប្រមូលបាន ត្រូវបានវិភាគដោយប្រើកម្មវិធី SPSS សម្រាប់គណនាតម្លៃមធ្យម គំលាតស្តង់ដា និងប្រៀបធៀបកម្រិតនៃការយល់ដឹងលើវិធីសាស្ត្រអានរបស់សិស្សចែកតាមភេទ ចំនួនឆ្នាំដែលសិស្សបានរៀន និងចំនួនម៉ោងដែលសិស្សបានអានតាមកម្មវិធី Descriptive Statistics Independent Samples t-Test និង One-way ANOVA ដោយកំណត់កម្រិតសំខាន់នៃភាពខុសគ្នាក្នុងកម្រិត $P \leq 0.0$៥។

លទ្ធផលនៃការស្រាវជ្រាវត្រូវបានសង្ខេបដូចខាងក្រោម៖

១. ការយល់ដឹងលើបំណិនអានភាសាអង់គ្លេសរបស់សិស្សមធ្យមសិក្សាទុតិយភូមិក្នុងខេត្តតាកែវតាមផ្នែក និងជារួមស្ថិតក្នុងកម្រិតមធ្យម។ សិស្សមានការយល់ដឹងទៅលើការអានលម្អិត ដើម្បីធ្វើការវិនិច្ឆ័យលើការយល់ដឹងទៅលើអត្ថបទទាំងមូលក្នុងកម្រិតខ្ពស់ជាងគេ និងមានការយល់ដឹងតិចជាងគេលើ ការអានល្អិតល្អន់ ដើម្បីពិនិត្យមើលអត្ថន័យជាក់លាក់របស់អត្ថបទទាំងមូល។ លទ្ធផលនេះបង្ហាញឱ្យឃើញ

ថា សិស្សនៅកម្រិតមធ្យមសិក្សាទុតិយភូមិក្នុងខេត្តតាកែវមានការយល់ដឹងលើបំណិនអានភាសាអង់គ្លេសនៅមានកម្រិត។ សិស្សមិនសូវបានប្រើការអានយ៉ាងល្អិតល្អន់ដើម្បីពិនិត្យមើលអត្ថន័យជាក់លាក់របស់អត្ថបទទាំងមូល ដោយមិនបានអានយ៉ាងយឺតៗ និងប្រុងប្រយ័ត្នដើម្បីឱ្យប្រាកដថាពួកគេយល់អ្វីដែលកំពុងអាន មិនព្យាយាមត្រឡប់មកអានត្រង់កន្លែងដែលបាត់បង់ការផ្ដោតអារម្មណ៍ និងមិនបានប្រើប្រាស់ឯកសារយោងដើម្បីធ្វើឱ្យចងចាំព័ត៌មាន។

២. ការប្រៀបធៀបកម្រិតយល់ដឹងបំណិនអានភាសាអង់គ្លេសរបស់សិស្សដោយបែងចែកទៅតាមភេទ ចំនួនឆ្នាំដែលសិស្សបានរៀនភាសាអង់គ្លេសមិនមានភាពខុសប្លែកគ្នាទេដោយតម្លៃ $P > 0.05$។ ចំពោះការយល់ដឹង លើបំណិនអានភាសាអង់គ្លេសតាមរយៈចំនួនម៉ោង ដែលសិស្សអានក្នុងមួយថ្ងៃមានលក្ខណៈខុសប្លែកគ្នាដោយតម្លៃ $P < 0.0៥$។ សិស្សដែលចំណាយពេលអានពី១ម៉ោង ទៅ ២ម៉ោងក្នុងមួយថ្ងៃមានការយល់ដឹងទៅលើបំណិនអានភាសាអង់គ្លេស ខ្ពស់ជាងសិស្សដែលចំណាយពេលអានតិចជាង ១ម៉ោងក្នុងមួយថ្ងៃ។

ជារួមការយល់ដឹងលើបំណិនអានភាសាអង់គ្លេសរបស់សិស្សនៅកម្រិតមធ្យមសិក្សាទុតិយភូមិ ក្នុងខេត្តតាកែវមានកម្រិតមធ្យម ហើយការយល់ដឹងដោយចែកទៅតាមភេទ និងចំនួនឆ្នាំដែលពួកគេរៀនភាសាអង់គ្លេសមិនមានភាពខុសប្លែកគ្នាទេ។ ចំណែកការយល់ដឹងតាមរយៈចំនួនម៉ោងដែលសិស្សអានមានលក្ខណៈខុសប្លែកគ្នា ដែលអាចបង្ហាញថាការចំណាយពេលអានកាន់តែច្រើនសិស្សនឹងមានការយល់ដឹងលើបំណិនអានកាន់តែច្រើន។ លទ្ធផលនេះនឹងនាំទៅរកសំណូមពរមួយចំនួនសម្រាប់រួមចំណែកធ្វើឱ្យការយល់ដឹងរបស់សិស្សលើបំណិនអានភាសាអង់គ្លេសបានល្អប្រសើរជាងមុន។

# Abstract

The purpose of this study about an understanding of English reading strategies for upper secondary school students in Takeo province were to (1) study the level of students' understanding regarding to English reading strategies at the upper secondary school in Takeo province and (2) to compare the level of understanding of their reading strategies classified by gender, number of years they learned English and number of reading-hour. The sample were the 15 English teachers, who teach in grade 10, grade 11 and grade 12 and 131 students, who study in grade 10, grade 11 and grade 12 from 8 upper secondary schools in Takeo province in 2019-2020. This research use mix methodology and tools are complementary questionnaires and interview questionnaires prepared by the researcher and approved by research supervisor. The collected data was analyzed by SPSS using Mean and Standard Deviation. The comparison of the students' understanding with compared variables was Independent Samples t-Test Descriptive Statistics and One-way ANOVA with statistically significant difference at 0.05.

The results of the research were summarized as follows:

1. The understanding of English reading strategies of upper secondary school students in Takeo by sector and overall is at moderate level. Students have an understanding of Reading for detail comprehension at the highest while Reading for specific information was at the lowest one. These results show that the understanding of upper secondary school students in Takeo province is still not better. They rarely read slowly and carefully to make sure they understand what they are reading, they do not try

to get back on track what they lose concentration and they do not use reference materials to help them remember it.

2. Comparing of students' understanding on English reading strategies based on gender and number of years that they learn English do not differ by $P > 0.05$. The number of hours they read per day, were difference with $P = 0.003 < 0.05$. Students who spend 1 to 2 hours a day reading have a higher understanding of reading strategies than students who spend time to read less than 1 hour a day.

Overall, students' understanding of English reading strategies at the upper secondary school in Takeo province is moderate, and their understanding based on gender and the number of years they learn English did not differ. The understanding through, number of hours they read per day is different which may indicate that spending more time reading will have a greater understanding of reading strategies. This result will lead to a number of suggestions for improving students' understanding of English reading strategies.

# មាតិកា

**ចំណងជើង** **ទំព័រ**


សេចក្តីប្រកាសអះអាងរបស់បេក្ខជន ........ i
លិខិតបញ្ជាក់ ........ ii
លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ ........ iii
សេចក្តីថ្លែងអំណរគុណ ........ iv
មូលន័យសង្ខេប ........ vi
Abstract ........ viii
មាតិកា ........ x
បញ្ជីក្រាប ........ xiii
បញ្ជីតារាង ........ xiv
បញ្ជីអក្សរកាត់ ........ xvii
**ជំពូកទី១ ៖ សេចក្តីផ្តើម** ........ ១
១.១. លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១
១.២. ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ៣
១.៣. គោលបំណងនៃការស្រាវជ្រាវ ........ ៥
១.៤. សំណួរស្រាវជ្រាវ ........ ៦
១.៥. សារៈសំខាន់នៃការស្រាវជ្រាវ ........ ៦
១.៦. វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ ........ ៧
១.៦.១. វិសាលភាពនៃការស្រាវជ្រាវ ........ ៧
១.៦.២. ដែនកំណត់ ........ ៨
១.៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៩
**ជំពូកទី២ ៖ រំលឹកទ្រឹស្តី** ........ ១១
២.១. ទិដ្ឋភាពទូទៅពីការសិក្សាភាសាបរទេសនៅកម្ពុជា ........ ១១

២.២. មុខវិជ្ជាភាសាអង់គ្លេស ........................................................................................................ ១២
២.៣. បំណិនក្នុងការសិក្សាភាសាអង់គ្លេស ........................................................................................ ១៣
២.៣.១. ការបង្រៀនបំណិនអាន ......................................................................................................... ១៦
២.៣.២. លំនាំនៃការបង្រៀនសមត្ថភាពអានក្នុងភាសាទី១ ....................................................................... ១៨
២.៣.៣. យុទ្ធសាស្ត្រការអានជាភាសាអង់គ្លេស ...................................................................................... ១៩
២.៤. គោលការណ៍ក្នុងការបង្រៀនអំណានភាសាអង់គ្លេស ......................................................................២៣
២.៥. គម្រូនៃអំណាន.........................................................................................................................២៤
២.៥.១. គម្រូតាមបែប Top-down ......................................................................................................២៥
២.៥.២. គម្រូតាមបែប Bottom-Up......................................................................................................២៥
២.៥.៣. គម្រូតាមបែប Interactive ......................................................................................................២៥
២.៦. តួនាទី របស់ Metacognition នៅក្នុងការយល់ដឹងលើការអាន ..........................................................២៦
២.៦.១. ការរៀបចំ និងធ្វើផែនការសម្រាប់ការសិក្សា ..............................................................................២៦
២.៦.២. ការជ្រើសរើស និងប្រើប្រាស់យុទ្ធសាស្ត្រនៃការរៀន.......................................................................២៧
២.៦.៣. ការប្រើប្រាស់យុទ្ធសាស្ត្រតាមដាន .............................................................................................២៧
២.៦.៤. រៀបចំយុទ្ធសាស្ត្រផ្សេងៗ...........................................................................................................២៧
២.៦.៥. ការវាយតម្លៃលើការប្រើប្រាស់យុទ្ធសាស្ត្រ និងការរៀន .....................................................................២៧
២.៧. ស្តង់ដាអំណាន ..........................................................................................................................២៨
**ជំពូកទី៣ ៖ វិធីសាស្ត្រស្រាវជ្រាវ** ..............................................................................................៣៤
៣.១. គម្រោងវិភាគ .............................................................................................................................៣៤
៣.១.១. ទីតាំងនៃការស្រាវជ្រាវ ...............................................................................................................៣៤
៣.១.២. អថេរ .......................................................................................................................................៣៥
៣.២. ការប្រមូលទិន្នន័យ........................................................................................................................៣៦
៣.៣. ឧបករណ៍ស្រាវជ្រាវ...................................................................................................................... ៣៧
៣.៤. ការជ្រើសរើសភាគសំណាក ............................................................................................................ ៤០

៣.៥. ការវិភាគទិន្នន័យ ............................................................................................... ៤២
**ជំពូកទី៤ ៖ លទ្ធផលនៃការស្រាវជ្រាវ និងការពិភាក្សា**............................................................... ៤៣
៤.១. របៀបនៃការបង្ហាញព័ត៌មាន ............................................................................... ៤៣
៤.២. លទ្ធផលនៃការសិក្សាស្រាវជ្រាវ ........................................................................... ៤៤
៤.២.១. ព័ត៌មានរបស់ភាគសំណាកដែលបានចូលរួម ............................................... ៤៤
៤.២.២. សំណួរស្រាវជ្រាវទី ១ ........................................................................... ៤៦
៤.២.៣. សំណួរស្រាវជ្រាវទី២............................................................................. ៦៧
**ជំពូកទី៥ ៖ សេចក្តីសន្និដ្ឋាន និងសំណូមពរ**............................................................................. ៩៤
៥.១. សេចក្តីសន្និដ្ឋាន .................................................................................................. ៩៤
៥.២. សំណូមពរ .......................................................................................................... ៩៦
៥.២.១. សម្រាប់អ្នកអនុវត្ត ................................................................................ ៩៦
៥.២.២. សម្រាប់អ្នកស្រាវជ្រាវបន្ត ........................................................................ ៩៧
ឯកសារយោង ....................................................................................................................... ៩៨
ឧបសម្ព័ន្ធ ............................................................................................................................ ១០៦

# បញ្ជីក្រាប


ក្រាប២.១៖ គម្រូទាំងបីរបស់អំណាន ........ ២៤

ក្រាប២.២៖  គម្រូអំណានតាមបែប Interactive Model ........ ២៦

ក្រាប២.៣៖  លទ្ធផលនៃការអានរបស់សិស្សថ្នាក់ទី ១១ តាមមុខវិជ្ជារង ........ ៣០

ក្រាប២.៤ ៖ លទ្ធផលនៃការអានតាមលទ្ធផលសិក្សា ........ ៣០

ក្រាប២.៥ ៖ កម្រិតសមត្ថភាពទាំង ៦ នៃវង្វាយតម្លៃ PISA-D ........ ៣២

ក្រាប២.៦៖ លទ្ធផលតេស្ត PISA-D ផ្នែកអំណានរបស់សិស្សប្រទេសកម្ពុជា ........ ៣២

ក្រាប២.៧ ៖ សមត្ថភាពផ្នែកអំណានរបស់សិស្សកម្ពុជាធៀបនឹងសមត្ថភាពកម្រិតមូលដ្ឋាន PISA-D ៣៣

ក្រាប៤.១៖ ការយល់ឃើញរបស់គ្រូទៅលើកម្រិតសំខាន់នៃភាសាអង់គ្លេស ........ ៤៦

ក្រាប៤.២៖ ការយល់ឃើញរបស់គ្រូលើសមត្ថភាពទូទៅផ្នែកភាសាអង់គ្លេសរបស់សិស្ស ........ ៤៧

ក្រាប៤.៣៖ ការយល់ឃើញរបស់គ្រូលើសមត្ថភាពអានភាសាអង់គ្លេសរបស់សិស្ស ........ ៤៨

ក្រាប៤.៤៖ ភាពញឹកញាប់នៃការដាក់កិច្ចការផ្ទះរបស់គ្រូទាក់ទងនឹងការអាន ........ ៤៨

ក្រាប៤.៥៖ ភាគរយបំណិនអានដែលគ្រូបានបង្រៀនទៅសិស្ស ........ ៤៩

ក្រាប៤.៦៖ ភាគរយគ្រូដែលបានណែនាំសិស្សពីរបៀបប្រើវិធីសាស្ត្រអានភាសាអង់គ្លេស ........ ៥១

ក្រាប៤.៧៖ ការណែនាំរបស់គ្រូពេលសិស្សជួបពាក្យពិបាក ........ ៥១

ក្រាប៤.៨៖ ការណែនាំរបស់គ្រូដើម្បីជំនួយដល់ការយល់ខ្លឹមសារ ........ ៥២

ក្រាប៤.៩៖ បញ្ហាដែលសិស្សជួបនៅពេលអាន ........ ៥៣

ក្រាប៤.១០៖ ភាគរយសិស្សដែលទាមទារឱ្យគ្រូបកប្រែអត្ថបទជាភាសាខ្មែរ ........ ៥៣

ក្រាប៤.១១៖ ការណែនាំពីពេលវេលាដែលត្រូវប្រើវចនានុក្រម ........ ៥៤

# បញ្ជីតារាង

តារាង ៣.១៖ ភាគសំណាកនៃការស្រាវជ្រាវ ........................................................................ ៤១

តារាង ៤.១៖ ភាគសំណាកដែលបានចូលរួម ........................................................................ ៤៥

តារាង ៤.២៖ ការយល់ឃើញរបស់គ្រូទៅលើកម្រិតនៃការប្រើវិធីសាស្ត្រអានភាសាអង់គ្លេសរបស់សិស្ស ........................................................................ ៥០

តារាង ៤.៣៖ កម្រិតនៃការយល់ដឹងលើអំណានរហ័សសម្រាប់ស្វែងរកព័ត៌មានជាក់លាក់ណាមួយ (Scanning) ........................................................................ ៥៥

តារាង ៤.៤៖ កម្រិតនៃការយល់ដឹងលើអំណានរហ័សសម្រាប់ស្វែងរកគោលគំនិតសំខាន់(Skimming) ........................................................................ ៥៦

តារាង ៤.៥៖ កម្រិតនៃការយល់ដឹងលើការអានដើម្បីស្វែងរកព័ត៌មានមកអះអាងបញ្ជាក់ (Reading to conform information) ........................................................................ ៥៧

តារាង ៤.៦៖ កម្រិតនៃការប្រើការអានយ៉ាងលម្អិតដើម្បីឱ្យយល់ពីគំនិតសំខាន់នៃអត្ថបទទាំងមូល (Reading for main idea) ........................................................................ ៥៨

តារាង ៤.៧៖ កម្រិតនៃការប្រើការអានយ៉ាងល្អិតល្អន់ ដើម្បីពិនិត្យមើលអត្ថន័យជាក់លាក់របស់អត្ថបទទាំងមូល (Reading for specific information) ........................................................................ ៥៩

តារាង ៤.៨៖ កម្រិតនៃការប្រើការអានលម្អិតដើម្បីធ្វើការវិនិច្ឆ័យលើការយល់ដឹងទៅលើអត្ថបទទាំងមូល (Reading for Detailed Comprehension ) ........................................................................ ៦០

តារាង ៤.៩៖ តារាងសរុបទិន្នន័យពីសិស្ស និងគ្រូលើការប្រើវិធីសាស្ត្រទាំង ៦ ........................................................................ ៦១

តារាង ៤.១០៖ ប្រៀបធៀបរវាងសិស្សភេទប្រុស និងសិស្សភេទស្រីទៅលើការប្រើប្រាស់អំណានរហ័សសម្រាប់ស្វែងរកព័ត៌មានជាក់លាក់ណាមួយ( Scanning) ........................................................................ ៦៨

តារាង ៤.១១៖ ប្រៀបធៀបរវាងសិស្សភេទប្រុស និងសិស្សភេទស្រីទៅលើការប្រើប្រាស់អំណានរហ័ស សម្រាប់ស្វែងរកគោលគំនិតសំខាន់ (Skimming) ............ ៦៩

តារាង ៤.១២៖ ប្រៀបធៀបរវាងសិស្សភេទប្រុស និងសិស្សភេទស្រីទៅលើការប្រើប្រាស់វិធីសាស្ត្រអាន ដើម្បីស្វែងរកព័ត៌មានមកអះអាងបញ្ជាក់ (Reading to conform information) ............ ៧០

តារាង ៤.១៣៖ ប្រៀបធៀបរវាងសិស្សភេទប្រុស និងសិស្សភេទស្រីទៅលើការប្រើប្រាស់ វិធីសាស្ត្រនៃការអានយ៉ាងលម្អិត ដើម្បីឱ្យយល់ពីគំនិតសំខាន់នៃអត្ថបទទាំងមូល (Reading for main idea) ........ ៧១

តារាង ៤.១៤៖ ប្រៀបធៀបរវាងសិស្សភេទប្រុស និងសិស្សភេទស្រីទៅលើការប្រើប្រាស់វិធីសាស្ត្រអានយ៉ាងល្អិតល្អន់ ដើម្បីពិនិត្យមើលអត្ថន័យជាក់លាក់របស់អត្ថបទទាំងមូល (Reading for specific information) ............ ៧២

តារាង ៤.១៥៖ ប្រៀបធៀបរវាងសិស្សភេទប្រុស និងសិស្សភេទស្រីទៅលើការប្រើប្រាស់វិធីសាស្ត្រអានលម្អិតដើម្បីធ្វើការវិនិច្ឆ័យលើការយល់ដឹងទៅលើអត្ថបទទាំងមូល(Reading for Detailed Comprehension) ............ ៧៣

តារាង ៤.១៦៖ ប្រៀបធៀបរវាងសិស្សភេទស្រី និងសិស្សភេទប្រុស ទៅលើការប្រើប្រាស់វិធីសាស្ត្របំណិនអានភាសាអង់គ្លេសទាំង ៦ ............ ៧៥

តារាង ៤.១៧៖ ការប្រៀបធៀបការយល់ដឹងលើវិធីសាស្ត្របំណិនអានភាសាអង់គ្លេសរបស់សិស្សដោយយោងទៅតាមចំនួនឆ្នាំដែលពួកគេបានរៀនភាសាអង់គ្លេស ............ ៧៧

តារាង ៤.១៨៖ ការយល់ដឹងទៅលើអំណានរហ័សសម្រាប់ស្វែងរកព័ត៌មានជាក់លាក់ណាមួយ (Scanning) យោងទៅតាមចំនួនម៉ោងដែលសិស្សអាន ............ ៧៩

តារាង ៤.១៩៖ ការយល់ដឹងពីវិធីសាស្ត្រអំណានរហ័ស សម្រាប់ស្វែងរកគោលគំនិតសំខាន់ (Skimming) យោងទៅតាមចំនួនម៉ោងដែលសិស្សអាន ............ ៨១

តារាង ៤.២០៖ ការយល់ដឹងពីវិធីសាស្រ្ត អានដើម្បីស្វែងរកព័ត៌មានមកអះអាងបញ្ជាក់ (Reading to conform information) យោងទៅតាមចំនួនម៉ោងដែលសិស្សអាន.......................................... ៨២
តារាង ៤.២១៖ ការយល់ដឹងពីវិធីសាស្រ្តអានយ៉ាងលម្អិត ដើម្បីឱ្យយល់ពីគំនិតសំខាន់នៃអត្ថបទទាំងមូល (Reading for main idea) យោងទៅតាមចំនួនម៉ោងដែលសិស្សអាន..................................... ៨៣
តារាង ៤.២២៖ ការយល់ដឹងពីវិធីសាស្រ្តអានយ៉ាងល្អិតល្អន់ ដើម្បីពិនិត្យមើលអត្ថន័យជាក់លាក់របស់អត្ថបទទាំងមូល (Reading for specific information) យោងទៅតាមចំនួនម៉ោងដែលសិស្សអាន...... ៨៤
តារាង ៤.២៣៖ ការយល់ដឹងពីវិធីសាស្រ្តអានលម្អិតដើម្បីធ្វើការវិនិច្ឆ័យលើការយល់ដឹងទៅលើ អត្ថបទទាំងមូល (Reading for Detailed Comprehension ) យោងទៅតាមចំនួនម៉ោងដែលសិស្សអាន.. ៨៦
តារាង ៤.២៤៖ ការយល់ដឹងពីវិធីសាស្រ្តអានទាំង៦ យោងទៅតាមចំនួនម៉ោងដែលសិស្សអាន ........ ៨៧

# បញ្ជីអក្សរកាត់

| | |
|---|---|
| UNESCO | : United Nations Educational, Scientific, and Cultural Organization |
| EFA | : Education for All |
| SDGs4 | : Sustainable Development Goals |
| MDGs | : Millennium Development Goals |
| MPAC2025 | : Master Plan on ASEAN Connectivity 2025 |
| ASEAN | : Association of South East Asian Nations |
| MoEYs | : Ministry of Education Youth and Sports |
| TOEIC | : Test of English for International Communication |
| TOEFL | : Test of English as a Foreign Language |
| EFL | : English as a Foreign Language |
| ESL | : English as a Second Language |
| SPSS | : Statistical Package for the Social Sciences |

# ជំពូកទី ១
# សេចក្តីផ្តើម

# ជំពូកទី ១

# សេចក្តីផ្តើម

## ១.១. លំនាំបញ្ហានៃការស្រាវជ្រាវ

បច្ចុប្បន្ននេះ ប្រទេសទាំងអស់នៅក្នុងពិភពលោកកំពុងមានការប្រកួតប្រជែងគ្នាឥតឈប់ឈរ ទាំងផ្នែកសេដ្ឋកិច្ច ផ្នែកបច្ចេកវិទ្យា និងវិទ្យាសាស្ត្រដែលធ្វើឱ្យគ្រប់ប្រទេសទាំងអស់ខិតខំប្រឹងប្រែងអភិវឌ្ឍប្រទេសរបស់ខ្លួនលើគ្រប់វិស័យ។ វិស័យអប់រំ មានតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍធនធានមនុស្សឱ្យមានចំណេះដឹង និងសមត្ថភាពខ្ពស់ ភាពច្នៃប្រឌិត ស្មារតីសហគ្រិនភាព នវានុវត្តន៍ និងក្រមសីលធម៌ខ្ពស់ (ក្រសួងអប់រំ យុវជន និងកីឡា, ២០១៩)។ ក្នុងន័យនេះហើយ ទើបការអប់រំត្រូវបានដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយបង្កើតជាធនធានមនុស្សសម្រាប់ជាកម្លាំងដើម្បីអភិវឌ្ឍប្រទេសនីមួយៗ ហើយការអប់រំក៏ជាស្ពាន ជាជណ្តើរ និងជាផែនទីបង្ហាញផ្លូវដល់មនុស្សគ្រប់រូបឱ្យចេះពីរបៀបអភិវឌ្ឍន៍ខ្លួន ក្នុងការឈានឆ្ពោះទៅកាន់គោលដៅដែលខ្លួនចង់បានដោយជោគជ័យ និងសម្រាប់បំពេញតម្រូវការរបស់ប្រទេសជាតិផងដែរ (IIEP, 2017)។ ជាក់ស្តែង នៅក្នុងវេទិកាពិភពលោកស្តីពីវិស័យអប់រំឆ្នាំ២០១៥នៅក្នុងទីក្រុងអ៊ិនឈុន សាធារណៈរដ្ឋកូរ៉េ អង្គការយូណេស្កូ UNESCO បានអនុម័តនូវសេចក្តីថ្លែងការណ៍រួមមួយហៅថា សេចក្តីថ្លែងការណ៍ទីក្រុង អ៊ិន ឈុន សម្រាប់វិស័យអប់រំឆ្នាំ២០៣០ ដែលក្នុងនោះបានកំណត់ដាក់ចេញចក្ខុវិស័យថ្មីសម្រាប់វិស័យអប់រំ គឺគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពចំណុចទី៤ (Sustainable Development Goals,SDGs4 ) ដោយដោះស្រាយបញ្ហាប្រឈមដែលមានសេសសល់ពីផែនការ ការអប់រំសម្រាប់ទាំងអស់គ្នា Education for All (EFA) និង គោលដៅអភិវឌ្ឍន៍សហសវត្សរ៍ Millennium Development Goals (MDGs) ហើយនិងឆ្លើយតបយ៉ាងពេញលេញទៅនឹងការធានាឱ្យបាននូវការអប់រំមានគុណភាព បរិយាបន្ន សមធម៌ និងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។ មួយវិញទៀត កត្តាបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍(Information Communication and Technology) ព្រមទាំងភាសាបរទេស ជាកត្តាចាំបាច់ក្នុងការធានាឱ្យការផ្សព្វផ្សាយចំណេះដឹង វិធីសាស្ត្រៀន និងបង្រៀនក្នុង

ប្រព័ន្ធអប់រំឱ្យកាន់តែមានប្រសិទ្ធភាព គុណភាព និងសម្បូរបែបបន្ថែមទៀត (វិស័យអប់រំឆ្នាំ២០៣០, ២០១៥)។ ឆ្លើយតបនឹងសេចក្តីអំពាវនាវជាសកល ក្រសួងអប់រំ យុវជន និងកីឡាកម្ពុជាបានរៀបចំផែនទីបង្ហាញផ្លូវវិស័យអប់រំឆ្នាំ២០៣០ ដើម្បីឱ្យកម្ពុជាសម្រេចបានឋានៈជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសចំណូលខ្ពស់នៅឆ្នាំ២០៥០ (ក្រសួងអប់រំ យុវជន និងកីឡា, ២០១៩)។ ដោយមើលឃើញពីបម្រែបម្រួលនៃស្ថានភាពសាកលភាវូបនីយកម្មទាំងឡាយនេះបានជាប្រទេសជាច្រើន បានទាញយកចំណេញពីបញ្ហានេះ ដោយការបង្កើននូវទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការជាអន្តរជាតិរវាងគ្នាក៏ដូចជាចងក្រងជាសហគមន៍តែមួយឱ្យកាន់តែជិតស្និទ្ធ រឹងមាំបន្ថែមទៀត ព្រមទាំងអាចជួយគ្នាទៅវិញទៅមកទៀតផង។ ហេតុនេះប្រទេសទាំងឡាយដែលស្ថិតនៅតំបន់អាស៊ីអាគ្នេយ៍បានរួមគ្នាបង្កើតជាសមាគមន៍មួយហៅថាអាស៊ាន (បណ្ឌិត ឈុន ណារ៉េត, ២០១០)។ ដើម្បីឱ្យទំនាក់ទំនងជាលក្ខណៈអន្តរជាតិកាន់តែងាយស្រួល និងមានប្រសិទ្ធភាព គេចាំបាច់ត្រូវតែពង្រឹងទៅលើភាសាសម្រាប់ទំនាក់ទំនងមានដូចជា ភាសាបច្ចេកវិទ្យា និងភាសាបរទេសជាដើម។ ម្យ៉ាងវិញទៀត ទោះបីជាអង្គការសហប្រជាជាតិ (United Nation) បានកំណត់ពីភាសាផ្លូវការរួមមាន ភាសាអង់គ្លេស បារាំង អេស្ប៉ាញ រុស្ស៊ី និងភាសាចិនក៏ដោយ ក៏ភាសាអង់គ្លេសជាភាសាផ្លូវការ ត្រូវបានដើរតួនាទីយ៉ាងសំខាន់គួរឱ្យកត់សំគាល់នៅក្នុងប្រទេសច្រើនជាង ៧០ ដូចជា ហ្គាណា ឥណ្ឌា នីហ្សេរីយ៉ា និងសឹង្ហបុរី ជាដើម។ ភាសាអង់គ្លេស ក៏បានក្លាយជាភាសាមួយដែលត្រូវបានជ្រើសរើសសម្រាប់ប្រើជាសាកលតាំងពីឆ្នាំ ១៩៩៥ (David Crystal, 2003)។ ចំណែកសមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ ដែលហៅកាត់ថាអាស៊ានក៏បានជ្រើសរើសយកភាសាអង់គ្លេសជាភាសាផ្លូវការសម្រាប់ប្រើក្នុងតំបន់អាស៊ានទាំងមូលផងដែរ ដូចមានចែងក្នុងមាត្រាទី៣៤ អំពីភាសាដែលប្រើប្រាស់ជាផ្លូវការក្នុងអាស៊ានគឺភាសាអង់គ្លេស (ធម្មនុញ្ញនៃសមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍, ២០០៧)។ ទន្ទឹមគ្នានេះដែរ បើយោងទៅតាមផែនការមេស្តីពីការតភ្ជាប់រវាងបណ្តាប្រទេសក្នុងតំបន់អាស៊ានឆ្នាំ២០២៥ បានបង្ហាញឱ្យដឹងថា ការផ្សារភ្ជាប់ប្រទេសអាស៊ានទាំងនេះនឹងក្លាយជាការបង្កនូវឱកាសជាច្រើនផងដែរ ដូចជាលើកកម្ពស់ការប្រកួតប្រជែងបរិយាបន្ន និងសហគមន៍ជាដើម។ មិនតែ

ប៉ុណ្ណោះ ផែនការនេះនឹងផ្សារភ្ជាប់មនុស្សគ្រប់គ្នានៃអាស៊ានឱ្យក្លាយជាសហគមន៍តែមួយតាមរយៈ របៀបដែលពួកគេរស់នៅ ធ្វើការ និងធ្វើដំណើរ។ ជាពិសេសជាងនេះទៅទៀត នៅក្នុងផែនការជាយុទ្ធសាស្ត្រចំណុចទី៥នៃ MPAC ២០២៥ ក៏កំណត់យ៉ាងច្បាស់ផងដែរ ពីចលភាពប្រជាជនថាត្រូវតែបង្កើនកម្រិតជំនាញ និងជំរុញប្រជាជាតិអាស៊ានឱ្យក្លាយជាប្រភពធនធានសំខាន់បំផុតរបស់អាស៊ាន (Master Plan on ASEAN Connectivity 2025, 2017)។ ដោយសារប្រទេសកម្ពុជា ជាសមាជិករបស់អាស៊ាន ហើយម៉្យាងទៀតនៅក្នុងសាកលភាវូបនីយកម្មទំនាក់ទំនងបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ វប្បធម៌ និងប្រព័ន្ធសេដ្ឋកិច្ចចំរុះត្រូវបានចែករំលែកពីមួយទៅមួយដែលត្រូវបានធ្វើឡើងជាភាសាអង់គ្លេស។ ហេតុនេះយុវជនរបស់កម្ពុជា ជាការពិតណាស់ចាំបាច់ត្រូវតែពង្រឹង បង្កើននូវជំនាញ និងចំណេះដឹងរបស់ខ្លួនជាពិសេសទៅលើសមត្ថភាពភាសាបរទេសមានភាសាអង់គ្លេសជាដើម ព្រមទាំងសមត្ថភាពប្រើប្រាស់បច្ចេកវិទ្យាសម្រាប់ធ្វើការឱ្យបានកាន់តែទូលំទូលាយ ដើម្បីឆ្លើយតបទៅនឹងការប្រកួតប្រជែង និងតម្រូវការទីផ្សារក្នុងតំបន់ក៏ដូចជាអន្តរជាតិជាពិសេសគឺដើម្បីសម្របខ្លួនទៅតាមពិភពលោកនាសម័យទំនើបនេះ។

## ១.២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ដោយយល់ឃើញថាភាសាអង់គ្លេស គឺជាភាសាសម្រាប់ពិភពលោកទាំងមូលអស់រយៈពេលជាងមួយសតវត្សរ៍មកហើយ ព្រមទាំងត្រូវបានគេទទួលស្គាល់នៅក្នុងបណ្ដាប្រទេសជាច្រើនជុំវិញពិភពលោក។ វាក៏នឹងនៅតែបន្តតួនាទីឈានមុខគេដដែលនៅថ្ងៃអនាគត។ មានអ្នកនិយាយភាសាអង់គ្លេសជាជនជាតិដើមប្រហែល ៣៣០លាននាក់ និងអ្នកមិនមែនជាជនជាតិដើមប្រហែល ៤៣០លាននាក់ (David Crystal, 2003)។ ម៉្យាងទៀត នៅក្នុងច្បាប់អប់រំរបស់ព្រះរាជាណាចក្រកម្ពុជាក្នុងជំពូកទី៥ ដែលចែងអំពីគុណភាព និងប្រសិទ្ធភាពអប់រំមាត្រា២៤ ស្ដីអំពីភាសាប្រើប្រាស់ក្នុងការបង្រៀន និងរៀនបានចែងថាភាសាបរទេសដែលជាភាសាអន្តរជាតិ ត្រូវបានកំណត់ជាក់លាក់ជាមុខវិជ្ជាសិក្សាមួយសម្រាប់កម្មវិធីសិក្សាគោលនៃការអប់រំចំណេះទូទៅស្របតាមសេចក្ដីត្រូវការរបស់អ្នកសិក្សា (ក្រសួងអប់រំ យុវជន និងកីឡា, ២០០៧)។ នៅក្នុងប្រទេសកម្ពុជា តាំងពីឆ្នាំ១៩៨៩មកភាសាអង់គ្លេស ត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធី

សិក្សាចំណេះទូទៅជាភាសាបរទេសចាប់ពីថ្នាក់ទី៧រហូតដល់ទី១២ (Neau Vira, 2003)។ ដោយមើលឃើញពីសារៈសំខាន់នៃភាសាអង់គ្លេសនាសម័យសាកលភាវូបនីយកម្ម បានជំរុញឱ្យរដ្ឋាភិបាលនៃប្រទេសជាច្រើននៅលើសាកលលោក ងាកមកផ្ដោតការយកចិត្តទុកដាក់លើកម្មវិធីអប់រំភាសាបរទេស។ ជាក់ស្ដែងនៅក្នុងប្រទេសកម្ពុជាចាប់ពីឆ្នាំ២០១៤មក ភាសាអង់គ្លេសត្រូវបានដាក់បញ្ចូលជាផ្លូវការនៅក្នុងកម្មវិធីសិក្សាថ្នាក់ជាតិចាប់ពីកម្រិតថ្នាក់ទី៤ រហូតដល់ថ្នាក់ទី១២ (Neau Vira, 2003)។ ការដាក់បញ្ចូលភាសាអង់គ្លេសចាប់តាំងពីថ្នាក់បឋមសិក្សាបែបនេះគឺ ដើម្បីជួយឱ្យសិស្សទទួលបានមូលដ្ឋានគ្រឹះនៃចំណេះដឹងតាំងពីថ្នាក់ក្រោមមក សម្រាប់បន្តការសិក្សាឱ្យកាន់តែងាយស្រួលនៅកម្រិតមធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិ ព្រមទាំងទទួលបានចំណេះដឹងទូលំទូលាយ មានទំនាក់ទំនងជាមួយពិភពវប្បធម៌ វិទ្យាសាស្ត្រ បច្ចេកវិទ្យាទំនើប ពាណិជ្ជកម្ម ឧស្សាហកម្ម និងការទូត ព្រមទាំងមានការទទួលខុសត្រូវ មានមនសិការស្នេហាជាតិ ស្គាល់ពីសិទ្ធិ និងកាតព្វកិច្ច ដើម្បីរួមចំណែកឱ្យកាន់តែសកម្មថែមទៀតក្នុងការអភិវឌ្ឍប្រទេសជាតិ ហើយការដាក់បញ្ចូលភាសាអង់គ្លេសនៅតាមសាលាមធ្យមសិក្សាចំណេះទូទៅសាធារណៈនេះក៏បានសបញ្ជាក់អោយឃើញផងដែរថា ក្រសួងមានឆន្ទៈ ព្រមទាំងចង់ជំរុញឱ្យសិស្សានុសិស្សទាំងអស់ បានយល់ដឹងពីសារប្រយោជន៍នៃភាសាអង់គ្លេស នៅក្នុងជីវភាពរស់នៅ និងការប្រកបការងារនាបរិបទបច្ចុប្បន្ន និងទៅអនាគត (ក្រសួងអប់រំ យុវជន និងកីឡា, ២០១៨)។ ជាងនេះទៅទៀត នៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០១៩ ដល់ ឆ្នាំ ២០២៣ ក្រសួងអប់រំ យុវជន និងកីឡា បានអនុម័តក្របខ័ណ្ឌកម្មវិធីសិក្សានៅឆ្នាំ២០១៦ និងកម្មវិធីសិក្សាលម្អិតគ្រប់មុខវិជ្ជា គ្រប់ភូមិសិក្សានៅឆ្នាំ២០១៨ ដែលចែកជាបីភូមិសិក្សាដាច់ដោយឡែកពីគ្នា តែប្រទាក់ក្រឡាគ្នា និងគាំទ្រគ្នាពីភូមិសិក្សាមួយទៅភូមិសិក្សាមួយទៀត ពីមុខវិជ្ជាមួយទៅមុខវិជ្ជាមួយទៀត និងភាពឆ្លើយតបនៃកម្មវិធីសិក្សាទៅឧត្តមសិក្សា។ មុខវិជ្ជាមួយចំនួនត្រូវបានកែសម្រួលបញ្ចូល និងបំបែកដូចជាមុខវិជ្ជា បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានភាសាបរទេស បំណិនជីវិតតាមមូលដ្ឋាន និងមុខវិជ្ជាអប់រំសុខសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម ព្រមទាំងគណិតវិទ្យា។ ការកែទម្រង់កម្មវិធីសិក្សាទាំងបីកម្រិតសំដៅបណ្ដុះបណ្ដាលបុគ្គលិកលក្ខណៈពេញលេញរបស់អ្នក

សិក្សាលើផ្នែករាងកាយ បញ្ញា សីលធម៌ តម្លៃ និងបំណិនមូលដ្ឋានសម្រាប់ការអប់រំនៅកម្រិតបន្តដើម្បីឱ្យក្លាយខ្លួនជាបុគ្គលល្អដែលមានប្រយោជន៍សម្រាប់ខ្លួនឯង គ្រួសារ សហគមន៍ ប្រទេសជាតិ និងពិភពលោក (ក្រសួងអប់រំ យុវជន និងកីឡា, ២០១៩)។ ក្នុងន័យនេះមានន័យថា ភាសាអង់គ្លេសមានទំនាក់ទំនងជាមួយមុខវិជ្ជាផ្សេងៗទៀត ហើយមានសារសំខាន់សម្រាប់បន្តការសិក្សាទៅថ្នាក់ឧត្តមសិក្សា។ ហេតុនេះភាសាអង់គ្លេសក៏ជាមុខវិជ្ជាមួយចាំបាច់សម្រាប់សិស្សក្នុងកម្រិតមធ្យមសិក្សាទុតិយភូមិ ដែលជាកម្រិតចុងក្រោយនៃសាលាចំណេះទូទៅ ហើយត្រៀមចូលថ្នាក់ឧត្តមសិក្សា។ ម្យ៉ាងទៀត ការបណ្តុះបណ្តាលនូវវិធីសាស្ត្រថ្មីៗ ព្រមទាំងការធ្វើបច្ចុប្បន្នភាពនៃសៀវភៅសិក្សាគោលជាបន្តបន្ទាប់សុទ្ធសឹងតែជាកិច្ចខិតខំប្រឹងប្រែង ជានាឱ្យចំណេះដឹងផ្នែកភាសាបរទេសរបស់យុវជនកម្ពុជាកាន់តែប្រសើរឡើងឈានឆ្ពោះទៅដល់កម្រិតតំបន់ និងអន្តរជាតិ ក៏ដូចជាស្របទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs)ថែមទៀតផង (ក្រសួងអប់រំ យុវជន និង កីឡា, ២០១៩)។

ទោះជាកន្លងមក មុខវិជ្ជាភាសាអង់គ្លេសមានការកែទម្រង់ជាបន្តបន្ទាប់ក្តីតាមរយៈលទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិមុខវិជ្ជាភាសាបរទេសសិស្សទទួលបានពិន្ទុទាបច្រើន ដែលបង្ហាញឱ្យយើងឃើញថាសមត្ថភាពភាសាបរទេសរបស់សិស្សនៅមានកម្រិតនៅឡើយ (ក្រសួងអប់រំ យុវជន និងកីឡា, ២០១៩)។ ម៉្យាងទៀត តាមរយៈលទ្ធផលនៃការស្រាវជ្រាវរបស់និស្សិតបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៥ដែលបានសិក្សាទៅលើបំណិនអាននេះបានបង្ហាញឱ្យឃើញថា បំណិនអានជាភាសាអង់គ្លេសរបស់សិស្សនៅមានលក្ខណៈទាប (ប៊ុន វឌ្ឍនា, ២០១៨)។ ដោយពិនិត្យឃើញថាពុំទាន់មានអ្នកសិក្សាស្រាវជ្រាវណាបានធ្វើការសិក្សា លើបញ្ហានេះនៅកម្រិតមធ្យមសិក្សាទុតិយភូមិនៅឡើយអ្នកស្រាវជ្រាវក៏មានបំណងចង់ធ្វើការសិក្សាពីបំណិនអានជាភាសាអង់គ្លេសរបស់សិស្សនៅកម្រិតមធ្យមសិក្សាទុតិយភូមិ ដើម្បីស្វែងយល់ឱ្យបានកាន់តែច្បាស់ និងចូលរួមជាប្រយោជន៍ដល់ការសិក្សារបស់សិស្ស។

## ១.៣. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះមានគោលបំណង៖

១. រកឱ្យឃើញកម្រិតនៃការយល់ដឹងរបស់សិស្ស ក្នុងការប្រើប្រាស់វិធីសាស្ត្រលើបំណិនអានភាសាអង់គ្លេស។

២. ការសិក្សាប្រៀបធៀប ការយល់ដឹងរបស់សិស្សនៅក្នុងខេត្តតាកែវ ចំពោះបំណិនអានជាភាសាអង់គ្លេសដោយចែកទៅតាមភេទ ចំនួនឆ្នាំដែលរៀនភាសា និងចំនួនម៉ោងដែលបានអានភាសាអង់គ្លេស។

## ១.៤. សំណួរស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងគោលបំណងនៃការស្រាវជ្រាវខាងលើនេះ អ្នកសិក្សាបានកំណត់លើកយកសំណួរស្រាវជ្រាវចំនួនពីរមកពិភាក្សា ដូចខាងក្រោម៖

១. តើសិស្សនៅកម្រិតមធ្យមសិក្សាទុតិយភូមិក្នុងខេត្តតាកែវ មានការយល់ដឹងលើការប្រើប្រាស់វិធីសាស្ត្រនៃបំណិនអានភាសាអង់គ្លេសក្នុងកម្រិតណា?

២. តើមានភាពដូចគ្នា ឬខុសគ្នាដែរឬទេ ចំពោះការយល់ដឹងពីវិធីសាស្ត្របំណិនអានភាសាអង់គ្លេសរបស់សិស្ស បើយោងទៅតាម ភេទ ចំនួនឆ្នាំដែលពួកគេបានរៀនភាសាអង់គ្លេស និងចំនួនម៉ោងដែលពួកគេបានអានភាសាអង់គ្លេស ?

## ១.៥. សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទស្តីពីការយល់ដឹងពីវិធីសាស្ត្រនៃការអានភាសាអង់គ្លេសរបស់សិស្សនៅកម្រិតមធ្យមសិក្សាទុតិយភូមិក្នុងខេត្តតាកែវ មានសារៈសំខាន់ដូចតទៅ៖

- ❖ យល់ដឹងពីយុទ្ធសាស្ត្រអានភាសាអង់គ្លេសរបស់សិស្ស ដែលអាចជួយឱ្យសិស្សយល់ដឹងបានកាន់តែច្រើនលើការសិក្សាភាសាអង់គ្លេស ដើម្បីលើកកម្ពស់ដល់ការទំនាក់ទំនងរបស់ពួកគាត់ ក្នុងការប្រកួតប្រជែងឱកាសការងារទាំងក្នុងតំបន់ និងក្នុងពិភពលោក។

❖ ជួយឱ្យការបង្រៀនរបស់គ្រូកាន់តែប្រសើរឡើង ដោយសារគ្រូបង្រៀនបានយល់ច្បាស់អំពីរបៀបដែលសិស្សចូលចិត្ត ជាហេតុនាំឱ្យការអប់រំមានគុណភាព ប្រសិទ្ធភាព ឆ្ពោះទៅរកការអភិវឌ្ឍន៍ធនធានមនុស្ស និងកសាងប្រទេសឱ្យកាន់តែមានការរីកចម្រើន។

❖ លើកកម្ពស់ការរៀនភាសាអង់គ្លេស ជាពិសេសក្នុងបំណិនអាន និងរួមចំណែកជួយសិស្សក្នុងការរៀនដោយខ្លួនឯងទោះជានៅក្នុងសាលា ឬក្រៅសាលាក្តី ស្របគ្នាទៅនឹងអត្ថន័យការរៀនពេញមួយជីវិតនាសតវត្សរ៍ទី២១នេះ។

❖ ជាការចូលរួមវិភាគទាន និងពញ្ញាក់ស្មារតីក្នុងការយកចិត្តទុកដាក់ឡើងវិញទៅលើសមត្ថភាពនៃបំណិនអាន ពិសេសការលើកទឹកចិត្ត និងគាំទ្រសមត្ថភាពបំណិនអានរបស់សិស្សជាភាសាជាតិ និងភាសាបរទេសឱ្យកាន់តែមានភាពប្រសើរ។

❖ ជាឯកសារសម្រាប់សិស្ស និស្សិត និងអ្នកសិក្សាជំនាន់ក្រោយៗទៀតយកទៅសិក្សាស្រាវជ្រាវលើបំណិនដទៃផ្សេងៗទៀត ឬប្រើវិសាលភាពទូទាំងប្រទេសជាបន្ត និងសម្រាប់ឆ្លើយតបទៅនឹងគោលនយោបាយរបស់ក្រសួងអប់រំ យុវជន និងកីឡា ក៏ដូចជាការវិវត្តផ្នែកភាសាផងដែរ។

## ១.៦. វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ

### ១.៦.១. វិសាលភាពនៃការស្រាវជ្រាវ

- **ខ្លឹមសារ៖** ការស្រាវជ្រាវនេះ មានខ្លឹមសារទាំងស្រុងផ្តោតទៅលើ វិធីសាស្ត្រអានដែលក្តោបទៅលើយុទ្ធសាស្ត្រអានជាភាសាអង់គ្លេសទាំង៦ (6 Reading Sub-skills) គឺ៖

❖ Scanning ៖ អំណានរហ័សសម្រាប់ស្វែងរកព័ត៌មានជាក់លាក់ណាមួយដូចជា កាលបរិច្ឆេទ លេខទូរស័ព្ទតួលេខ ឬឆ្នាំជាដើម។

❖ Skimming ៖ អំណានរហ័ស សម្រាប់ស្វែងរកគោលគំនិតសំខាន់ ដែលភាគច្រើនមាននៅក្នុងសេចក្តីផ្តើម ឬសេចក្តីបញ្ចប់។

- Reading to confirm Information ៖ ការអានដើម្បីស្វែងរកព័ត៌មានមកអះអាងបញ្ជាក់។
- Reading for Main idea ៖ ការអានយ៉ាងលម្អិតដើម្បីឱ្យយល់អំពីគំនិតសំខាន់នៃអត្ថបទទាំងមូល។
- Reading for Specific Information ៖ ការអានយ៉ាងល្អិតល្អន់ដើម្បីពិនិត្យមើលអត្ថន័យជាក់លាក់របស់អត្ថបទទាំងមូល។
- Reading for Detailed Comprehension ៖ ការអានលម្អិត ដើម្បីធ្វើការវិនិច្ឆ័យលើការយល់ដឹងទៅលើអត្ថបទទាំងមូល។

### ១.៦.២. ដែនកំណត់

អ្នកស្រាវជ្រាវបានជ្រើសរើសយកខេត្តតាកែវជាគោលដៅ ដោយអ្នកសិក្សាយល់ឃើញថាខេត្តនេះជាខេត្តមួយមានវ័យចំណាស់ជាងគេក្នុងចំណោមរាជធានី ខេត្តទាំង២៥នៃព្រះរាជាណាចក្រកម្ពុជា ហើយក៏ជាខេត្តដែលសម្បូរទៅដោយធនធានធម្មជាតិមានដូចជា សម្បត្តិវប្បធម៌ ប្រវត្តិសាស្ត្រ និងជាខេត្តដែលមានចរន្តរស់រវើកផ្នែកសេដ្ឋកិច្ច ទីផ្សារការងារ និងទេសចរណ៍។ ដូច្នេះការសិក្សាភាសាអង់គ្លេស ពិតជាមានសារៈសំខាន់ខ្លាំងណាស់ចំពោះសិស្សានុសិស្សនៅកម្រិតវិទ្យាល័យ មុនពេលដែលពួកគេឈានជើងចូលមហាវិទ្យាល័យដើម្បីសិក្សាបន្ត និងចាប់យកឱកាសទីផ្សារការងារក្នុងតំបន់ និងពិភពលោក។ អ្នកស្រាវជ្រាវបានជ្រើសរើសយកវិទ្យាល័យចំនួន៨នៅក្នុងខេត្តតាកែវ រួមមានដូចជាវិទ្យាល័យសម្តេចក្រុមព្រះអង្គនាប វិទ្យាល័យសុខអាន១ឧសភា វិទ្យាល័យព្រៃទប់ វិទ្យាល័យហ៊ុនសែន ពោធិ៍អំពិល វិទ្យាល័យសុខអានលាយបូរ វិទ្យាល័យសុខអានសន្លុង វិទ្យាល័យហ៊ុនសែនព្រៃឈើទាល និងវិទ្យាល័យព្រៃឈើទាល។ ជាងនេះទៅទៀត ដើម្បីឱ្យការប្រមូលព័ត៌មានបានច្បាស់លាស់ និងត្រឹមត្រូវ អ្នកស្រាវជ្រាវបានប្រើប្រាស់ភាគសំណាក ២ ប្រភេទគឺ ភាគសំណាកទីមួយមាន លោកគ្រូ អ្នកគ្រូ បង្រៀនភាសាអង់គ្លេសថ្នាក់ទី១០ ទី

១១ និងទី១២ ភាគសំណាកទីពីរគឺ សិស្សានុសិស្សនៅកម្រិតមធ្យមសិក្សាទុតិយភូមិ ថ្នាក់ទី១០ ទី១១ និងទី១២ នៃវិទ្យាល័យទាំង៨ដែលបានជ្រើសរើស។

## ១.៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះ ចែកចេញជា ៥ជំពូក ដែលរួមមាន៖

**ជំពូកទី១ ៖ សេចក្តីផ្តើម**

ជំពូកនេះពណ៌នាដោយសង្ខេបទៅលើ លំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។

**ជំពូកទី២ ៖ រំលឹកទ្រឹស្តី**

ជំពូកនេះនឹងធ្វើការបកស្រាយពីឯកសារពាក់ព័ន្ធនានាក៏ដូចជា ការស្រាវជ្រាវមុនៗដែលមានទាក់ទងនឹងប្រធានបទ និងពន្យល់យ៉ាងលម្អិតទៅលើវិធីសាស្ត្រផ្សេងៗក្នុងការបង្រៀន និងរៀនអំណានជាភាសាទី១ និងភាសាអង់គ្លេសជាភាសាទី២ ទ្រឹស្តីនានាដែលទាក់ទងទៅនឹងការបង្រៀនបំណិនអាន ព្រមទាំងជំនាញតូចៗ ដែលមានក្នុងបំណិនអាន។

**ជំពូកទី៣ ៖ វិធីសាស្ត្រនៃការស្រាវជ្រាវ**

ជំពូកនេះនឹងលើកឡើងពីវិធីសាស្ត្រនៃការស្រាវជ្រាវ និងគម្រោងនៃការវិភាគ ដោយកំណត់ទៅលើអថេរឯករាជ្យ និងអថេរមិនឯករាជ្យ សម្រាប់ការសិក្សា បង្ហាញពីការកំណត់ពេលវេលា និងទីកន្លែងគោលដៅដែលត្រូវសិក្សាស្រាវជ្រាវ។ ការជ្រើសរើសវិធីសាស្ត្រប្រមូលទិន្នន័យ វិភាគសំណាក ការប្រើប្រាស់ឧបករណ៍ស្ថិតិ ការប្រើរូបមន្តសម្រាប់គណនា និងជ្រើសរើសវិធីសាស្ត្រប្រមូលទិន្នន័យ។

**ជំពូកទី៤ ៖ លទ្ធផលនៃការស្រាវជ្រាវ និងការពិភាក្សា**

ជំពូកនេះនឹងធ្វើការពិភាក្សាយ៉ាងលម្អិតទៅលើកម្រងសំណួរសម្រាប់យកមកវិភាគទិន្នន័យ ធ្វើការបកស្រាយទិន្នន័យដែលប្រមូលបានជាក់ស្តែង និងបានពិភាក្សាសម្រាប់ឆ្លើយតបទៅនឹងគោលបំណងនៃការសិក្សាស្រាវជ្រាវ។

**ជំពូកទី៥ ៖ សេចក្តីសន្និដ្ឋាន និងសំណូមពរ**

ជំពូកនេះបានសង្ខេបគ្រប់លទ្ធផលទាំងអស់ដែលបានរកឃើញដើម្បីធ្វើការសន្និដ្ឋាន និងផ្តល់ជាយោបល់ ឬជាសំណូមពរសម្រាប់ធ្វើការកែលម្អ។

# ជំពូកទី ២
# រំលឹកទ្រឹស្តី

# ជំពូកទី២

# រំលឹកទ្រឹស្តី

## ២.១. ទិដ្ឋភាពទូទៅពីការសិក្សាភាសាបរទេសនៅកម្ពុជា

ក្រោយពីភាសាបរទេសដែលមានភាសាបារាំង និងភាសាអង់គ្លេសត្រូវបានអនុញ្ញាតឱ្យមានការសិក្សាជាផ្លូវការនាអំឡុងឆ្នាំ១៩៨៩មក (Neau Vira, 2003) ក៏មានការសង្កេតឃើញថាភាសាអង់គ្លេសមានការកើនប្រជាប្រិយភាពខ្លាំងក្នុងចំណោមអ្នកសិក្សាទាំងឡាយ គឺដោយសារតែមានព្រឹត្តិការណ៍ដែលសំខាន់ៗចំនួន២កើតឡើងដូចជា លំហូរនៃកងកម្លាំងរក្សាសន្តិភាពអង្គការសហប្រជាជាតិដើម្បីជួយរៀបចំដំណើរការបោះឆ្នោតនាអំឡុងឆ្នាំ១៩៩២-១៩៩៣ និងការចូលជាសមាជិកសមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍(ASEAN) (David Cristal, 2003)។ ម្យ៉ាងទៀតតាមរយៈស្នាដៃរបស់ឯកឧត្តមបណ្ឌិត ហង់ជួន ណារ៉ុន ដែលមានចំណងជើងថា កំណែទម្រង់វិស័យអប់រំនៅកម្ពុជា មាគ៌ាឆ្ពោះទៅរកសង្គមពុទ្ធិ និងវិបុលភាព លោកក៏បានទទួលស្គាល់ដែរថា ប្រទេសកម្ពុជាបានចាប់ផ្តើមប្រែក្លាយបន្តិចម្តងៗ ពីប្រទេសនិយាយភាសាបារាំងទៅជាប្រទេសនិយាយភាសាអង់គ្លេសក្រោមហេតុផល ដូចដែលបានលើកបញ្ជាក់ពីខាងលើ (ហង់ជួន ណារ៉ុន, ២០១៦)។ មុខវិជ្ជាភាសាបរទេស ជាមុខវិជ្ជាចាំបាច់ដែលត្រូវសិក្សា។ ភាសាបរទេសគឺជាមុខវិជ្ជាយានក្នុងការប្រាស្រ័យទាក់ទងក្នុងការរស់នៅប្រចាំថ្ងៃ ការសិក្សាស្រាវជ្រាវ ការប្រកបកិច្ចការងារ ការអភិវឌ្ឍការគិត ការវិភាគ និងការច្នៃប្រឌិតដើម្បីឆ្លើយតបទៅនឹងការផ្លាស់ប្តូរសង្គម និងការជឿនលឿនផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យាក្នុងតំបន់ និងសាកលលោក។ ជាងនេះទៅទៀត ភាសាបរទេសមានសារប្រយោជន៍យ៉ាងទូលំទូលាយក្នុងការសិក្សា ការទទួលបានការងារធ្វើ និងការរស់នៅប្រចាំថ្ងៃ (ក្រសួងអប់រំ យុវជន និងកីឡា, ២០០៤)។ បើទោះជាយ៉ាងនេះក្តី មុខវិជ្ជាភាសាបរទេសមិនទាន់ត្រូវបានបញ្ចូលជាមុខវិជ្ជាកាតព្វកិច្ចក្នុងការប្រឡងថ្នាក់ជាតិនៅឡើយ ទោះជាក្នុងកម្រិតមធ្យមសិក្សាបឋមភូមិ ឬមធ្យមសិក្សាទុតិយភូមិក្តី (ក្រសួងអប់រំ យុវជន និង កីឡា, ២០០៥)។ នៅក្នុងការបង្រៀន និងរៀនក្នុងគ្រឹះស្ថានសិក្សាសាធារណៈ គេបានចាត់ទុកភាសាបរទេសជាជីវភាសាដែលមានភាសាអង់គ្លេស ឬភាសាបារាំង សិក្សានៅ

កម្រិតបឋមសិក្សា និងមធ្យមសិក្សាដោយផ្អែកទៅតាមភាសាដែលសិស្សជ្រើសរើសនៅបឋមសិក្សា។ បើសិស្សរៀនភាសាអង់គ្លេសនៅបឋមសិក្សា សិស្សនឹងបន្តរៀនភាសាអង់គ្លេសជាជីវភាសាទី១ និងភាសាបារាំងជាជីវភាសាទី២នៅមធ្យមសិក្សា ឬបើក្នុងករណីផ្ទុយ គឺសិស្សត្រូវរៀនភាសាបារាំងជាជីវភាសាទី១ និងភាសាអង់គ្លេសជាជីវភាសាទី២។ ក្នុងនោះមុខវិជ្ជាភាសាបរទេសមានសមាសភាគបួន គឺការស្តាប់ ការអាន ការនិយាយ និងការសរសេរ ហើយគោលបំណងនៃការសិក្សាភាសាបរទេសគឺជានាឱ្យសិស្សមានសមត្ថភាពទំនាក់ទំនងក្នុងបំណិនទាំងបួន និងក្លាយជាអ្នករៀនពេញមួយជីវិតប្រកបដោយការច្នៃប្រឌិត និងការជឿជាក់ ហើយជាពិសេស ភាសាអង់គ្លេសបានដើរតួជាភាសាសាកលដែលសិស្សត្រូវចេះក្នុងសតវត្សរ៍ទី២១ (ក្រសួងអប់រំ យុវជន និងកីឡា, ២០១៦)។

## ២.២. មុខវិជ្ជាភាសាអង់គ្លេស

ភាសាអង់គ្លេស គឺជាភាសាផ្លូវការមួយដែលត្រូវបានគេប្រើប្រាស់យ៉ាងទូលំទូលាយក្នុងចំណោមភាសាផ្លូវការទាំងឡាយសម្រាប់ការប្រាស្រ័យទាក់ទងគ្នា ការសិក្សា ការស្រាវជ្រាវផ្សេងៗ ការងារជំនួញ ការប្រកបកិច្ចការងារ ការអភិវឌ្ឍការគិត ការវិភាគ និងការច្នៃប្រឌិតដើម្បីឆ្លើយតបទៅនឹងការផ្លាស់ប្តូរសង្គម និងការជឿនលឿនផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យាក្នុងតំបន់ និងសាកលលោក។ ភាសាអង់គ្លេសមានសារប្រយោជន៍យ៉ាងទូលំទូលាយក្នុងការសិក្សា ការទទួលបានការងារធ្វើ ការប្រាស្រ័យទាក់ទងគ្នា និងការរស់នៅប្រចាំថ្ងៃ។ ជាងនេះទៅទៀត បច្ចុប្បន្ននេះភាសាអង់គ្លេសបានក្លាយជាភាសាមួយដែលត្រូវបានគេដាក់ជាភាសាបរទេសសម្រាប់រៀន និងបង្រៀន(EFL)ច្រើនជាង១០០ប្រទេសដូចជា ចិន រុស្ស៊ី អាល្លឺម៉ង់ អេស្ប៉ាញ អេហ្ស៊ីប និងប្រេស៊ីលជាដើម (David Cristal, 2003)។ ក្នុងឆ្នាំ១៩៩៦ចំនួនសិស្ស និងនិស្សិតដែលងាកមកចាប់អារម្មណ៍ទៅលើការសិក្សាភាសាអង់គ្លេស ចាប់ផ្តើមមានការកើនឡើងជាបន្តបន្ទាប់ក្នុងប្រទេសកម្ពុជាខណៈពេលដែលភាសាបារាំងមិនត្រូវបានប្រើប្រាស់ច្រើនដូចមុន (Koji Ikawa, 2008)។ នេះសបញ្ជាក់ឱ្យឃើញថា ភាសាអង់គ្លេសត្រូវបានគេយកចិត្តទុកដាក់ខ្លាំង។ ជាក់ស្តែង ប្រទេសចិន សាធារណៈរដ្ឋកូរ៉េខាងត្បូង និងប្រទេសជប៉ុនបានដាក់បញ្ចូលភាសាអង់គ្លេសទៅក្នុងកម្មវិធីសិក្សាថ្នាក់ជាតិ

របស់ខ្លួន ដើម្បីឱ្យសិស្សសិក្សារៀនសូត្រចាប់ពីថ្នាក់ទី១ឡើងទៅ (Gerald Fallon and Natalei Rublik, 2012)។ ប្រទេសមួយចំនួននៅក្នុងបណ្តាប្រទេសអាស៊ាន ក៏មិនខុសពីនិន្នាការនៃប្រទេសជាច្រើនទៀតនៅលើពិភពលោកដែរ គឺភាសាអង់គ្លេសត្រូវបានគេចាត់ទុកជាភាសាបរទេសចាំបាច់ និងមានសារៈសំខាន់ ហើយបានដាក់បញ្ចូលមុខវិជ្ជានេះទៅក្នុងកម្មវិធីសិក្សាថ្នាក់ជាតិរបស់ពួកគេ។ ជាក់ស្តែងនៅក្នុងប្រព័ន្ធអប់រំប្រទេសថៃ ភាសាអង់គ្លេសត្រូវបានគេដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សាជាតិចាប់ពីថ្នាក់ដំបូងនៅឆ្នាំ១៩៩៦ បើទោះបីជាគោលនយោបាយអប់រំភាសាបរទេសនេះ អាចអនុវត្តបានតែនៅក្នុងទីក្រុង និងនៅសាលាឯកជនក៏ដោយ (Kam, 2006)។ ក្នុងទសវត្សរ៍ឆ្នាំ១៩៧០ ប្រទេសម៉ាឡេស៊ីបានប្រើប្រាស់ និងដាក់បញ្ចូលភាសាអង់គ្លេសទៅក្នុងការបង្រៀន និងរៀនដែលជាផ្នែកមួយនៃប្រព័ន្ធអប់រំបែបទំនើប។ ហើយក្រោយមកភាសាអង់គ្លេស បានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការរីកចម្រើនរបស់បច្ចេកវិទ្យា សេដ្ឋកិច្ច ពាណិជ្ជកម្ម ការទូត និងទំនាក់ទំនងអន្តរជាតិដែលបម្រើឱ្យជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជន (Ahmed, 2015)។ ប្រទេសឥណ្ឌាបានចាត់ទុកភាសាអង់គ្លេស ជាភាសាកាតព្វកិច្ចទាំងនៅក្នុងកម្រិតមធ្យមសិក្សា និងមហាវិទ្យាល័យ ហើយដើម្បីអាចបន្តការសិក្សានៅថ្នាក់ឧត្តមសិក្សា សិស្ស និស្សិតតម្រូវឱ្យមានមូលដ្ឋានគ្រឹះភាសាអង់គ្លេសជាចាំបាច់ (Hywel Coleman, 2011)។ នៅក្នុងបរិបទនៃប្រទេសកម្ពុជា ភាសាអង់គ្លេសគឺជាឧបករណ៍មួយ ចូលរួមចំណែកក្នុងការកសាងសង្គមសេដ្ឋកិច្ចកម្ពុជាឱ្យមានការអភិវឌ្ឍជឿនលឿនទៅមុខ និងជាអាវុធជួយលុបបំបាត់ភាពក្រីក្រនិងភាពល្ងង់ខ្លៅ ព្រមទាំងជាយានជំនិះជួយដល់អ្នកសិក្សាដែលចង់ធ្វើដំណើរទៅកាន់ប្រទេសជុំវិញពិភពលោក (Lydia M. Musau & Migosi Joash Abere, 2015)។

## ២.៣. បំណិនក្នុងការសិក្សាភាសាអង់គ្លេស

ការសិក្សាភាសាអង់គ្លេស គឺផ្តោតសំខាន់ទៅលើសមាសភាគ ឬបំណិន៤សំខាន់ៗដូចជា បំណិនស្តាប់ បំណិននិយាយ បំណិនអាន និង បំណិនសរសេរ (MOEYS, 2015)។

បំណិនស្តាប់ គឺជាសមត្ថភាពក្នុងការកំណត់ និងយល់ពីអ្វីដែលអ្នកដទៃកំពុងនិយាយ ព្រមទាំងជាជំនាញក្នុងការទទួលយកចំណេះដឹងផ្សេងៗនៅជុំវិញខ្លួនតាមរយៈការស្តាប់។ ដំណើរការនេះពាក់ព័ន្ធនឹង

ការយល់ដឹងពីការបញ្ចេញសំឡេង វេយ្យាករណ៍ វាក្យស័ព្ទ និងការយល់អត្ថន័យរបស់អ្នកនិយាយ។ ការស្ដាប់បានល្អជួយឱ្យអ្នកទទួលបាននូវព័ត៌មានច្បាស់លាស់ និងអាចឆ្លើយតបទៅវិញបានត្រឹមត្រូវផងដែរ (Hamouda, 2003)។ ការស្ដាប់ដោយមានបម្រុងប្រយ័ត្នខ្ពស់ និងប្រកបដោយភាពរស់រវើកពិតជាមានសារសំខាន់ខ្លាំងណាស់ ក្នុងការជួយធ្វើឱ្យទំនាក់ទំនងរបស់អ្នកកាន់តែមានភាពស្និទ្ធស្នាលបន្ថែមទៀត (Thomlison, 1984)។

បំណិននិយាយ គឺជាជំនាញក្នុងការនិយាយ បញ្ចេញទស្សនៈ មតិយោបល់ ចែករំលែកការយល់ដឹងទៅកាន់អ្នកដទៃ។ ការនិយាយមានសារប្រយោជន៍ក្នុងទំនាក់ទំនងជីវភាពប្រចាំថ្ងៃក្នុងការផ្ដល់ និងប្រមូលព័ត៌មាន ជាជំនួយបន្ថែមសម្រាប់អភិវឌ្ឍន៍ជំនាញអាន និងសរសេរ (Marry Ann Cunningham Florez, 1999)។

បំណិនអាន គឺជាជំនាញទទួលយកចំណេះដឹង និងព័ត៌មានផ្សេងៗតាមរយៈការអាន។ ការអានត្រូវបានគេចាត់ទុកថាសំខាន់សូម្បីតែជាភាសាជាតិ ឬភាសាអង់គ្លេសក៏ដោយ ព្រោះវាអាចផ្ដល់ឱ្យអ្នកអាននូវភាពរីករាយ ចំណេះដឹង ការយល់ដឹងពីពិភពលោក ជំនាញសង្គម និងធ្វើឱ្យជីវិតកាន់តែប្រសើរឡើង។ ជាងនេះទៅទៀត ការអានជាភាសាអង់គ្លេសជួយឱ្យអ្នករៀនភាសាបានកាន់តែរហ័ស និងពេញលេញ ព្រមទាំងឆាប់ទទួលបានជោគជ័យ ប៉ុន្តែវាទាមទារឱ្យអ្នកអានត្រូវមានការយកចិត្តទុកដាក់ និងតាំងចិត្តខ្ពស់ ព្រោះវាក៏អាចជួយអ្នកអានឱ្យចេះវាក្យស័ព្ទ និងមានគំនិតច្រើន ទទួលបានព័ត៌មានច្រើនជំនួយដល់សមត្ថភាពនិយាយ និងសមត្ថភាពសរសេររបស់អ្នក ព្រមទាំងអាចឱ្យអ្នករៀនដោយខ្លួនឯងផងដែរ (Reading Skills Guide, 2020)។ ការអានផ្ដល់ឱ្យអ្នករៀនភាសានូវឱកាសចាប់យកចំណេះដឹង វេយ្យាករណ៍ ពង្រឹងវាក្យស័ព្ទ យល់ដឹងកាន់តែច្បាស់លើអត្ថបទសំណេរ និងជួយដល់ការនិយាយភាសាអង់គ្លេសឱ្យកាន់តែប្រសើរ (Patrici L, Carrell, J Devine, DE Eskey, 1988)។

បំណិនសរសេរ គឺជាជំនាញក្នុងការសរសេរនូវគំនិត យោបល់ ការពិតរឿងផ្សេងៗជាដើមដោយប្រើប្រាស់ពាក្យពេចន៍ សំណង់ប្រយោគ សញ្ញាវណ្ណយុត្តិឱ្យបានត្រឹមត្រូវក្នុងការបង្ហាញគំនិត ទស្សនៈរបស់ខ្លួនទៅកាន់អ្នកអាន។ ដើម្បីសរសេរឱ្យបានល្អ អ្នកសិក្សាចាំបាច់ត្រូវយល់ឱ្យបានច្បាស់ពីវប្បធម៌ និងប្រពន្ធ័នៃភាសានោះដូចជា ចំណេះដឹងលើវាក្យស័ព្ទ វេយ្យាករណ៍ រចនាសម្ព័ន្ធ ឬទម្រង់នៃការសរសេរ និងការប្រើប្រាស់វាក្យស័ព្ទ ជាដើម (Kumar, 2020)។ ការនិយាយភាសាកំណើត គឺមនុស្សទាំងអស់អាចទទួលយកតាមធម្មជាតិ ប៉ុន្តែការសរសេរចាំបាច់ត្រូវតែរៀនដោយយកចិត្តទុកដាក់ (Jeremy Harmer, 1988)។

សមាសភាគទាំង៤ នៃភាសាអង់គ្លេសមានទំនាក់ទំនង និងជាជំនួយដល់គ្នាទៅវិញទៅមកដែលអ្នកសិក្សាគួរតែយកចិត្តទុកដាក់ខិតខំសិក្សាឱ្យបានល្អ។

ក្រៅពីសមាសភាគទាំង៤ អ្នករៀនភាសាអង់គ្លេស ក៏គប្បីយល់នូវពាក្យមួយចំនួនដែលពាក់ព័ន្ធនឹងការរៀនភាសាអង់គ្លេស ដូចជា ៖

- **Test of English for International Communication (TOEIC)**៖ គឺជាតេស្តស្តង់ដាអន្តរជាតិនៃជំនាញភាសាអង់គ្លេស សម្រាប់អ្នកនិយាយដែលមិនមែនជាជនជាតិដើម។ វាត្រូវបានបង្កើតឡើងដោយចេតនា ដើម្បីវាស់ស្ទង់ជំនាញភាសាអង់គ្លេសប្រចាំថ្ងៃរបស់មនុស្សដែលធ្វើការនៅក្នុងបរិស្ថានអន្តរជាតិ (Wikipedia, 2020)។
- **Test of English as a Foreign Language (TOEFL)**៖ គឺជាតេស្តសម្រាប់វាស់ជំនាញភាសាអង់គ្លេសរបស់មនុស្ស ដើម្បីដឹងថាពួកគេមានសមត្ថភាពល្អគ្រប់គ្រាន់សម្រាប់ចូលរៀន ឬបញ្ចប់ការសិក្សាក្នុងប្រទេសដែលនិយាយភាសាអង់គ្លេសដែរឬទេ (Wikipedia, 2020)។
- **Teaching English as a Second Language (TESL)**៖ មានន័យថាការបង្រៀនភាសាអង់គ្លេសជាភាសាទីពីរ៖ គឺជាការបង្រៀនភាសាអង់គ្លេសដល់អ្នកដែលរស់នៅក្នុងប្រទេសដែលនិយាយភាសាអង់គ្លេស ប៉ុន្តែភាសាទីមួយមិនមែនជាភាសាអង់គ្លេស (Wikipedia, 2020)។

- **Teaching English to Speakers of Other Languages (TESOL)**៖ គឺជាការបង្រៀនភាសាអង់គ្លេសដល់អ្នកដែលរស់នៅក្នុងប្រទេសដែលនិយាយភាសាដទៃផ្សេងពីភាសាអង់គ្លេស (Oxford Advanced Learner's Dictionary , 2005)។
- **English as a Foreign Language (EFL)**៖ រៀនភាសាអង់គ្លេសជាភាសាបរទេស មានន័យថា ជាការប្រើប្រាស់ភាសាអង់គ្លេស ដោយអ្នកដែលមិនមែនជាជនជាតិអង់គ្លេសហើយក្នុងប្រទេសរបស់គាត់ភាសាអង់គ្លេសមិនត្រូវបានចាត់ទុកជាភាសាជាតិផ្លូវការទេ (COBUILD Advanced English Dictionary, 2020)។ ឧទាហរណ៍៖ ប្រទេសកម្ពុជា
- **English as a Second Language (ESL)៖** រៀនភាសាអង់គ្លេសជាភាសាទី ២៖ មានន័យថា ជាការប្រើប្រាស់ភាសាអង់គ្លេស ដោយអ្នកដែលមិនមែនជាជនជាតិអង់គ្លេស តែក្នុងប្រទេសរបស់គាត់ភាសាអង់គ្លេសត្រូវបានគេនិយាយ និងចាត់ទុកជាភាសាផ្លូវការទី២ បន្ទាប់ពីភាសាកំណើត (Nordquist, 2019)។ ឧទាហរណ៍៖ ប្រទេសសឹង្ហបុរី
- **First Language (L1)** ភាសាទី១៖ មានន័យថា ជាភាសាដែលប្រជាជនក្នុងប្រទេសមួយ បានចេះ និងប្រើប្រាស់ពីកំណើតមក និងជាភាសាជាតិរបស់ប្រទេសនោះ (Oxford Advanced Learner's Dictionary , 2005)។ ឧទាហរណ៍៖ ប្រទេសអង់គ្លេសប្រើភាសាអង់គ្លេស។
- **Second Language (L2)** ភាសាទី២៖ មានន័យថា ជាភាសាមួយផ្សេងទៀតដែលប្រជាជនក្នុងប្រទេសមួយត្រូវការហើយរៀនបន្ទាប់ពីភាសាជាតិកំណើតទី១ របស់ខ្លួន (Oxford Advanced Learner's Dictionary , 2005)។

ឧទាហរណ៍៖ ប្រទេសសឹង្ហបុរីប្រើភាសាអង់គ្លេសជាភាសាទី២។

### ២.៣.១. ការបង្រៀនបំណិនអាន

យោងទៅតាម ឯកសារបំប៉នសមត្ថភាពគ្រូនៅអនុវិទ្យាល័យឆ្នាំ២០១០របស់នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការបានឱ្យដឹងថា បញ្ញត្តិទូទៅក្នុងភាសាខ្មែរ(L1) ក៏បានលើកឡើងទាក់ទងទៅនឹងការ

ពង្រឹង និងពង្រីកសមត្ថភាពយល់ដឹងទៅលើសមត្ថភាពទាំង៤ ការនិយាយ ការស្តាប់ ការអាន និងការសរសេរតាំងពីកម្រិតបឋមសិក្សាដល់មធ្យមសិក្សាផងដែរ ដែលក្នុងនោះបំណិននិយាយ និងសរសេរជាបំណិនសម្រាប់សម្តែងចេញ និងផ្សព្វផ្សាយទៅក្រៅឱ្យអ្នកដទៃបានដឹង។ ចំណែកឯបំណិនពីរទៀត គឺការស្តាប់ និងការអានជាបំណិនសម្រាប់យល់អត្ថន័យអ្វីមួយ និងសម្រាប់ឱ្យមនុស្សបានយល់ព័ត៌មានដែលអ្នកដទៃទៀតបានផ្សព្វផ្សាយ។ ជាពិសេសអំណាន និងការអភិវឌ្ឍផ្នែកភាសាជួយឱ្យសិស្សចេះប្រើប្រាស់ពាក្យបានសមរម្យ និងអានបានត្រឹមត្រូវតាមភាសាវិទ្យា (នាយកដ្ឋានបណ្តុះបណ្តាល និង វិក្រិតការ, ២០១០)។

ម្យ៉ាងវិញទៀតចំពោះភាសាអង់គ្លេស(L2) ការដែលជម្រុញឱ្យសិស្សអានឱ្យបានច្រើនចំពោះអត្ថបទជាភាសាអង់គ្លេសក៏ជាផ្នែកសំខាន់មួយនៃការងារជាគ្រូបង្រៀន ហើយបើគ្រូអាចធ្វើឱ្យការអានកាន់តែមានលក្ខណៈងាយស្រួលសម្រាប់សិស្សគឺកាន់តែប្រសើរ ព្រោះពួកគេត្រូវការអានជាភាសាអង់គ្លេសដើម្បីការងារ ការសិក្សារៀនសូត្ររបស់ពួកគេ ឬសម្រាប់ជាការកំសាន្តជាដើម។ ក្រៅពីនេះ ការអានមានអត្ថប្រយោជន៍ដល់អ្នកសិក្សាភាសាបរទេសដោយសារតែនៅពេលដែលពួកគេបានអាន ការយល់ដឹងពីភាសាកាន់តែមានភាពរីកចម្រើន ជាពិសេសនៅពេលអត្ថបទកាន់តែគួរអោយចាប់អារម្មណ៍ (Harmer, 2002)។ មិនតែប៉ុណ្ណោះ អត្ថបទអានផ្តល់ឱកាសដល់អ្នកសិក្សាភាសាបរទេស ឱ្យយល់បានច្បាស់ពីការប្រើប្រាស់វាក្យស័ព្ទ វេយ្យាករណ៍ វណ្ណយុត្តិ សំណង់ប្រយោគ កថាខណ្ឌ និងអត្ថបទ។ ទន្ទឹមនឹងនេះ អ្នកអានក៏ទទួលបាននូវប្រធានបទថ្មីៗ គំនិតនៃការពិភាក្សាផ្សេងៗ និងមេរៀនល្អៗផងដែរ ដែលទាំងអស់នោះមានសារៈប្រយោជន៍ ជួយដល់បំណិនសរសេររបស់សិស្សថែមទៀតផង (Harmer, 2002)។ ម្យ៉ាយវិញទៀត គោលបំណងសំខាន់នៃការអានជាភាសាអង់គ្លេស មិនថាជាភាសាទី២(ESL) ឬជាភាសាបរទេស (EFL)គឺការអានដើម្បីរៀនមិនមែនរៀនដើម្បីអាននោះទេ (PL Carrell, 1998)។

មួយវិញទៀត ការស្រាវជ្រាវរបស់លោក Li and Munby (1996)បានរកឃើញថា នៅក្នុងការអានសិស្សបានប្រើចំណេះដឹងមានស្រាប់របស់ខ្លួន, ការបកប្រែទៅជាភាសាទី១ (L1) ការចោទសួរទៅខ្លួនឯងការសង្ខេប និងការព្យាករណ៍។ ការស្រាវជ្រាវនេះក៏បានរកឃើញផងដែរថា សិស្សខ្លះបានប្រើពាក្យគន្លឹះ

ហើយខ្លះទៀតប្រើភាសាចិន (L1) ដើម្បីដោះស្រាយបញ្ហា នៅពេលដែលអានអត្ថបទពិបាកៗ។ លើសពីនេះទៅទៀត នៅពេលដែលអត្ថបទពិបាកក្នុងការគិតជាភាសាអង់គ្លេសសិស្សEFLទាំងអស់នេះបានប្រែមកគិតជាភាសារបស់ពួកគេ (L1) មួយរំពេច (Li, S.Y/ Munby, H, 1996)។

### ២.៣.២. លំនាំនៃការបង្រៀនសមត្ថភាពអានក្នុងភាសាទី១

ក្នុងភាសាខ្មែរ វិធីសាស្ត្របង្រៀនអំណានចែកជាបីដំណាក់កាលដូចជា ត្រៀមអំណាន អំណាន និងក្រោយអំណាន ហើយក្នុងសៀវភៅគោលសិស្សអំណានត្រូវបានចែកជាពីរ គឺអំណានសម្រាប់អត្ថបទអក្សរសិល្ប៍ និងអំណានទាក់ទងនឹងជីវភាពរស់នៅ។ មេរៀនអំណាននីមួយៗ មានទម្រង់ជា៖

- ចំណងជើងអំណាន
- រូបភាព៖ ជួយឱ្យយល់ខ្លឹមសារមេរៀន
- ចំណងជើងអត្ថបទ និងអត្ថបទ
- សំណួរត្រិះរិះ៖ ដើម្បីឱ្យសិស្សហាត់អនុវត្តបំណិន អក្សរសិល្ប៍ និងអំណាន។

នេះបើតាមការលើកឡើងក្នុងឯកសារបំប៉នសមត្ថភាពគ្រូនៅអនុវិទ្យាល័យឆ្នាំ២០១០របស់នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ។ ឯកសារដដែលក៏បានបង្ហាញផងដែរពីលំនាំនៃការបង្រៀនសមត្ថភាពអានផងដែរ (នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ, ២០១០)៖

- ❖ ត្រៀមអំណាន

១. បំផុសចំណេះដឹងសិស្សតាមរយៈសំណួរពីរូបភាព និងសំណួរពីចំណងជើង។

២. ឱ្យសិស្សស្វែងយល់ពាក្យពិបាកដោយប្រើទីសេចក្តី និងបទានុក្រមនៅផ្នែកខាងក្រោយនៃសៀវភៅ។

៣. រំឭកបញ្ញត្តិដែលមានទំនាក់ទំនង ឬប្រើក្នុងអំណាននេះ។

៤. ឱ្យសិស្សសាកល្បងទាយមើលថាតើអត្ថបទនេះនិយាយពីអ្វីខ្លះ ?

❖ អំណាន

១. ឱ្យសិស្សអានសំណួរត្រិះរិះ ដែលស្ថិតនៅខាងក្រោមអត្ថបទ។

២. ឱ្យសិស្សអានអត្ថបទដោយស្ងៀមស្ងាត់ (ឬឱ្យសិស្សអាននៅផ្ទះជាមុន )។

៣. ឱ្យសិស្ស ឆ្លើយនូវសំណួរត្រិះរិះ ដែលមាននៅក្នុងសៀវភៅសិស្ស។ បើសិស្សមិនអាចឆ្លើយសំណួរណាមួយលោកគ្រូ អ្នកគ្រូ ជ្រើសរើសផ្នែកដែលមានចម្លើយឱ្យសិស្សអានឡើងវិញម្ដងទៀត ឬគ្រូសួរសំណួរលម្អិតបន្ថែម។

❖ ក្រោយអំណាន

១. លោកគ្រូ អ្នកគ្រូ ជ្រើសរើសផ្នែកណាមួយឱ្យសិស្សអាន ដោយប្រើប្រាស់សំនៀងត្រឹមត្រូវ។

២. លោកគ្រូ អ្នកគ្រូ ជ្រើសរើសផ្នែកណាមួយនៃវគ្គសន្ទនាឱ្យសិស្សដើរតួ។

៣. ឱ្យសិស្សធ្វើការជាក្រុមដើម្បីគូររូបភាពផ្នែកណាមួយនៃអត្ថបទ តែងកាព្យ លើកពាក្យស្លោកទាក់ទងនឹងខ្លឹមសារអត្ថបទ សង្ខេបអត្ថបទអំណានទាំងមូល ឬស្វែងរកចម្រៀង និងអត្ថបទកំណាព្យដែលទាក់ទងនឹងប្រធានបទអំណានជាដើម។ល។

### ២.៣.៣. យុទ្ធសាស្ត្រការអានជាភាសាអង់គ្លេស

តើដូចម្ដេចដែលហៅថាយុទ្ធសាស្ត្រនៃការអានភាសាអង់គ្លេស? បើយោងតាមលោក Barnett បានឱ្យនិយមន័យថាជាដំណើរការក្នុងខួរក្បាលនៅពេលអ្នកអាន អានអត្ថបទហើយយល់ពីអ្វីដែលពួកគេកំពុងអាន (Barnett, 1988)។ យុទ្ធសាស្ត្រនៃការអាន គឺជាចំណាប់អារម្មណ៍ទៅលើអ្វីដែលអ្នកអានបានសម្ដែងចេញអំពីរបៀបដែលពួកគេមានទំនាក់ទំនងជាមួយនឹងអត្ថបទសំណេរ ព្រមទាំងការយល់ដឹងទៅលើអត្ថបទនោះ។ យុទ្ធសាស្ត្រទាំងនោះ ត្រូវបានប្រើប្រាស់សម្រាប់ជួយបង្កើនសមត្ថភាពអានរបស់សិស្ស (Carrell, P. L, Pharis, B. G, Liberto, J. C, 1989)។ ចំណែកលោក Nuttall បានសរសេរក្នុងសៀវភៅ

ដែលមានចំណងជើងថា Teaching Reading Skills in a foreign Language ក្នុងឆ្នាំ១៩៩៦ ក៏បានលើកឡើងដែរថាយុទ្ធសាស្ត្រអាននេះ រួមបញ្ចូលពីរបៀបដែលអ្នកអានយល់លើកិច្ចការ យល់អំពីអ្វីដែលពួកគេអាន និងអ្វីដែលពួកគេនឹងធ្វើពេលដែលពួកគេមិនយល់ (Nuttall, 1996)។

ទោះជាយ៉ាងណា នៅក្នុងឯកសារស្តីពីការបង្រៀនអានភាសាខ្មែរពុំឃើញមានបង្ហាញពីភាពដោយឡែកៗនៃយុទ្ធសាស្ត្របំណិនអាននោះទេ តែចំណែកក្នុងភាសាអង់គ្លេសវិញ តើមានវិធីសាស្ត្រអានភាសាអង់គ្លេសអ្វីខ្លះដែលត្រូវយកមកបង្រៀនឱ្យសិស្សចេះ?

បើតាមលោក Françoise Grellet ឆ្នាំ២០០២ បានលើកឡើងថា វិធីសាស្ត្រ Skimming និង Scanning គឺជាវិធីសាស្ត្រចាំបាច់សម្រាប់សិស្សក្នុងការអានបានរហ័ស និងមានប្រសិទ្ធភាពព្រោះថាចំពោះ Scanning អ្នកអានមិនចាំបាច់មើលអត្ថបទទាំងស្រុងនោះទេ គឺយើងគ្រាន់តែរកមើលព័ត៌មានជាក់លាក់ណាមួយដែលយើងចង់ដឹងដូចជា ឈ្មោះ ឬកាលបរិច្ឆេទជាដើម។ រីឯ Skimming អ្នកអានគ្រាន់តែមើលអត្ថបទទាំងមូលយ៉ាងឆាប់រហ័សដើម្បីសរុបយកខ្លឹមសារសំខាន់នៃអត្ថបទ រចនាបថ ឬគោលគំនិត និងចេតនារបស់អ្នកសរសេរ (Françoise Grellet, 2002)។

ចំណែក លោកJeremy បានបង្ហាញបន្ថែមនូវវិធីសាស្ត្រ១ទៀតក្រៅពី Skimming និង Scanning គឺ Reading for Detailed Comprehension។ Reading for Detailed Comprehension មិនដូចវិធីសាស្ត្រ Skimming និងScanning ត្រង់ថា នៅពេលសិស្សអានអត្ថបទដើម្បីស្វែងរកព័ត៌មានលម្អិត គ្រូរំពឹងថាសិស្សនឹងយកចិត្តទុកដាក់ ផ្តោតអារម្មណ៍លើចំណុចសំខាន់តូចៗក្នុងអត្ថបទដែលពួកគេកំពុងអាន (Harmer, 2002)។

មួយវិញទៀត បើតាមវគ្គបណ្តុះបណ្តាលរបស់កម្មវិធីសហប្រតិបត្តិការសឹង្ហបុរី ស្តីពីការបង្រៀនភាសាអង់គ្លេសជាភាសាទី២ កម្មវិធីសិក្សា និងគរុកោសល្យឆ្នាំ២០១៧ បានបង្ហាញថា យុទ្ធសាស្ត្រនៃការអានជាភាសាអង់គ្លេសមាន៦ (Singapore Cooperation Programme, 2017)គឺ៖

- Scanning ៖ អំណានរហ័សសម្រាប់ស្វែងរកព័ត៌មានជាក់លាក់ណាមួយដូចជា កាលបរិច្ឆេទ លេខទូរស័ព្ទ តួលេខ ឬឆ្នាំជាដើម។
- Skimming ៖ អំណានរហ័សសម្រាប់ស្វែងរកគោលគំនិតសំខាន់ ដែលភាគច្រើនមាននៅក្នុងសេចក្តីផ្តើម ឬសេចក្តីសរុបបញ្ចប់។
- Reading to confirm Information ៖ ការអានដើម្បីស្វែងរកព័ត៌មានមកអះអាងបញ្ជាក់។
- Reading for Main idea ៖ ការអានយ៉ាងលម្អិតដើម្បីឱ្យយល់ពីគំនិតសំខាន់នៃអត្ថបទទាំងមូល។
- Reading for Specific Information ៖ ការអានយ៉ាងល្អិតល្អន់ដើម្បីពិនិត្យមើលអត្ថន័យជាក់លាក់របស់អត្ថបទទាំងមូល។
- Reading for Detailed Comprehension ៖ ការអានលម្អិតដើម្បីធ្វើការវិនិច្ឆ័យលើការយល់ដឹងទៅលើអត្ថបទទាំងមូល។

រីឯលោកWilliam Grape ក្នុងឆ្នាំ២០០៩ ក៏បានគូសបញ្ជាក់ក្នុងសៀវភៅរបស់លោកផងដែរទាក់ទងទៅនឹងយុទ្ធសាស្ត្រការអានជាភាសាអង់គ្លេសទាំង៦ (6 Reading Sub -skills) ដោយលោកបានលើកឡើងថាអ្នកអានទាំងអស់ មានគោលបំណងខុសៗគ្នាក្នុងការអាន។ ហេតុដូចនេះ របៀបដែលអ្នកអានប្រើក្នុងការអានក៏ខុសគ្នាដែរដូចជា ការរៀនអានរហ័សដើម្បីប៉ាន់ស្មានបានត្រឹមត្រូវតាមសំណួរដែលសួរ ការអានដើម្បីទទួលព័ត៌មាន និងគំនិតសំខាន់នៃអត្ថបទមួយ (Reading for Main idea and Reading for Specific Information) និងការអានហើយសរុបព័ត៌មានផ្សេងៗដាក់បញ្ចូលគ្នា។ ការអានក្នុងគោលបំណងខុសគ្នាត្រូវតែប្រើរបៀបអានខុសៗគ្នាដូចជា បើយើងអានដើម្បីរៀនយើងអាចនឹងអានលម្អិតដើម្បីធ្វើការវិនិច្ឆ័យលើការយល់ដឹងទៅលើអត្ថបទទាំងមូល (Reading for Detailed Comprehension) ឬយើងអានរហ័ស (Scanning and Skimming)សម្រាប់ទទួលបានព័ត៌មានឆាប់រហ័ស (William Grabe, 2009)។

មួយវិញទៀត បើតាមលោក Brown និង Baker ឆ្នាំ ១៩៨៣ បានបញ្ជាក់ក្នុងសៀវភៅរបស់គាត់ថា ចាប់តាំងពីដើមទសវត្សរ៍ឆ្នាំ១៩៧០ មកការស្រាវជ្រាវមួយចំនួននៅក្នុងវិស័យអានបានផ្តោតទៅលើយុទ្ធសាស្ត្រដែលជួយសម្រួលដល់ការអាន ហើយការប្រើប្រាស់យុទ្ធសាស្ត្រផ្សេងៗត្រូវបានគេរកឃើញថាមានប្រសិទ្ធភាពក្នុងការកែលម្អការចេះអានរបស់សិស្សថែមទៀត (Brown and Baker, 1983)។

ក្រៅពីយុទ្ធសាស្ត្រក្នុងការអានដែលប្រើប្រាស់ដោយអ្នកអាន ចំណេះដឹងមានស្រាប់របស់ពួកគេ ការលើកទឹកចិត្ត ឥរិយាបថ អាយុ និងភេទក៏មានឥទ្ធិពលក្នុងការអានរបស់សិស្សផងដែរ ដោយលោក Keshavarz. និងលោក Ashtarian ឆ្នាំ ២០០៨ បានលើកឡើងដែរថាសិស្សស្រីមានសមត្ថភាពក្នុងការអាន ឬការយល់ដឹងពីអត្ថបទអំណានខ្ពស់ជាងសិស្សប្រុស (Keshavarz. and Ashtarian, 2008)។

ម៉្យាងទៀត លោក Jill Hadfiekd និង លោក Charles Hadfield ក៏បានពន្យល់ផងដែរថា អ្នកអានដែលពូកែគឺជាអ្នកអានដែលមានយុទ្ធសាស្ត្រច្រើនបំផុត។ ពួកគេប្រើយុទ្ធសាស្ត្រអានខុសៗគ្នាអាស្រ័យទៅលើប្រភេទអត្ថបទដែលពួកគេកំពុងអាន និងមូលហេតុនៃការអានរបស់ពួកគេ។ បន្ទាប់មកពួកគេទទួលបានអត្ថន័យពីក្នុងអត្ថបទដោយយុទ្ធសាស្ត្រយល់ដឹងទាំងនោះ ស្ថិតនៅក្រោមការត្រួតពិនិត្យរបស់អ្នកអានដែលធ្វើការសម្រេចចិត្តទៅលើយុទ្ធសាស្ត្រអ្វីដែលត្រូវប្រើប្រាស់ និងពេលណាដែលត្រូវប្រើវា។ ម៉្យាងទៀត អ្នកអានត្រូវការជំនាញអានផ្សេងៗដើម្បីជួយឱ្យការអានរបស់ពួយគេទទួលបានជោគជ័យ ព្រមទាំងប្រើចំណេះដឹងមានស្រាប់របស់ពួកគេទៅលើអត្ថបទដើម្បីប៉ាន់ស្មានពីអត្ថន័យនៅក្នុងអត្ថបទ។ ផ្ទុយទៅវិញ អ្នកដែលមិនពូកែអាន ច្រើនតែមិនសូវមានចំណេះដឹងមានស្រាប់ទាក់ទងនឹងប្រធានបទ ឬរចនាបថនៃអត្ថបទឱ្យបានគ្រប់គ្រាន់ ជាហេតុធ្វើឱ្យពួកគេមិនងាយយល់ពីអត្ថបទនៅពេលពួកគេអាន (Jill Hardfiekd and Charles Hadfield, 2008)។

## ២.៤. គោលការណ៍ក្នុងការបង្រៀនអំណានភាសាអង់គ្លេស

បើតាមលោក Jeremy Harmer ឆ្នាំ ២០០២ បានឱ្យដឹងថា ក្នុងការបង្រៀនអំណានគ្រូបង្រៀនគប្បីចងចាំនូវគោលការណ៍ចំនួន ៦ចំណុច (Harmer, 2002)។ គោលការណ៍ទាំងនោះមានដូចខាងក្រោម ៖

- ❖ គោលការណ៍ទី១ ៖ អំណានមិនមែនជាបំណិនអកម្មនោះទេ។ អ្នកអានត្រូវរៀនឱ្យយល់ពីអត្ថន័យនៃពាក្យ ខ្លឹមសារ រូបភាព និងរចនាបថនៃទម្រង់ដែលអ្នកនិពន្ធសរសេរ ដើម្បីជំនួយដល់ការយល់ខ្លឹមសារ និងការចងចាំអត្ថន័យរបស់អត្ថបទបានយូរ។

- ❖ គោលការណ៍ទី២ ៖ សិស្សត្រូវតែមានការយល់ដឹងលើអ្វីដែលគេកំពុងអាន។ បើពួកគេមិនមានការយល់ដឹងសោះលើអត្ថបទអំណាននោះ សិស្សនឹងមិនចាប់អារម្មណ៍ពីអ្វីដែលគេអាន ហើយបើទោះជាគេបន្តការអានក៏មិនបានទទួលផលប្រសើរឡើយ។

- ❖ គោលការណ៍ទី៣ ៖ សិស្សគួរតែលើកទឹកចិត្តឱ្យផ្តោតអារម្មណ៍លើបរិបទនៃអត្ថបទ ជាជាងគ្រាន់តែរៀនភាសា។ ការសិក្សាអំណានក្រៅពីជួយសិស្សពីរបៀបប្រើប្រាស់ភាសា វាក៏ជួយផ្តល់ជាសារឱ្យសិស្សចេះគិត ចេះសម្តែងអារម្មណ៍ទាក់ទងនឹងប្រធានបទ និងជួយកែប្រែដល់ឥរិយាបថផ្ទាល់ខ្លួនទៀតផង។

- ❖ គោលការណ៍ទី៤ ៖ ការប៉ាន់ស្មានទុកមុនជាកត្តាចំបងក្នុងការអាន។ សិស្សអាចធ្វើការស្មានពីខ្លឹមសារនៃអត្ថបទតាមរយៈគម្របសៀវភៅ រូបភាព និងចំណងជើងមុនពេលអានអត្ថបទដើម្បីឱ្យខួរក្បាលចាប់ផ្តើមដំណើរការគិតពីអ្វីដែលអាចមានក្នុងអត្ថបទ។ ការធ្វើបែបនេះ សិស្សនឹងអានបានប្រសើរហើយឆាប់យល់។

❖ គោលការណ៍ទី៥ ៖ លំហាត់ ឬកិច្ចការដែលសិស្សត្រូវធ្វើ ត្រូវតែសមស្របនឹងប្រធានបទ។ គ្រូគប្បីរើសការងារដែលសិស្សត្រូវធ្វើមុន និងក្រោយពីអានឱ្យបានល្អដើម្បីជួយសិស្សឱ្យឆាប់យល់ និងចាប់អារម្មណ៍ក្នុងការអាន។

❖ គោលការណ៍ទី៦ ៖ អត្ថបទអំណានត្រូវតែជាអត្ថបទពេញលេញ ជៀសវាងបាត់អត្ថន័យ ឬគំនិតក្នុងអត្ថបទ។ អត្ថបទគួរតែមានភាពទាក់ទងគ្នាងាយស្រួលឱ្យសិស្សធ្វើការពិភាក្សា ធ្វើកិច្ចការមេរៀនបន្ទាប់ និងឈានដល់ការប្រើប្រាស់ភាសាថែមទៀត។

## ២.៥. គម្រូនៃអំណាន

អំណាន គឺកើតឡើងនៅពេលមនុស្សម្នាក់សម្លឹងមើលទៅអត្ថបទមួយ ហើយធ្វើការផ្តល់ន័យដល់និមិត្តសញ្ញាដែលបានសរសេរនៅក្នុងអត្ថបទនោះ។ វាគឺជាអន្តរអំពើរវាងអត្ថបទ និងអ្នកអានដើម្បីបង្កើតអត្ថន័យ។ ហេតុនេះ គម្រូនៃអំណានត្រូវបានបង្កើតឡើងដើម្បីពិពណ៌នាពីអន្តរកម្មនេះរវាងអ្នកអានជាមួយនឹងអត្ថបទ ព្រមទាំងអ្វីដែលបានកើតឡើងអំឡុងពេលកំពុងអាន (Jo Ann Aebersold and Mary Lee Field, 1997)។

ខាងក្រោមនេះ គឺជាគម្រូនៃអំណានក្នុងការអានជាភាសាបរទេស ឬជាភាសាទីពីរចំនួន៣ ត្រូវបានលើកយកមកបង្ហាញ។

ក្រាប២.១៖ គម្រូទាំងបីរបស់អំណានប្រភព (Dechant, 1991)



**២.៥.១. គម្រូតាមបែប** Top-down (Top-down Model) ៖ មានន័យថា អ្នកអានពាំនាំនូវចំណេះដឹងមានស្រាប់ និងបទពិសោធន៍ដែលពួកគេធ្លាប់មានចូលមកក្នុងអត្ថបទ ហើយពួកគេនឹងបន្តអានរហូតទាល់តែការរំពឹងទុករបស់ពួកគេត្រូវបានរកឃើញពីក្នុងអត្ថបទ។ ដំណើរការនៃគម្រូប្រភេទនេះ មានដូចខាងក្រោម៖

- ❖ មុនដំបូង អ្នកអានមើលទៅអត្ថបទអំណាន ឬកថាខណ្ឌណាមួយ។
- ❖ បន្ទាប់មក ពួកគាត់អានចំណងជើងអត្ថបទ ចំណងជើងរង រួចទាយប៉ាន់ស្មាន តើអត្ថបទចង់និយាយពីអ្វីដោយផ្អែកលើបទពិសោធន៍ និងចំណេះដឹងមានស្រាប់ដែលគាត់មានទាក់ទងនឹងប្រធានបទ។
- ❖ អ្នកអាន អានអត្ថបទបន្តដើម្បីស្វែងរកការបញ្ជាក់ដែលទាក់ទងនឹងប្រធានបទ។ ដូច្នេះអ្នកអានរួមបញ្ចូលអត្ថបទទៅក្នុងចំណេះដឹងដែលពួកគេមានរួចហើយ (Tomas S. C. Farrell, 2002)។

**២.៥.២. គម្រូតាមបែប** Bottom-Up (Bottom-Up Model)៖ មានន័យថាអ្នកអានពិនិត្យមើលពាក្យ ឃ្លាប្រយោគ និងទម្រង់របស់អត្ថបទដើម្បីឱ្យយល់ន័យសេចក្ដីដែលបានសរសេរក្នុងអត្ថបទ។ ដោយមិនទាក់ទងទៅនឹងបទពិសោធន៍ និងចំណេះដឹងមានស្រាប់ អ្នកអានស្វែងយល់ពីអត្ថន័យខ្លឹមសារតាមរយៈវាក្យស័ព្ទ និងសំណង់ប្រយោគ។ គម្រូអានតាមបែប Bottom-Up គឺត្រូវពឹងផ្អែកលើពាក្យប្រយោគ វេយ្យាករណ៍ និងអត្ថបទជាមូលដ្ឋានដែលជួយឱ្យអ្នកអានបានយល់ និងចងចាំ។ ជំនួសឱ្យការយល់ពីអត្ថបទជាមុន គម្រូតាមបែប Bottom-Up គឺតម្រូវឱ្យអានផ្ដើមចេញពីការយល់លើអត្ថបទ មុននឹងយល់ពីអត្ថន័យ (Tomas S. C. Farrell, 2002)។

**២.៥.៣. គម្រូតាមបែប** Interactive (Interactive Model)៖ គឺនៅពេលដែលអ្នកពូកែអានម្នាក់ អានដោយប្រើការរួមបញ្ចូលគ្នារវាងគម្រូតាមបែប Top-down និងគម្រូតាមបែប Bottom-Up។ អ្នកអានស្ទាត់ ភាគច្រើនចាប់ផ្ដើមអានដោយការប៉ាន់ស្មានទៅលើខ្លឹមសារអត្ថបទ ថាតើប្រធានបទនោះគួរឱ្យ

ចាប់អារម្មណ៍ និងគួរអានបន្តទៀតឬទេ។ បន្ទាប់មក ពួកគេពិនិត្យមើលលើពាក្យមួយចំនួនដែលពាក់ព័ន្ធនឹងប្រធានបទ ហើយមើលរំលងពាក្យដែលមិនចាំបាច់ ឬពាក្យពិបាក ប៉ុន្តែនៅពេលដែលអ្នកអានរកឃើញថាខ្លួនបានប៉ាន់ស្មានខុសហើយការយល់ដឹងលើអត្ថបទរបស់ខ្លួនមិនត្រឹមត្រូវ អ្នកអានត្រូវចាប់ផ្ដើមគ្រោងការសន្មតហើយបន្តនូវវដ្តដូចរៀបរាប់ពីខាងលើឡើងវិញ (Tomas S. C. Farrell, 2002)។

ក្រាប២.២៖ គម្រូអំណានតាមបែប Interactive Model ប្រភព (Rosie Amstutz, 2012)




ការអានគម្រូតាមបែប Interactiveគឺជា អន្តរកម្មរវាងគម្រូតាមបែប Bottom-Up និងគម្រូតាមបែប Top-down។

## ២.៦. តួនាទី របស់ Metacognition នៅក្នុងការយល់ដឹងលើការអាន

Metacognitionមានន័យថា ការទទួលដឹង និងការយល់អំពីដំណើរការគិតរបស់ខ្លួនឯង ហើយវារួមបញ្ចូលគ្នានូវដំណើរការគិត និងដំណើរការផ្ដល់ព័ត៌មានត្រឡប់។ Metacognitionដើរតួយ៉ាងសំខាន់ក្នុងការយល់ដឹងលើការអាន ដោយលោក Anderson ក្នុងឆ្នាំ១៩៩៤ បានធ្វើការសង្ខេបសមាសភាគចម្បងរបស់ Metacognition ចំនួន៥ (Anderson R. C, 1994)ដូចតទៅ ៖

### ២.៦.១. ការរៀបចំ និងធ្វើផែនការសម្រាប់ការសិក្សា

ក្នុងដំណាក់កាលមុនការអាន Metacognition ត្រូវបានប្រើដើម្បីឆ្លុះបញ្ចាំងយ៉ាងសកម្មលើការប្រើប្រាស់ចំណេះដឹងមានស្រាប់ជាមូលដ្ឋានសម្រាប់បង្កើតការប៉ាន់ស្មានអំពីអ្វីដែលត្រូវអាន។ ក្នុងនោះផងដែរ Metacognition ជួយដល់សកម្មភាពការគិត អំពីគោលបំណងនៃការអាន និងជួយជ្រើសរើសយុទ្ធសាស្ត្រអានដែលមានប្រសិទ្ធភាព។

### ២.៦.២. ការជ្រើសរើស និងប្រើប្រាស់យុទ្ធសាស្ត្រនៃការរៀន

ក្នុងអំឡុងពេលអាន Metacognition ជួយសិស្សឱ្យត្រួតពិនិត្យការយល់ដឹងលើការអាន និងជួយចងក្រងគំនិត រូបភាព ឬព័ត៌មានសំខាន់ៗ។ មិនតែប៉ុណ្ណោះ វាក៏ជួយសិស្សក្នុងការបង្កើតសំណួរ ការព្យាករណ៍ទុកមុន ព្រមទាំងការវាយតម្លៃអាកប្បកិរិយាផ្ទាល់ខ្លួនទៅលើការងារដែលជាហេតុនាំឱ្យការយល់ដឹងកាន់តែកើនឡើងថែមទៀត។

### ២.៦.៣. ការប្រើប្រាស់យុទ្ធសាស្ត្រតាមដាន

នៅក្នុងដំណាក់កាលក្រោយអំណាន Metacognition ជំរុញការផ្តល់ព័ត៌មានត្រឡប់លើអំណាន និងជួយប្រមូលគោលគំនិតសំខាន់ៗ និងព័ត៌មានលម្អិតដើម្បីសង្ខេបអត្ថបទ។ យុទ្ធសាស្ត្រមួយចំនួននឹងត្រូវបានជ្រើសរើសយកមកប្រើយ៉ាងសមស្រប ប្រសិនបើការផ្តល់ព័ត៌មានត្រឡប់ពីភាពខ្វះចន្លោះក្នុងការយល់ដឹងបានត្រឹមត្រូវ។

### ២.៦.៤. រៀបចំយុទ្ធសាស្ត្រផ្សេងៗ

នៅពេលសិស្សជួបប្រទះការលំបាកក្នុងពេលកំពុងអានសៀវភៅ ពួកគេត្រូវការការសម្របសម្រួលការរៀបចំ និងជ្រើសរើសយុទ្ធសាស្ត្រផ្សេងៗមកប្រើ ដើម្បីជៀសវាងការយល់ដឹងលើការអានត្រូវបំផ្លាញ។

### ២.៦.៥. ការវាយតម្លៃលើការប្រើប្រាស់យុទ្ធសាស្ត្រ និងការរៀន

អ្នកអានគួរតែត្រូវបានលើកទឹកចិត្តឱ្យចេះគិត និងវាយតម្លៃថាតើយុទ្ធសាស្ត្រលើការអានមួយណាដែលមាន ឬគ្មានប្រសិទ្ធភាព។ Metacognition អាចជួយអ្នកអានឱ្យមានការអភិវឌ្ឍក្នុងការអាន ដោយផ្អែកលើការយល់ដឹងផ្ទាល់ខ្លួន ក៏ដូចជាជួយកសាងទំនុកចិត្ត និងមានភាពឈ្លាសវៃក្នុងការដោះស្រាយបញ្ហាផងដែរ។ ជាងនេះទៅទៀត Metacognition ដើរតួនាទីយ៉ាងសំខាន់ក្នុងការអានប្រកបដោយប្រសិទ្ធភាពខ្ពស់ ដោយសារវាជួយអ្នកអានក្នុងការធ្វើផែនការសម្រាប់ការរៀន ជួយរើសយុទ្ធសាស្ត្រអានឱ្យបានសមស្រប និងយុទ្ធសាស្ត្រពេលជួបការលំបាកនៅពេលអាន។

## ២.៧. ស្តង់ដារអំណាន

តាមរយៈ ឯកសារជំនួយគ្រូឧទ្ទេសសម្រាប់បណ្ដុះបណ្ដាលគរុសិស្ស និងគ្រូស្ដីពី «ស្តង់ដាអំណានថ្នាក់ទី១ ទី២ និងទី៣» បានបញ្ជាក់ឱ្យដឹងថា ស្តង់ដាអំណានថ្នាក់ទី១ ទី២ និងទី៣នេះត្រូវបានរៀបចំជាដំណាក់កាល ហើយដំណាក់កាលនីមួយៗត្រូវបានរៀបចំទៅតាមបណ្ដុំមេរៀនតិច ឬច្រើនអាស្រ័យលើប្រធានបទនៃខ្លឹមសារមេរៀនដែលមានក្នុងសៀវភៅភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី១ ទី២ និងទី៣។ ជាងនេះទៅទៀត មធ្យោបាយដ៏សំខាន់ដើម្បីបង្រៀនកុមារឱ្យសម្រេចគោលដៅនៃការអានជាសកល គឺការអនុវត្តបំណិនអំណានគន្លឹះទាំង៥ រួមមាន ការស្គាល់សូរ ការស្គាល់តួអក្សរ ការចេះវាក្យសព្ទ ការចេះអានស្ទាត់ និងការអានដើម្បីយល់ន័យ (នាយកដ្ឋានបណ្ដុះបណ្ដាល និង វិក្រឹតការ, ២០១៦)។ ម៉្យាងទៀត នៅក្នុងសៀវភៅស្តង់ដាអំណានថ្នាក់ទី៣ ដែលសហការបង្កើតដោយក្រសួងអប់រំ យុវជន និងកីឡា ជាមួយអង្គការអប់រំពិភពលោក(WE) ព្រមទាំងអង្គការសកម្មភាពសម្រាប់បឋមសិក្សានៅកម្ពុជា (KAPE) និងអ្នកពាក់ព័ន្ធជាច្រើនទៀតក៏បានទទួលស្គាល់ដែរថា លទ្ធផលអំណាន និងសំណេរនៅមានកម្រិតទាបនៅឡើយ។ ហេតុនេះហើយ ស្តង់ដាអំណានត្រូវបានបង្កើតឡើងដើម្បីផ្ដល់ឱ្យគ្រូនូវឯកសារច្បាស់លាស់អំពីសមត្ថភាពជាក់លាក់ក្នុងការអាន និងការសរសេរដែលសិស្សត្រូវទទួលបានពីមេរៀននីមួយៗក្នុងសៀវភៅសិក្សាគោល ព្រមទាំងជួយឱ្យគ្រូកាន់តែមានភាពប្រសើរឡើងក្នុងការរៀបចំការវាយតម្លៃសមត្ថភាពសិស្សតូចៗដែលទើបនឹងចាប់ផ្ដើមរៀនអាន និងរៀនសរសេរនៅក្នុងថ្នាក់ដំបូង និងផ្ដល់ព័ត៌មានត្រឡប់កាន់តែប្រសើរអំពីរបៀបដោះស្រាយបញ្ហាសិក្សាផ្សេងៗ ព្រមទាំងអាចតាមដានហើយជួយសិស្សដែលមិនទាន់យល់មេរៀនច្បាស់បានទាន់ពេលវេលា ដើម្បីឱ្យសិស្សអាចឈានដល់កម្រិតស្តង់ដាជាក់លាក់មួយ (ក្រសួងអប់រំ យុវជន និង កីឡា, ២០១៤)។ ជាឧទាហរណ៍ ស្តង់ដាការអានសម្រាប់សិស្សថ្នាក់ទី១គឺត្រូវចេះអានពាក្យ អានឮតួអក្សរនៃអក្ខរក្រម ឬអាចយល់បានពីប្រភេទអត្ថបទដែលងាយៗ និងសម្រាប់ថ្នាក់ទី៣ សិស្សអាចប្រាប់ពីសេចក្ដីលំអិតសំខាន់ៗនៃអត្ថបទ តាមព័ត៌មានបង្ហាញត្រង់ (ក្រសួងអប់រំ យុវជន និង កីឡា, ២០១៦)។ ដោយឡែកបើពិនិត្យមើលកម្មវិធីសិក្សាលម្អិតភាសាខ្មែរសម្រាប់កម្រិតមធ្យមសិក្សាបឋមភូមិ

លើសមត្ថភាពអានបានបង្ហាញថា សិស្សត្រូវចេះអានលើកដាក់សំឡេង និងគោរពតាមសញ្ញាផ្សេងៗបានត្រឹមត្រូវ អានឱ្យបានស្ទាត់ដើម្បីរកព័ត៌មានផ្សេងៗ (ក្រសួងអប់រំ យុវជន និង កីឡា, ២០១៨)។ ក្រៅពីនេះ នៅក្នុងកម្មវិធីសិក្សាលម្អិតមុខវិជ្ជាអក្សរសាស្ត្រខ្មែរ សម្រាប់កម្រិតមធ្យមសិក្សាទុតិយភូមិ ផ្នែកសមត្ថភាពអានក៏បានបញ្ជាក់ផងដែរថា សិស្សមានសមត្ថភាពបង្ហាញឥរិយាបថវិជ្ជមានក្នុងការអានប្រកបដោយប្រសិទ្ធភាព យល់ដឹងពីរបៀបអានដើម្បីកំណត់ពីខ្លឹមសារ និងរបៀបស្វែងរកព័ត៌មាន (ក្រសួងអប់រំ យុវជន និង កីឡា, ២០១៨)។ ម្យ៉ាងវិញទៀត បើពិនិត្យមើលក្នុងសៀវភៅកម្មវិធីសិក្សាលម្អិតមុខវិជ្ជាភាសាអង់គ្លេស សម្រាប់មធ្យមសិក្សាទុតិយភូមិឆ្នាំ២០១៨ ក៏បានលើកឡើងពីលទ្ធផលសិក្សាដែលត្រូវសម្រេចឱ្យបានចំពោះបំណិនអាន ដោយតម្រូវឱ្យសិស្សចេះប្រមូល និងចាត់ថ្នាក់ព័ត៌មាន វិភាគ ព្យាករណ៍ និងសន្និដ្ឋានពីព្រឹត្តិការណ៍ក្នុងអត្ថបទអំណាន កាសែត ឬទស្សនាវដ្ដី បញ្ហាទាក់ទងនឹងជីវភាពប្រចាំថ្ងៃក្នុងប្រទេស និងក្នុងពិភពលោក (ក្រសួងអប់រំ យុវជន និង កីឡា, ២០១៨)។

នៅក្នុងលទ្ធផលតេស្តវង្វាយតម្លៃថ្នាក់ជាតិថ្នាក់ទី ១១ បានបង្ហាញថាសិស្សថ្នាក់ទី១១ នៅប្រទេសកម្ពុជាសម្រេចលទ្ធផលលើផ្នែកអំណានបាន ៥៧.៦% ដោយធ្វើបានល្អទៅលើលទ្ធផលសិក្សាខ្លះដូចជាការរកប្រភពអត្ថបទ ការកំណត់ឈ្មោះអ្នកនិពន្ធ និងកាលបរិច្ឆេទនៃការតែងអត្ថបទ។ (Ministry of Education, 2019)

ក្រាប២.៣៖ លទ្ធផលនៃការអានរបស់សិស្សថ្នាក់ទី ១១ តាមមុខវិជ្ជារង




ប្រភព ( Ministry of Education, 2019 )

ក្រាប២.៤៖ លទ្ធផលនៃការអានតាមលទ្ធផលសិក្សា




ប្រភព ( Ministry of Education, 2019 )

ចំណែកឯបរិបទពិភពលោកវិញ តាមរយៈកម្មវិធីសម្រាប់ការវាយតម្លៃនិស្សិតជាអន្តរជាតិ(PISA) ដែលជាការវាយតម្លៃជាអន្តរជាតិអំពីជំនាញ និងចំណេះដឹងចំពោះក្មេងអាយុ១៥ឆ្នាំដោយសង្កត់ធ្ងន់លើសមត្ថភាពរបស់សិស្សក្នុងការអនុវត្តចំណេះដឹង និងជំនាញរបស់ខ្លួនក្នុងជីវិតជាក់ស្តែងលើសមត្ថភាពក្នុងការវិភាគ ផ្តល់ទទ្បីករណ៍ និងប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពដោយពួកគេកំណត់ បកស្រាយ និងដោះស្រាយបញ្ហាក្នុងស្ថានភាពផ្សេងៗ ក្នុងនោះអក្ខរកម្មអំណានសំដៅលើសមត្ថភាពយល់ ប្រើប្រាស់ ពិចារណាលើអត្ថបទសរសេរដើម្បីសម្រេចបានគោលដៅអភិវឌ្ឍចំណេះដឹង និងសក្តានុពលរបស់ខ្លួន ព្រមទាំងដើម្បីចូលរួមក្នុងសង្គម ហើយជំនាញក្នុងការអានដែល PISA ត្រូវវាស់វែងមានវិសាលភាពធំទូលាយជាងសមត្ថភាពអានជាមូលដ្ឋាន។ សមត្ថភាពអាននេះ រួមបញ្ចូលទាំងសមត្ថភាពក្នុងការយល់និងប្រើប្រាស់ព័ត៌មានក្នុងអត្ថបទមួយទៅតាមស្ថានភាព និងគោលបំណងផ្សេងគ្នា។ ជំនាញអានដែលវាស់វែងដោយ PISA ត្រូវបានកំណត់តាមលំដាប់លំដោយជា ៦កម្រិតដោយកម្រិតទី៦ ជាកម្រិតខ្ពស់បំផុត និងកម្រិតទី ១ ជាកម្រិតទាបបំផុត។ កម្រិត ២ គឺជាកម្រិតមូលដ្ឋាននៃសមត្ថភាពរបស់សិស្ស ដែលសិស្សអាចបង្ហាញពីសមត្ថភាពចូលរួមយ៉ាងមានប្រសិទ្ធភាព និងប្រកបដោយផលិតភាពក្នុងជីវិតជាសិស្សដែលអាចរៀនបន្ត ជាពលករ និងជាពលរដ្ឋ (ក្រសួងអប់រំ យុវជន និងកីឡា, ២០១៨)។

ក្រាប២.៥៖ កម្រិតសមត្ថភាពទាំង ៦ នៃវង្វាយតម្លៃ PISA-D




| កម្រិត | ពិន្ទុអំណាន | ពិន្ទុគណិតវិទ្យា | ពិន្ទុវិទ្យាសាស្ត្រ |
|---|---|---|---|
| 1c<br>1b<br>1a | 189<br>262<br>335 | 236<br>295<br>358 | 186<br>260<br>335 |
| 2 | 407 | 420 | 410 |
| 3 | 480 | 482 | 484 |
| 4 | 553 | 545 | 559 |
| 5 | 626 | 607 | 633 |
| 6 | 698 | 669 | 708 |

ប្រភព (ក្រសួងអប់រំ យុវជន និងកីឡា, ២០១៨)

នៅកម្ពុជា សិស្សទទួលបានពិន្ទុផ្នែកអំណានទាបជាងកម្រិតទី២ របស់ PISA-D ព្រមទាំងទាបជាងពិន្ទុរបស់សិស្សមកពីប្រទេសជាសមាជិក PISA-D ជាមធ្យម។

ក្រាប២.៦៖ លទ្ធផលតេស្ត PISA-D ផ្នែកអំណាន របស់សិស្ស ប្រទេសកម្ពុជា




ប្រភព (ក្រសួងអប់រំ យុវជន និងកីឡា, ២០១៨)

នៅកម្ពុជា សិស្សប្រហែល ៨% ទទួលបានសមត្ថភាពកម្រិតមូលដ្ឋានលើផ្នែកអំណាន។

ក្រាប២.៧៖ សមត្ថភាពផ្នែកអំណានរបស់សិស្សកម្ពុជាធៀបនឹងសមត្ថភាពកម្រិតមូលដ្ឋាន PISA-D




ប្រភព (ក្រសួងអប់រំ យុវជន និងកីឡា, ២០១៨)

# ជំពូកទី ៣

# វិធីសាស្ត្រស្រាវជ្រាវ

# ជំពូកទី៣

# វិធីសាស្ត្រស្រាវជ្រាវ

## ៣.១. គម្រោងវិភាគ

ដើម្បីឆ្លើយតបទៅនឹងវត្ថុបំណងនៃការសិក្សាស្រាវជ្រាវ និងសំណួរស្រាវជ្រាវខាងលើ អ្នកសិក្សាបានជ្រើសរើសយកវិធីសាស្ត្រនៃការស្រាវជ្រាវតាមបែបចម្រុះ (Mixed-Methods) ដែលមានវិធីសាស្ត្របែបបរិមាណវិស័យ និងវិធីសាស្ត្របែបគុណវិស័យរួមបញ្ចូលគ្នាព្រោះវិធីសាស្ត្រចម្រុះ ជាវិធីសាស្ត្រដែលអ្នកសិក្សាស្រាវជ្រាវប្រើដើម្បីប្រមូល និងវិភាគទិន្នន័យបានច្បាស់លាស់ និងស៊ីជម្រៅជាងការប្រើប្រាស់វិធីសាស្ត្រតែមួយបែប។ នៅក្នុងការសិក្សាស្រាវជ្រាវតាមវិធីសាស្ត្របែបបរិមាណវិស័យ អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់កម្រងសំណួរបែបជាទម្រង់បិទ ដើម្បីអនុញ្ញាតឱ្យអ្នកចូលរួមឆ្លើយមានចម្លើយជ្រើសរើសហើយងាយស្រួលបំពេញ ព្រមទាំងប្រើប្រាស់ពេលវេលាតិចសម្រាប់បំពេញ។ មួយវិញទៀត ការស្រាវជ្រាវតាមបែបបរិមាណវិស័យនេះ ជាកម្រងសំណួរដែលអ្នកស្រាវជ្រាវបានរៀបចំរួចជាស្រេច ហើយអាចឱ្យអ្នកស្រាវជ្រាវចំណេញពេលវេលាក្នុងការប្រមូល និងបញ្ចូលទិន្នន័យថែមទៀតផង។ ចំណែកការសិក្សាស្រាវជ្រាវតាមបែបគុណវិស័យ អ្នកសិក្សាស្រាវជ្រាវនឹងប្រើប្រាស់កម្រងសំណួរបែបទម្រង់បើក សម្រាប់សម្ភាស ដើម្បីធ្វើការបំពេញ និងស្វែងរកនូវព័ត៌មានកាន់តែជាក់លាក់បន្ថែមទៀត។ លើសពីនេះទៅទៀត ការសិក្សាស្រាវជ្រាវតាមបែបគុណវិស័យ ធ្វើឱ្យអ្នកសិក្សាស្រាវជ្រាវ បានសិក្សាស៊ីជម្រៅទៅលើវិធីសាស្ត្រអាន និងរបៀបដែលសិស្សប្រើប្រាស់វិធីសាស្ត្រទាំងនោះក្នុងការអានអត្ថបទភាសាអង់គ្លេសឱ្យបានកាន់តែជាក់លាក់ថែមទៀត។

### ៣.១.១. ទីតាំងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវចំពោះប្រធានបទខាងលើ អ្នកសិក្សាបានសម្រេចជ្រើសរើសយកវិទ្យាល័យចំនួន ៨ នៅក្នុងខេត្តតាកែវ។ វិទ្យាល័យទាំងនោះត្រូវបានជ្រើសរើសចេញពីប្រភេទសាលាធំ សាលាមធ្យម និងសាលាតូច ដោយជ្រើសរើសយកភាគសំណាក គឺលោកគ្រូ អ្នកគ្រូដែលបង្រៀនភាសាអង់គ្លេសថ្នាក់ទី

១០ ថ្នាក់ទី ១១ និងថ្នាក់ទី១២ និងសិស្សានុសិស្សដែលកំពុងរៀនក្នុងកម្រិតថ្នាក់ទី ១០ ថ្នាក់ទី ១១ និងថ្នាក់ទី ១២ ក្នុងឆ្នាំសិក្សា ២០១៩-២០២០។ តាមរយៈលិខិតលេខ ២៥៦ អយក. សណន របស់ក្រសួងអប់រំ យុវជន និងកីឡា ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០២ សេចក្ដីណែនាំស្ដីអំពី ការកំណត់និយាមប្រើប្រាស់មន្ត្រីរាជការសម្រាប់សាលាមត្តេយ្យសិក្សា បឋមសិក្សា មធ្យមសិក្សាចំណេះទូទៅ និងសាលាគរុកោសល្យ បានកំណត់ពីប្រភេទសាលាធំជាសាលារៀនដែលមានចំនួនថ្នាក់រៀនច្រើនជាង៤០ថ្នាក់ សាលាមធ្យមជាសាលារៀនដែលមានចំនួនថ្នាក់រៀនចាប់ពី ២១ថ្នាក់ ដល់ ៤០ថ្នាក់ និងសាលាតូចជាសាលារៀនដែលមានចំនួនថ្នាក់រៀនតិចជាង ២១ថ្នាក់ ហេតុនេះចំពោះសាលាធំអ្នកសិក្សាបានជ្រើសយកវិទ្យាល័យចំនួនពីរគឺ វិទ្យាល័យ សម្ដេចក្រុមព្រះ អង្គនោប និងវិទ្យាល័យសុខអាន១ឧសភា។ ចំពោះសាលាមធ្យមអ្នកស្រាវជ្រាវបានជ្រើសយកវិទ្យាល័យចំនួនបីគឺ វិទ្យាល័យព្រៃទប់ វិទ្យាល័យហ៊ុន សែន ពោធិ៍អំពិល និងវិទ្យាល័យសុខ អាន លាយបូរ។ ចំណែកវិទ្យាល័យតូចអ្នកសិក្សាបានជ្រើសរើសយកវិទ្យាល័យចំនួនបីដែរគឺ វិទ្យាល័យ សុខ អានសន្លុង វិទ្យាល័យហ៊ុន សែន ព្រៃឈើទាល និងវិទ្យាល័យព្រៃឈើទាល។ ការសិក្សាស្រាវជ្រាវនេះប្រព្រឹត្តទៅ ក្នុងចន្លោះរវាងខែមីនា ដល់ ខែកញ្ញា ឆ្នាំ២០២០។

### ៣.១.២. អថេរ

អថេរដែលបានលើកមកក្នុងទីនេះ រួមមាន៖

- អថេរឯករាជ្យ ៖ លោកគ្រូ អ្នកគ្រូដែលកំពុងបង្រៀនភាសាអង់គ្លេសថ្នាក់ទី ១០ ថ្នាក់ទី ១១ និងថ្នាក់ទី១២ និងសិស្សានុសិស្សថ្នាក់ទី ១០ ថ្នាក់ទី ១១ និងថ្នាក់ទី១២ ក្នុងឆ្នាំសិក្សា ២០១៩-២០២០ នៃវិទ្យាល័យទាំង ៨ ដែលបានជ្រើសរើសខាងលើ ដោយបែងចែកទៅតាម ភេទ ចំនួនឆ្នាំដែលពួកគេបានរៀនភាសា និងចំនួនម៉ោងដែលពួកគេបានអានភាសាអង់គ្លេស។

- អថេរមិនឯករាជ្យ ៖ យុទ្ធសាស្ត្រការអានភាសាអង់គ្លេសទាំង៦ (6 Reading Su-skills) ដោយបែងចែកជា៣០វិធីសាស្ត្រតូចៗដាក់ក្នុងកម្រងសំណួរ។

## ៣.២. ការប្រមូលទិន្នន័យ

ក្រោយពីបានទទួលការប្រឹក្សាយោបល់ពីសំណាក់លោកសាស្ត្រាចារ្យដឹកនាំទាក់ទងទៅនឹងប្រធានបទស្រាវជ្រាវ ព្រមទាំងទទួលបានលិខិតអនុញ្ញាតពីវិទ្យាស្ថានជាតិអប់រំឱ្យនិស្សិតទាំងអស់ធ្វើការប្រមូលទិន្នន័យតាមប្រព័ន្ធ online ក៏ដូចជាការអនុញ្ញាតពីប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តតាកែវ អ្នកសិក្សាស្រាវជ្រាវបានរៀបចំផែនការដើម្បីប្រមូលទិន្នន័យ។ ដោយសារស្ថានភាពជំងឺកូវីត១៩ កំពុងរីករាលដាលទូទាំងពិភពលោក ប្រទេសកម្ពុជាបានបិទសាលារៀនទាំងអស់ដើម្បីការពារការឆ្លងរាលដាលនៃជំងឺនេះ និងបានអនុវត្តការសិក្សាពីចម្ងាយ។ ហេតុនេះ អ្នកស្រាវជ្រាវមិនអាចចុះទៅដល់សាលាផ្ទាល់ដើម្បីប្រមូលទិន្នន័យបានទេ។ អ្នកស្រាវជ្រាវក៏បានរៀបចំកម្រងសំណួរជាទម្រង់ Google Form វិញដើម្បីអាចឱ្យលោកគ្រូ អ្នកគ្រូ ក៏ដូចជាសិស្សានុសិស្សអាចបំពេញកម្រងសំណួរតាមប្រព័ន្ធ online បាន។ ក្រោយពីចងកម្រងសំណួរតាមទម្រង់ Google Form រួចហើយអ្នកស្រាវជ្រាវបានផ្ញើកម្រងសំណួរនោះទៅឱ្យសិស្ស ៥ នាក់ និងគ្រូ៥នាក់បំពេញសាកល្បង។ គោលបំណងនៃការសាកល្បងកម្រងសំណួរនេះគឺដើម្បីធានាអំពីប្រសិទ្ធភាព និងភាពពិតប្រាកដនៃកម្រងសំណួរថា តើអាចយកមកប្រមូលទិន្នន័យផ្លូវការបានដែរឬទេ។ ក្រោយពីការសាកល្បងលើកម្រងសំណួរទាំងនោះ អ្នកសិក្សាស្រាវជ្រាវសង្កេតឃើញថា ការសាកល្បងនេះពិតជាទទួលបានផលល្អមែន ព្រោះអ្នកសិក្សារកឃើញចំណុចខ្វះខាតមួយចំនួនរបស់កម្រងសំណួរ។ បន្ទាប់មកអ្នកសិក្សាស្រាវជ្រាវក៏យកបញ្ហាទាំងនោះទៅពិភាក្សាជាមួយសាស្ត្រាចារ្យដឹកនាំ ដើម្បីទទួលបានយោបល់ត្រឡប់ក្នុងការកែលម្អកម្រងសំណួរឡើងវិញ។ ក្រោយពីការណែនាំកែលម្អ និងមានការឯកភាពពីសាស្ត្រាចារ្យដឹកនាំរួចមក អ្នកសិក្សាស្រាវជ្រាវក៏ចាប់ផ្តើមធ្វើការទំនាក់ទំនងទៅកាន់នាយកសាលាគោលដៅទាំង ៨ ដែលត្រូវបានជ្រើសរើសរួចហើយនោះ តាមរយៈទូរស័ព្ទ និងប្រព័ន្ធតេឡេក្រាម ដើម្បីឱ្យគាត់ជួយសម្រួលក្នុងការទំនាក់ទំនងទៅកាន់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស។ ក្រោយពីនាយកសាលាបានពិនិត្យលិខិតអនុញ្ញាតពីមន្ទីរអប់រំ យុវជន និងកីឡាក្នុងកិច្ចការស្រាវជ្រាវនេះរួចហើយ គាត់ក៏បានអនុញ្ញាតឱ្យអ្នកសិក្សារៀបចំការប្រមូលទិន្នន័យ តាមផែនការដែលឯកភាពគ្នាទៅតាមដំណាក់

កាលនីមួយៗ។ ដំណើរការនៃការប្រមូលទិន្នន័យ ត្រូវបានពិភាក្សាជាមួយថ្នាក់ដឹកនាំសាលាអំពីគោលបំណង និងផែនការទាំងមូលនៃការសិក្សាស្រាវជ្រាវ។

បន្ទាប់ពីមានការយល់ព្រមសហការពីគណៈនាយកនៃវិទ្យាល័យរួចមក អ្នកសិក្សាក៏បានធ្វើការទំនាក់ទំនងទៅកាន់លោកគ្រូ អ្នកគ្រូដែលបង្រៀនភាសាអង់គ្លេសនៃសាលាគោលដៅទាំង៨ តាមប្រព័ន្ធទូរស័ព្ទ Messenger និងតេឡេក្រាមដើម្បីធ្វើការសម្ភាស និងឱ្យពួកគាត់បំពេញកម្រងសំណួរស្រាវជ្រាវរបស់អ្នកសិក្សា។ មុននឹងធ្វើការសម្ភាស និងឱ្យលោកគ្រូ អ្នកគ្រូបំពេញកម្រងសំណួរ អ្នកសិក្សាបានពន្យល់យ៉ាងច្បាស់លាស់ពីគោលបំណងនៃការស្រាវជ្រាវ ព្រមទាំងស្នើសុំឱ្យពួកគាត់ចែករំលែកទស្សនៈរបស់ពួកគាត់ដោយការស្ម័គ្រចិត្តជៀសវាងការជះឥទ្ធិពលមកដល់ចម្លើយ និងការវិភាគទិន្នន័យនៅពេលក្រោយ។ ចំណែកសិស្សានុសិស្ស អ្នកស្រាវជ្រាវក៏បានអនុវត្តដូចគ្នាចំពោះវិធីនៃការប្រមូលទិន្នន័យនេះដែរ ដោយមានការសហការពីលោកគ្រូ អ្នកគ្រូក្នុងការផ្តល់វិធីទំនាក់ទំនងតាមទូរស័ព្ទ តាមក្រុមសិក្សាពីចម្ងាយរបស់ពួកគាត់ជាតេឡេក្រាម និងក្រុម Messenger របស់គ្រូនីមួយៗ។ ក្រោយពីប្រមូលទិន្នន័យរួចរាល់ហើយ អ្នកស្រាវជ្រាវក៏បានធ្វើការសម្ភាសទៅកាន់សិស្ស ៣នាក់ក្នុងប្រភេទសាលានីមួយៗ តាមទូរស័ព្ទដៃដោយចៃដន្យចេញពីសិស្សដែលបានបំពេញកម្រងសំណួរ ដើម្បីទទួលបានព័ត៌មានកាន់តែជាក់លាក់។

ក្រោយពីធ្វើការសម្ភាសចប់សព្វគ្រប់ ជាចុងក្រោយអ្នកស្រាវជ្រាវក៏បានថ្លែងអំណរគុណទៅកាន់ភាគសំណាក លោកគ្រូ អ្នកគ្រូ គណៈនាយក និងសិស្សានុសិស្សដែលបានរួមចំណែកយ៉ាងសកម្ម ជាហេតុនាំឱ្យអ្នកស្រាវជ្រាវប្រមូលបានទិន្នន័យទៅតាមការកំណត់មួយរយភាគរយ។

### ៣.៣. ឧបករណ៍ស្រាវជ្រាវ

ដើម្បីប្រមូលទិន្នន័យបានជាក់លាក់ អ្នកសិក្សាស្រាវជ្រាវបានបង្កើតឧបករណ៍ស្រាវជ្រាវជាទម្រង់កម្រងសំណួរសម្រាប់បំពេញ និងកម្រងសំណួរសម្រាប់សម្ភាស ដែលក្នុងនោះមានកម្រងសំណួរសម្រាប់ឱ្យសិស្សបំពេញ និងកម្រងសំណួរសម្រាប់សម្ភាសសិស្ស កម្រងសំណួរបំពេញសម្រាប់លោកគ្រូ អ្នកគ្រូ និងកម្រងសំណួរសម្រាប់សម្ភាសលោកគ្រូ អ្នកគ្រូដែលបង្រៀនភាសាអង់គ្លេសថ្នាក់ទី១០ ថ្នាក់ទី១១ និង

ថ្នាក់ទី១២។ ចំពោះទម្រង់កម្រងសំណួរសម្រាប់ឱ្យសិស្សបំពេញគឺមានលក្ខណៈ ជាទម្រង់វាយតម្លៃតាមកម្រិតការអនុវត្ត តាមកម្រិតនៃការប្រើប្រាស់វិធីសាស្ត្រអានរបស់សិស្សដូចជា កម្រិតនៃការប្រើច្រើនបំផុត ច្រើន មធ្យម តិច និងតិចបំផុត។ ម្យ៉ាងទៀត កម្រងសំណួរនេះផ្តោតជាសំខាន់ទៅលើបំណិនអានជាភាសាអង់គ្លេសទាំង៦ (6 Reading Sub-skills) ដោយបែងចែកជា៣០វិធីសាស្ត្រតូចៗដើម្បីឱ្យអ្នកបំពេញងាយស្រួលយល់។ នៅក្នុងកម្រងសំណួរបំពេញសម្រាប់គ្រូត្រូវបានចែកចេញជា៤ ផ្នែកធំៗ ដូចជា៖

- ផ្នែកទី១ អំពីព័ត៌មានផ្ទាល់ខ្លួន ដែលទាក់ទងនឹង ភេទ អាយុ កម្រិតថ្នាក់ដែលគ្រូបង្រៀន ឈ្មោះសាលារៀន និងឯកទេសដើមរបស់លោកគ្រូ អ្នកគ្រូ។
- ផ្នែកទី២ ព័ត៌មានទូទៅទាក់ទងនឹងការបង្រៀនភាសាអង់គ្លេស ដូចជាចំនួនឆ្នាំដែលបង្រៀនភាសាអង់គ្លេស ការប្រាប់ហេតុផលរៀនភាសាអង់គ្លេសដល់សិស្ស សារៈសំខាន់នៃសមត្ថភាពអានភាសាអង់គ្លេស ការវាយតម្លៃកម្រិតសមត្ថភាពរបស់សិស្ស រយៈពេលដែលគ្រូឱ្យសិស្សចំណាយសម្រាប់អានភាសាអង់គ្លេសក្នុងមួយថ្ងៃ និងភាពញឹកញាប់នៃការដាក់កិច្ចការផ្ទះទាក់ទងនឹងការអានទៅដល់សិស្ស។
- ផ្នែកទី៣ ទាក់ទងនឹងវិធីសាស្ត្របង្រៀនអំណានរបស់គ្រូសម្រាប់ជួយឱ្យសិស្សមានសមត្ថភាពអានភាសាអង់គ្លេសល្អ ដែលត្រូវបានបែងចែកជា៨សំណួរតូចៗទៀតដែលទាក់ទងនឹងវិធីសាស្ត្រអានដែលគ្រូបានបង្រៀនដល់សិស្ស ការយល់ឃើញរបស់គ្រូទៅលើកម្រិតនៃការយល់ដឹងរបស់សិស្សលើសមត្ថភាពអាន ការណែនាំពីវិធីសាស្ត្រអាន និងមូលហេតុ ការណែនាំសិស្សពេលជួបបញ្ហានៅពេលអាន ការណែនាំសិស្សដើម្បីជួយឱ្យពួកគេយល់ខ្លឹមសារអត្ថបទ បញ្ហាលំបាកដែលសិស្សជួបនៅពេលអាន ភាពញឹកញាប់ដែលសិស្សទាមទារឱ្យគ្រូបកប្រែអត្ថបទជាភាសាខ្មែរ ការណែនាំឱ្យសិស្សប្រើវចនានុក្រម និងការយល់ឃើញរបស់គ្រូអំពីកម្រិតសំខាន់នៃការបង្កើនសមត្ថភាពអានរបស់សិស្ស។

❖ ផ្នែកទី៤ យោបល់ និងសំណូមពរ ដែលលោកគ្រូ អ្នកគ្រូ អាចបញ្ចេញយោបល់ផ្ទាល់ខ្លួន និងសំណូមពរផ្សេងៗដែលពួកគាត់ចង់ឱ្យគណៈគ្រប់គ្រង ឬអ្នកពាក់ព័ន្ធដទៃទៀតជួយឱ្យការបង្រៀនសមត្ថភាពអានដល់សិស្សរបស់ពួកគាត់បានរីកចម្រើន។

បំណែកកម្រងសំណួរបំពេញសម្រាប់សិស្សត្រូវបានបែងចែកជា៥ ផ្នែកធំៗគឺ៖

❖ ផ្នែកទី១ ព័ត៌មានផ្ទាល់ខ្លួនរបស់សិស្ស ដែលក្នុងផ្នែកនេះមាន៤សំណួរ ទាក់ទងទៅនឹង ភេទ អាយុ កម្រិតថ្នាក់ និងឈ្មោះរបស់សាលារៀន។

❖ ផ្នែកទី២ ព័ត៌មានទូទៅទាក់ទងនឹងការរៀនភាសាអង់គ្លេសរបស់សិស្ស ដែលក្នុងនោះអ្នកសិក្សាបានបែងចែកជា៥សំណួរ ទាក់ទងទៅនឹងចំនួនឆ្នាំដែលសិស្សរៀនភាសាអង់គ្លេស ហេតុផលនៃការរៀន កម្រិតសំខាន់នៃភាសាអង់គ្លេស កម្រិតសមត្ថភាព និងចំនួនម៉ោងដែលសិស្សចំណាយសម្រាប់ការអានភាសាអង់គ្លេសក្នុងមួយថ្ងៃ។

❖ ផ្នែកទី៣ ការអនុវត្តវិធីសាស្ត្រនៃបំណិនអានដែលសិស្សត្រូវគូសធីក លើវិធីសាស្ត្រទាំងឡាយដែលមានក្នុងកម្រងសំណួរ ដែលមាន៦វិធីសាស្ត្រធំៗ និងចែកជា៣០ខ្លឹមសារតូចៗ ស្របទៅតាមភាពជាក់ស្តែងរបស់ពួកគេ ដោយជ្រើសរើសទៅតាមកម្រិតដូចខាងក្រោម៖

- **ច្រើនបំផុត** មានន័យថា៖ ការអនុវត្តតាមខ្លឹមសារគោលគំនិតនោះ **ច្រើនបំផុត** ឬជាប្រចាំគ្រប់ពេលយ៉ាងទៀងទាត់ ពោលគឺក្នុងកម្រិតពី ៩១% - ១០០%។

- **ច្រើន** មានន័យថា៖ ការអនុវត្តតាមខ្លឹមសារគោលគំនិតនោះ **ច្រើន** ឬស្ទើរគ្រប់ពេល ពោលគឺក្នុងកម្រិតពី ៦១% - ៩០%។

- **មធ្យម** មានន័យថា៖ ការអនុវត្តតាមខ្លឹមសារគោលគំនិតនោះ **មធ្យម** ឬអនុវត្តខ្លះមិនអនុវត្តខ្លះ ពោលគឺក្នុងកម្រិតពី ៤១% - ៦០%។

- **តិច** មានន័យថាៈ ការអនុវត្តតាមខ្លឹមសារគោលគំនិតនោះ **តិច** ឬអនុវត្តម្តងម្កាលក្នុងកម្រិតតិចតួច ពោលគឺក្នុងកម្រិតពី ១១% - ៤០%។

- **តិចបំផុត** មានន័យថាៈ ការអនុវត្តតាមខ្លឹមសារគោលគំនិតនោះ **តិចបំផុត** មិនដែលធ្វើទាល់តែសោះ ឬធ្វើក្នុងកម្រិតតិចបំផុត ពោលគឺក្នុងកម្រិតពី 0% - ១០%។

❖ ផ្នែកទី៤ ការយល់ដឹងអំពីការប្រើប្រាស់វិធីសាស្ត្រអានភាសាអង់គ្លេស ដែលជាកម្រងសំណួរដែលតម្រូវឱ្យសិស្សបំពេញអំពីរបៀបដែលពួកគេប្រើវិធីសាស្ត្រអានទាំង៦ ដើម្បីចង់ដឹងថាសិស្សយល់ពីការប្រើវិធីសាស្ត្រទាំងនោះច្បាស់កម្រិតណា។

❖ ផ្នែកទី៥ គឺយោបល់ និងសំណូមពរ ដែលសិស្សអាចបញ្ចេញយោបល់ផ្ទាល់ខ្លួន និងដាក់ជាសំណូមពរផ្សេងៗដែលពួកគេចង់ឱ្យ លោកគ្រូ អ្នកគ្រូ ឬអ្នកពាក់ព័ន្ធដទៃទៀតដែលអាចជួយឱ្យសមត្ថភាពអានរបស់ពួកគេរីកចម្រើន។

### ៣.៤. ការជ្រើសរើសភាគសំណាក

ចំពោះទំហំប្រជាជន និងភាគសំណាក អ្នកស្រាវជ្រាវបានជ្រើសរើសយកខេត្តតាកែវជាគោលដៅ និងលោកគ្រូ អ្នកគ្រូបង្រៀនភាសាអង់គ្លេសថ្នាក់ទី១០ ថ្នាក់ទី១១ ថ្នាក់ទី១២ និងសិស្សានុសិស្សដែលកំពុងរៀនក្នុងកម្រិតថ្នាក់ទី១០ ថ្នាក់ទី១១ និងថ្នាក់ទី១២ ក្នុងឆ្នាំសិក្សា ២០១៩-២០២០។ ដោយសារតែវិទ្យាល័យក្នុងខេត្តតាកែវត្រូវបានបែងចែកជាបីប្រភេទគឺ សាលាធំ សាលាមធ្យម និងសាលាតូច អ្នកស្រាវជ្រាវក៏បានជ្រើសរើសយកវិទ្យាល័យចេញពីប្រភេទសាលានីមួយៗ ដោយបានកំណត់យកសិស្សថ្នាក់ទី១០ ថ្នាក់ទី១១ និងថ្នាក់ទី១២ ក្នុងមួយកម្រិតថ្នាក់ ១០នាក់។ មានន័យថាសិស្សថ្នាក់ទី១០របស់សាលាធំចំនួន១០នាក់ សាលាមធ្យមចំនួន១០នាក់ សាលាតូចចំនួន១០នាក់ សិស្សថ្នាក់ទី១១របស់សាលាធំចំនួន១០នាក់ សាលាមធ្យមចំនួន១០នាក់ សាលាតូចចំនួន១០នាក់ និងសិស្សថ្នាក់ទី១២របស់សាលាធំចំនួន១០នាក់ សាលាមធ្យមចំនួន១០នាក់ សាលាតូចចំនួន១០នាក់។ ចំណែកគ្រូបង្រៀន អ្នកស្រាវជ្រាវបានជ្រើសយកគ្រូបង្រៀនរបស់ប្រភេទសាលាធំចំនួន៥នាក់ គ្រូបង្រៀនរបស់ប្រភេទសាលាមធ្យមចំនួន៥

នាក់ និងគ្រូបង្រៀនរបស់ប្រភេទសាលាតូចចំនួន ៥នាក់។ ហេតុនេះ ដើម្បីឱ្យបានភាគសំណាកគ្រូគ្រប់ចំនួន អ្នកស្រាវជ្រាវបានជ្រើសរើសយកវិទ្យាល័យ២ចេញពីប្រភេទសាលាធំ គឺវិទ្យាល័យសម្តេចក្រុមព្រះអង្គនាប និងវិទ្យាល័យសុខអាន១ឧសភា។ ចំពោះប្រភេទសាលាមធ្យមអ្នកស្រាវជ្រាវបានជ្រើសរើសយកវិទ្យាល័យ៣ គឺវិទ្យាល័យព្រៃទប់ វិទ្យាល័យហ៊ុនសែនពោធិ៍អំពិល និងវិទ្យាល័យសុខអានលាយបូរ។ ចំណែកវិទ្យាល័យតូចអ្នកសិក្សាបានជ្រើសយកវិទ្យាល័យ៣ដែរគឺ វិទ្យាល័យសុខអានសន្លុង វិទ្យាល័យហ៊ុនសែនព្រៃឈើទាល និងវិទ្យាល័យព្រៃឈើទាល។

អ្នកស្រាវជ្រាវ បានប្រើប្រាស់ភាគសំណាក២ប្រភេទក្នុងការសិក្សាស្រាវជ្រាវនេះដែលរួមមានភាគសំណាកទី១គឺ លោកគ្រូ អ្នកគ្រូ បង្រៀនភាសាអង់គ្លេស ថ្នាក់ទី១០ ថ្នាក់ទី១១ និងថ្នាក់ទី១២ព្រោះពួកគាត់ជាអ្នកបង្រៀនផ្ទាល់ ហើយក៏ជាអ្នកបានដឹងពីការប្រើប្រាស់វិធីសាស្ត្រអានរបស់សិស្សនៅក្នុងថ្នាក់។ ភាគសំណាកទី២គឺ សិស្សានុសិស្សថ្នាក់ទី១០ ថ្នាក់ទី១១ និងថ្នាក់ទី១២ ក្នុងឆ្នាំសិក្សា ២០១៩-២០២០ នៃវិទ្យាល័យទាំង៨ខាងលើដែលត្រូវបានជ្រើសរើសជាភាគសំណាក សម្រាប់ប្រើក្នុងការប្រមូលទិន្នន័យស្រាវជ្រាវនេះ។

តារាង ៣.១៖ ភាគសំណាកនៃការស្រាវជ្រាវ

| ភាគសំណាក | វិទ្យាល័យធំ(១) វិ. សម្តេចក្រុមព្រះអង្គនាប និង វិ. សុខអាន១ឧសភា | | វិទ្យាល័យមធ្យម(២) វិ.ពោធិអំពិល វិ. លាយបូរ និង វិ. ព្រៃទប់ | | វិទ្យាល័យតូច(៣) វិ. សន្លុង វិ.ហស ព្រៃឈើទាល និងវិ. ព្រៃឈើទាល | | (១)+(២)+(៣) | |
|---|---|---|---|---|---|---|---|---|
| | សិស្ស | គ្រូ | សិស្ស | គ្រូ | សិស្ស | គ្រូ | សិស្ស | គ្រូ |
| ថ្នាក់ទី ១០ | ១០ នាក់ | | ១០ នាក់ | ៥ នាក់ | ១០ នាក់ | ៥ នាក់ | ៣០ នាក់ | ៥ នាក់ |
| ថ្នាក់ទី ១១ | ១០ នាក់ | ៥ នាក់ | ១០ នាក់ | | ១០ នាក់ | | ៣០ នាក់ | ៥ នាក់ |
| ថ្នាក់ទី ១២ | ១០ នាក់ | | ១០ នាក់ | | ១០ នាក់ | | ៣០ នាក់ | ៥ នាក់ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ភាគសំណាកសរុប | ៣០ នាក់ | ៥ នាក់ | ៣០ នាក់ | ៥ នាក់ | ៣០ នាក់ | ៥ នាក់ | ៩០ នាក់ | ១៥ នាក់ |

## ៣.៥. ការវិភាគទិន្នន័យ

ការសិក្សាស្រាវជ្រាវនេះ អ្នកសិក្សាបានប្រើប្រាស់វិធីសាស្ត្រវិភាគទិន្នន័យតាមបែបបរិមាណវិស័យ និងគុណវិស័យ។ ក្នុងការវិភាគបែបបរិមាណវិស័យទិន្នន័យដែលប្រមូលបាន អ្នកស្រាវជ្រាវបានប្រើប្រាស់វិធីសាស្ត្រដូចជា៖

- ប្រើប្រាស់កម្មវិធី SPSS សម្រាប់គណនាស្ថិតិបែបពិពណ៌នា (Descriptive Statistic) ដើម្បីគណនា តម្លៃមធ្យម គំលាតស្តង់ដា និងភាគរយ (percentage) ជំរុញដល់ការសង់ក្រាហ្វ ឬធ្វើចំណាត់ថ្នាក់ទៅតាមយុទ្ធសាស្ត្រអានទាំង៦ និងចែកជា៣០វិធីសាស្ត្រតូចៗ។ Independent Sample t-Test សម្រាប់ធ្វើការប្រៀបធៀបយុទ្ធសាស្ត្រអានរបស់សិស្សដោយយោងទៅតាម ភេទ និងចំនួនម៉ោងដែលសិស្សបានអានភាសាអង់គ្លេស។ ចំណែក One-Way ANOVA សម្រាប់ប្រៀបធៀបពីចំនួនឆ្នាំដែលសិស្សបានរៀនភាសាអង់គ្លេស។
- Microsoft Excel សម្រាប់សង់ក្រាប តារាង និងបកស្រាយព័ត៌មានរបស់ភាគសំណាកនីមួយៗ។

ការវិភាគបែបគុណវិស័យ ជាការប្រមូលផ្តុំគំនិត ទស្សនៈ ការយល់ឃើញនានា របស់អ្នកផ្តល់បទសម្ភាសន៍ដោយចាប់បញ្ចូលនូវចំណុចដែលដូច ឬប្រហាក់ប្រហែលគ្នាដើម្បីបន្ថែមព័ត៌មាន និងបង្ហាញគំនិតគាំទ្រចំពោះទិន្នន័យនៃការវិភាគតាមបែបបរិមាណវិស័យ។ បន្ទាប់មកអ្នកសិក្សាស្រាវជ្រាវបានលើកឡើងជាសំណូមពរចំពោះចំណុចខ្វះខាត និងកែលម្អចំណុចខ្វះខាតទាំងនោះឱ្យបានប្រសើរឡើង។

# ជំពូកទី ៤
# លទ្ធផលនៃការស្រាវជ្រាវ និងការពិភាក្សា

# ជំពូកទី ៤

# លទ្ធផលនៃការស្រាវជ្រាវ និងការពិភាក្សា

នៅក្នុងជំពូកនេះអ្នកស្រាវជ្រាវនឹងធ្វើការបកស្រាយ និងពិភាក្សាលទ្ធផលនៃការវិភាគទិន្ន័យដែលបានមកពីការបំពេញកម្រងសំណួររបស់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស ព្រមទាំងលទ្ធផលដែលបានមកពីការសម្ភាស លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សដើម្បីឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវដែលត្រូវបានបកស្រាយជាបន្តបន្ទាប់ ដូចខាងក្រោមៈ

១. តើសិស្សនៅមធ្យមសិក្សាទុតិយភូមិក្នុងខេត្តតាកែវ មានការយល់ដឹងលើការប្រើប្រាស់វិធីសាស្ត្រនៃបំណិនអានភាសាអង់គ្លេសក្នុងកម្រិតណា?

២. តើមានភាពដូចគ្នា ឬខុសគ្នាដែរឬទេ ចំពោះការយល់ដឹងពីវិធីសាស្ត្របំណិនអានភាសាអង់គ្លេសរបស់សិស្ស បើយោងទៅតាម ភេទ ចំនួនឆ្នាំដែលពួកគេបានរៀនភាសា និងចំនួនម៉ោងដែលពួកគេបានអានភាសាអង់គ្លេស ?

## ៤.១. របៀបនៃការបង្ហាញព័ត៌មាន

ព័ត៌មានត្រូវបានបង្ហាញតាមរយៈតារាងដែលក្នុងនោះ Mean តាងឱ្យតម្លៃមធ្យមក្នុងការវាយតម្លៃកម្រិតយល់ដឹងរបស់សិស្សលើការប្រើប្រាស់វិធីសាស្ត្រនៃបំណិនអានជាភាសាអង់គ្លេស ដែលក្នុងនោះប្រសិនបើៈ

- Mean មានតម្លៃចាប់ពី ៣.៥០ ឡើងទៅ មានន័យថា ខ្ពស់
- Mean មានតម្លៃចាប់ពី ២.៥០ ដល់ ៣.៤៩ មានន័យថា មធ្យម
- Mean មានតម្លៃតូចជាង ២.៥០ មានន័យថា ទាប ( Oxford, R.L.and Burry-stock, J.A, 1995 )

អក្សរកាត់នៅក្នុងតារាងត្រូវបានពន្យល់ដូចខាងក្រោមៈ

- SD តាងឱ្យ គម្លាតស្តង់ដា

- t តាងឱ្យ តម្លៃស្ថិតិនៃការវិភាគតេស្ត Independent-Sample t-Test
- F តាងឱ្យ តម្លៃស្ថិតិនៃការវិភាគតេស្ត One-Way ANOVA
- ss តាងឱ្យ តម្លៃនៃផលបូកការេ ( sum of square )
- df តាងឱ្យចំនួនដឺក្រេសេរី ឬអថេរសេរី
- p តាងឱ្យ កម្រិតសំខាន់នៃភាពជឿជាក់ដែលមានទំហំ ០.០៥

## ៤.២. លទ្ធផលនៃការសិក្សាស្រាវជ្រាវ

### ៤.២.១. ព័ត៌មានរបស់ភាគសំណាកដែលបានចូលរួម

ភាគសំណាកដែលបានចូលរួម គឺជាគ្រូបង្រៀនភាសាអង់គ្លេស និងសិស្សានុសិស្សថ្នាក់ទី១០ ថ្នាក់ទី១១ និងថ្នាក់ទី១២ ដែលត្រូវបានជ្រើសរើសចេញពីសាលាបីប្រភេទគឺ សាលាធំ សាលាមធ្យម និងសាលាតូចនៅក្នុងខេត្តតាកែវ។ តាមរយៈលិខិតលេខ ២៥៦ អយក. សណន របស់ក្រសួងអប់រំ យុវជន និងកីឡា ចុះថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០០២ សេចក្តីណែនាំស្តីអំពី ការកំណត់និយាមប្រើប្រាស់មន្ត្រីរាជការសម្រាប់សាលាមត្តេយ្យសិក្សា បឋមសិក្សា មធ្យមសិក្សាចំណេះទូទៅ និងសាលាគរុ កោសល្យ បានកំណត់ពីប្រភេទសាលាធំជាសាលារៀនដែលមានចំនួនថ្នាក់រៀនច្រើនជាង ៤០ ថ្នាក់ សាលាមធ្យមជាសាលារៀនដែលមានចំនួនថ្នាក់រៀនចាប់ពី ២១ ថ្នាក់ ដល់ ៤០ថ្នាក់ និងសាលាតូចជាសាលារៀនដែលមានចំនួនថ្នាក់រៀនតិចជាង ២១ថ្នាក់។ ហេតុនេះចំពោះសាលាធំ អ្នកស្រាវជ្រាវបានយកវិទ្យាល័យ២គឺ វិទ្យាល័យសម្តេចក្រុមព្រះអង្គនោប និងវិទ្យាល័យសុខអាន១ឧសភា។ ចំពោះសាលាមធ្យមអ្នកស្រាវជ្រាវបានជ្រើសយកវិទ្យាល័យ៣គឺ វិទ្យាល័យព្រៃទប់ វិទ្យាល័យហ៊ុនសែនពោធិ៍អំពិល និងវិទ្យាល័យសុខអានលាយបូរ។ ចំណែកសាលាតូចអ្នកសិក្សាបានជ្រើសយកវិទ្យាល័យ៣ដែរគឺ វិទ្យាល័យសុខអានសន្លុង វិទ្យាល័យហ៊ុនសែនព្រៃឈើទាល និងវិទ្យាល័យព្រៃឈើទាល។

តារាង ៤.១៖ ភាគសំណាកដែលបានចូលរួម

| ភាគសំណាក | វិទ្យាល័យធំ(១) វិ. សម្តេចក្រុមព្រះអង្គនរាប និង វិ. សុខអាន១ឧសភា | | វិទ្យាល័យមធ្យម(២) វិ.ពោធិអំពិល វិ. លាយបូរ និង វិ. ព្រៃទប់ | | វិទ្យាល័យតូច(៣) វិ. សន្លុង វិ.ហស ព្រៃឈើទាល និង វិ.ព្រៃឈើទាល | | (១)+(២)+(៣) | |
|---|---|---|---|---|---|---|---|---|
| | សិស្ស | គ្រូ | សិស្ស | គ្រូ | សិស្ស | គ្រូ | សិស្ស | គ្រូ |
| ថ្នាក់ទី១០ | ១២ នាក់ | | ២២ នាក់ | ៥ នាក់ | ១២ នាក់ | ៥ នាក់ | ៤៨ នាក់ | ៥ នាក់ |
| ថ្នាក់ទី១១ | ២០ នាក់ | ៥ នាក់ | ១១ នាក់ | | ១២ នាក់ | | ៤៤ នាក់ | ៥ នាក់ |
| ថ្នាក់ទី១២ | ១៦ នាក់ | | ១១ នាក់ | | ១៥ នាក់ | | ៣៩ នាក់ | ៥ នាក់ |
| សរុប | ៤៨ នាក់ | ៥ នាក់ | ៤៤ នាក់ | ៥ នាក់ | ៣៩ នាក់ | ៥ នាក់ | ១៣១ នាក់ | ១៥ នាក់ |

តាមរយៈតារាង៤.១ខាងលើបង្ហាញថា ក្នុងចំណោមភាគសំណាកនៅក្នុងវិទ្យាល័យទាំង៨ ខាងលើ អ្នកស្រាវជ្រាវប្រមូលទិន្នន័យពីគ្រូបង្រៀនភាសាអង់គ្លេសដែលបង្រៀនថ្នាក់ទី១០ ថ្នាក់ទី១១ និងថ្នាក់ទី១២បានសរុបចំនួន ១៥នាក់ ស្រី ៤នាក់ និងប្រុស ១១នាក់។ ក្នុងនោះគ្រូបង្រៀនវិទ្យាល័យធំចំនួន ៥នាក់ គ្រូបង្រៀនវិទ្យាល័យមធ្យមចំនួន ៥នាក់ និងគ្រូបង្រៀនវិទ្យាល័យតូចចំនួន ៥នាក់។ អ្នកស្រាវជ្រាវទទួលបានទិន្នន័យពីសិស្សចំនួន ១៣១នាក់ ស្រី ៨៩នាក់ ប្រុស៤២នាក់ ដោយសារទិន្នន័យនេះត្រូវបានប្រមូលតាមប្រព័ន្ធ online ហេតុនេះភាគសំណាកសិស្សដែលប្រមូលបានគឺលើសផែនការចំនួន ៤១នាក់ ស្មើនឹង ៤៥.៥%។ ក្នុងនោះទិន្នន័យដែលបានពីសិស្សវិទ្យាល័យធំមានចំនួន ៤៨នាក់ ស្មើនឹង ៣៦% សិស្សវិទ្យាល័យមធ្យមមានចំនួន ៤៤នាក់ ស្មើនឹង ៣៤% និងទិន្នន័យដែលបានមកពីសិស្សវិទ្យាល័យតូចមានចំនួន ៣៩នាក់ ស្មើនឹង ៣០%។

### ៤.២.២. សំណួរស្រាវជ្រាវទី ១

សំណួរស្រាវជ្រាវទី១ ត្រូវបានបង្កើតឡើងដើម្បីឆ្លើយតបនឹងគោលបំណងទីមួយរបស់ប្រធានបទស្រាវជ្រាវដែលចង់រកឱ្យឃើញពីកម្រិតនៃការយល់ដឹងរបស់សិស្ស ក្នុងការប្រើប្រាស់វិធីសាស្ត្រលើបំណិនអានភាសាអង់គ្លេស ដោយចោទសួរថា៖ តើសិស្សនៅមធ្យមសិក្សាទុតិយភូមិក្នុងខេត្តតាកែវ មានការយល់ដឹងលើការប្រើប្រាស់វិធីសាស្ត្រនៃបំណិនអានជាភាសាអង់គ្លេសក្នុងកម្រិតណា?

ក្នុងការបកស្រាយសំណួរទី១នេះ អ្នកស្រាវជ្រាវបានប្រើប្រាស់ទិន្នន័យដែលបានមកពីការបំពេញកម្រងសំណួររបស់ភាគសំណាកសិស្សទាំង ១៣១នាក់ និងគ្រូចំនួន ១៥នាក់សម្រាប់យកមកធ្វើការបកស្រាយ និងវិភាគ។ អ្នកស្រាវជ្រាវបានចងកូដ និងបញ្ចូលទិន្នន័យក្នុងកម្មវិធី SPSS និងបានធ្វើការវិភាគរកភាគរយ តម្លៃមធ្យម គម្លាតស្តង់ដា និងបានប្រើប្រាស់កម្មវិធី excel សម្រាប់សង់ក្រាប និងគូសតារាង។ អ្នកសិក្សាបានធ្វើការវិភាគវិធីសាស្ត្រទាំង៦ម្តងមួយៗ ដើម្បីស្វែងយល់ពីកម្រិតនៃការយល់ដឹងលើវិធីសាស្ត្រនីមួយៗ បន្ទាប់មកទើបធ្វើការប្រៀបធៀបពីការយល់ដឹងលើវិធីសាស្ត្រទាំងអស់ជារួម។

#### ៤.២.២.១. ទិន្នន័យដែលបានពីលោកគ្រូ អ្នកគ្រូ

**ក. ការយល់ឃើញរបស់គ្រូទៅលើកម្រិតសំខាន់នៃភាសាអង់គ្លេសចំពោះសិស្ស**

ក្រាប៤.១៖ ការយល់ឃើញរបស់គ្រូទៅលើកម្រិតសំខាន់នៃភាសាអង់គ្លេស



តាមរយៈក្រាប៤.១ ខាងលើបង្ហាញថា ក្នុងចំណោមគ្រូបង្រៀន ១៥នាក់ មានគ្រូបង្រៀនចំនួន ១៣នាក់ ស្មើនឹង ៨៧%ដែលយល់ថាសមត្ថភាពផ្នែកភាសាអង់គ្លេសមានសារៈសំខាន់ខ្លាំងណាស់ចំពោះសិស្ស និងមានគ្រូបង្រៀនចំនួន ២នាក់ ស្មើនឹង ១៣% ដែលយល់ថាសមត្ថភាពផ្នែកភាសាអង់គ្លេសមានសារៈសំខាន់ចំពោះសិស្ស។ សរុបមកគ្រូបង្រៀនស្ទើរតែទាំងអស់យល់ថា សមត្ថភាពផ្នែកភាសាអង់គ្លេសមានសារៈសំខាន់ខ្លាំងណាស់ចំពោះសិស្ស។

**ខ. សមត្ថភាពទូទៅផ្នែកភាសាអង់គ្លេសរបស់សិស្ស**

ក្រាប៤.២៖ ការយល់ឃើញរបស់គ្រូលើសមត្ថភាពទូទៅផ្នែកភាសាអង់គ្លេសរបស់សិស្ស




តាមរយៈក្រាប៤.២ ខាងលើបង្ហាញថា មានគ្រូបង្រៀន១៣%បានយល់ថាសិស្សមានសមត្ថភាពទូទៅផ្នែកភាសាអង់គ្លេសខ្សោយ មានគ្រូបង្រៀន៨០% យល់ថាសិស្សមានសមត្ថភាពទូទៅផ្នែកភាសាអង់គ្លេសមធ្យម និងមានគ្រូបង្រៀន៧% យល់ថាសិស្សមានសមត្ថភាពទូទៅផ្នែកភាសាអង់គ្លេសល្អ។ សរុបមកគ្រូបង្រៀនភាគច្រើនយល់ថាសិស្សមានសមត្ថភាពទូទៅផ្នែកភាសាអង់គ្លេសមធ្យម។

## គ. សមត្ថភាពអានភាសាអង់គ្លេសរបស់សិស្ស

ក្រាប៤.៣៖ ការយល់ឃើញរបស់គ្រូលើសមត្ថភាពអានភាសាអង់គ្លេសរបស់សិស្ស




តាមរយៈក្រាប៤.៣ ខាងលើបង្ហាញថា គ្រូ៧%យល់ថាសិស្សមានសមត្ថភាពអានភាសាអង់គ្លេសខ្សោយ គ្រូ ៧៣% យល់ថាសិស្សមានសមត្ថភាពអានភាសាអង់គ្លេសមធ្យម និងមានគ្រូ ២០% យល់ថាសិស្សមានសមត្ថភាពអានភាសាអង់គ្លេសល្អ។ សរុបមក គ្រូបង្រៀនភាគច្រើនយល់ថាសិស្សមានសមត្ថភាពអានភាសាអង់គ្លេសមធ្យម។

## ឃ. ការដាក់កិច្ចការផ្ទះទាក់ទងនឹងការអាន

ក្រាប៤.៤៖ ភាពញឹកញាប់នៃការដាក់កិច្ចការផ្ទះរបស់គ្រូទាក់ទងនឹងការអាន



តាមរយៈក្រាប៤.៤ បង្ហាញថាមានគ្រូ ២៧% បានដាក់កិច្ចការទាក់ទងនឹងការអានដល់សិស្សម្តងម្កាល មានគ្រូបង្រៀន ៦៦%បានដាក់កិច្ចការទាក់ទងនឹងការអានដល់សិស្សញឹកញាប់ និងមានគ្រូបង្រៀន ២៧% បានដាក់កិច្ចការទាក់ទងនឹងការអានដល់សិស្សញឹកញាប់ណាស់។ សរុបមក គ្រូបង្រៀនជាមធ្យមបានដាក់កិច្ចការផ្ទះទាក់ទងនឹងការអានដល់សិស្សញឹកញាប់។

## ខ. បំណិនអានដែលគ្រូបានបង្រៀនទៅសិស្ស

ក្រាប៤.៥៖ ភាគរយបំណិនអានដែលគ្រូបានបង្រៀនទៅសិស្ស




តាមរយៈក្រាប៤.៥ ខាងលើបង្ហាញថា មានគ្រូបង្រៀន ២១.១០% បានបង្រៀនវិធីសាស្ត្រ Scanning ដល់សិស្ស មានគ្រូបង្រៀន ២២.៨០% បានបង្រៀនវិធីសាស្ត្រ Skimming ដល់សិស្ស មានគ្រូបង្រៀន ១២.៣០% បានបង្រៀនវិធីសាស្ត្រ Reading to confirm information ដល់សិស្ស មានគ្រូបង្រៀន ២១.១០% បានបង្រៀនវិធីសាស្ត្រ Reading for main idea ដល់សិស្ស មានគ្រូបង្រៀន ១៤% បានបង្រៀនវិធីសាស្ត្រ Reading for specific information ដល់សិស្ស និងមានគ្រូបង្រៀន ៨.៨០% បានបង្រៀនវិធីសាស្ត្រ Reading Detailed comprehensionដល់សិស្ស។ សរុបមក គ្រូបានបង្រៀនទៅលើវិធីសាស្ត្រ Skimming ច្រើនជាងគេ។

**ច. ការយល់ឃើញរបស់គ្រូទៅលើកម្រិតនៃការប្រើវិធីសាស្ត្រអានភាសាអង់គ្លេស របស់សិស្ស**

តារាង ៤.២៖ ការយល់ឃើញរបស់គ្រូទៅលើកម្រិតនៃការប្រើវិធីសាស្ត្រអានភាសាអង់គ្លេសរបស់សិស្ស

| ខ្លឹមសារ វិធីសាស្ត្រអានជាភាសាអង់គ្លេស | មធ្យម | គំលាតស្តង់ដា | កម្រិត |
|---|---|---|---|
| ១. អំណានរហ័សសម្រាប់ស្វែងរកព័ត៌មានជាក់លាក់ណាមួយ (Scanning) | ២.៧៣ | ០.៨០ | មធ្យម |
| ២. អំណានរហ័សសម្រាប់ស្វែងរកគោលគំនិតសំខាន់ (Skimming) | ២.៦៦ | ០.៦២ | មធ្យម |
| ៣. ការអានដើម្បីស្វែងរកព័ត៌មានមកអះអាងបញ្ជាក់ (Reading to conform information) | ២.៦៦ | ០.៤៩ | មធ្យម |
| ៤. ការអានយ៉ាងលម្អិត ដើម្បីឱ្យយល់ពីគំនិតសំខាន់នៃអត្ថបទទាំងមូល (Reading for main idea) | ២.៧៣ | ០.៤៦ | មធ្យម |
| ៥. ការអានយ៉ាងល្អិតល្អន់ ដើម្បីពិនិត្យមើលអត្ថន័យជាក់លាក់របស់អត្ថបទទាំងមូល (Reading for specific information) | ២.៧៣ | ០.៥៩ | មធ្យម |
| ៦. ការអានលម្អិត ដើម្បីធ្វើការវិនិច្ឆ័យលើការយល់ដឹងទៅលើអត្ថបទទាំងមូល (Reading for detailed comprehension) | ២.៨០ | ០.៤១ | មធ្យម |
| សរុប | ២.៧២ | ០.៣៥ | មធ្យម |

តាមរយៈតារាង៤.២ខាងលើបានបង្ហាញថា គ្រូយល់ឃើញថាសិស្សយល់ដឹងទៅលើវិធីសាស្ត្រអានភាសាអង់គ្លេសស្ថិតក្នុងកម្រិតមធ្យមដោយតម្លៃមធ្យម ២.៧២ និងគំលាតស្តង់ដា ០.៣៥។ ក្នុងនោះ បង្ហាញថាសិស្សប្រើការអានលម្អិតដើម្បីធ្វើការវិនិច្ឆ័យលើការយល់ដឹងទៅលើអត្ថបទទាំងមូល (Reading for detailed comprehension) ច្រើនជាងគេ និងយល់ដឹងក្នុងកម្រិតតិចជាងគេគឺអំណានរហ័សសម្រាប់ស្វែងរកគោលគំនិតសំខាន់ (Skimming)។

## ឆ. ការណែនាំសិស្សពីរបៀបប្រើវិធីសាស្ត្រអានភាសាអង់គ្លេស

ក្រាប៤.៦៖ ភាគរយគ្រូដែលបានណែនាំសិស្សពីរបៀបប្រើវិធីសាស្ត្រអានភាសាអង់គ្លេស




តាមរយៈក្រាប៤.៦ ខាងលើបង្ហាញថា គ្រូបង្រៀនទាំងអស់សុទ្ធតែធ្លាប់បានណែនាំសិស្សពីរបៀបប្រើវិធីសាស្ត្រអានភាសាអង់គ្លេស។

## ជ. ការណែនាំរបស់គ្រូពេលសិស្សជួបពាក្យពិបាក

ក្រាប៤.៧៖ ការណែនាំរបស់គ្រូពេលសិស្សជួបពាក្យពិបាក




តាមរយៈក្រាប៤.៧ ខាងលើបានបង្ហាញថានៅពេលសិស្សអានហើយជួបពាក្យពិបាក គ្រូណែនាំឱ្យសិស្សបើកវចនានុក្រមក្នុងកម្រិតញឹកញាប់ជាងគេ(២៣.៤០%) និងមិនធ្លាប់ឱ្យសិស្សរំលងពាក្យដែលពួកគេមិនចេះចោលទេ។

## ឈ. ការណែនាំរបស់គ្រូដើម្បីជំនួយដល់ការយល់ខ្លឹមសារ

ក្រាប៤.៨៖ ការណែនាំរបស់គ្រូដើម្បីជំនួយដល់ការយល់ខ្លឹមសារ




តាមរយៈក្រាប៤.៨ បង្ហាញថាដើម្បីជំនួយដល់ការយល់ខ្លឹមសារអត្ថបទ មានគ្រូ១៣.៣០% បានណែនាំឱ្យសិស្សអានអត្ថបទពេញលេញ ជៀសវាងបាត់អត្ថន័យឬគំនិត មានគ្រូ ២០% ណែនាំឱ្យសិស្សអានលំហាត់ ឬ កិច្ចការដែលត្រូវធ្វើ មានគ្រូ ១៣.៣០% ណែនាំឱ្យសិស្សស្មានពីខ្លឹមសារនៃអត្ថបទតាមរយៈគម្របសៀវភៅរូបភាព និងចំណងជើង មានគ្រូ ២០% ណែនាំឱ្យសិស្សផ្ដោតអារម្មណ៍លើបរិបទនៃអត្ថបទ មានគ្រូ ៨.៩០% ណែនាំឱ្យសិស្សមានការយល់ដឹងលើអ្វីដែលគេកំពុងអាន និងមានគ្រូ ២៤.៤០% ណែនាំសិស្សឱ្យយល់ពីអត្ថន័យនៃពាក្យ ខ្លឹមសារ រូបភាព និងរចនាបថ។ សរុបមក ដើម្បីជួយឱ្យសិស្សយល់ខ្លឹមសារអត្ថបទ គ្រូណែនាំឱ្យសិស្សយល់ពីអត្ថន័យនៃពាក្យ ខ្លឹមសារ រូបភាព និងរចនាបថ ក្នុងកម្រិតច្រើនជាងគេ ក្រៅពីនេះគ្រូណែនាំឱ្យសិស្សផ្ដោតអារម្មណ៍លើបរិបទនៃអត្ថបទ និងអានលំហាត់ ឬកិច្ចការដែលត្រូវធ្វើក្នុងកម្រិតញឹកញាប់ផងដែរ។

## ញ. បញ្ហាដែលសិស្សជួបនៅពេលអាន

ក្រាប៤.៩៖ បញ្ហាដែលសិស្សជួបនៅពេលអាន




តាមរយៈក្រាប៤.៩ ខាងលើបង្ហាញថា នៅពេលអានសិស្សបានជួបបញ្ហាមិនយល់ខ្លឹមសារអត្ថបទ ១៨.២០% មិនដឹងប្រើវិធីសាស្ត្រអានមួយណា២.៣០% មិនមានគោលបំណងក្នុងការអាន ៤.៥០% មិនយល់រចនាសម្ព័ន្ធវេយ្យាករណ៍ ២២.៧០% ការបញ្ចេញសំឡេង ២៥% និងកំណត់ន័យពាក្យពិបាក ២៧.៣០%។ សរុបមក នៅពេលអានសិស្សជួបបញ្ហាក្នុងការកំណត់ន័យពាក្យពិបាកច្រើនជាងគេ បន្ទាប់មកគឺការបញ្ចេញសំឡេង និងមិនយល់ពីរចនាសម្ព័ន្ធវេយ្យាករណ៍។

## ដ. ភាគរយសិស្សដែលទាមទារឱ្យគ្រូបកប្រែអត្ថបទជាភាសាខ្មែរ

ក្រាប៤.១០៖ ភាគរយសិស្សដែលទាមទារឱ្យគ្រូបកប្រែអត្ថបទជាភាសាខ្មែរ



តាមរយៈក្រាប៤.១០ ខាងលើបង្ហាញថា មិនមានសិស្សណាម្នាក់ដែលមិនធ្លាប់ទាមទារឱ្យគ្រូបកប្រែអត្ថបទជាភាសាខ្មែរទេ។ មានសិស្ស ១៣.៣០% ដែលទាមទារឱ្យគ្រូបកប្រែអត្ថបទជាភាសាខ្មែរម្តងម្កាល មានសិស្ស ៦៦.៧០% ទាមទារឱ្យគ្រូបកប្រែអត្ថបទជាភាសាខ្មែរញឹកញាប់ និងមានសិស្ស ២០% ទាមទារឱ្យគ្រូបកប្រែអត្ថបទជាភាសាខ្មែរញឹកញាប់ខ្លាំង។

## ៥. ការណែនាំពីពេលវេលាដែលត្រូវប្រើវចនានុក្រម

ក្រាប៤.១១៖ ការណែនាំពីពេលវេលាដែលត្រូវប្រើវចនានុក្រម




តាមរយៈក្រាប៤.១១ ខាងលើបង្ហាញថា មានគ្រូ ១៦.២០% បានណែនាំសិស្សឱ្យប្រើវចនានុក្រមនៅពេលចង់ផ្ទៀងផ្ទាត់ន័យដែលស្មានរួច មានគ្រូ ២១.៦០% មានគ្រូ ២៧% បានណែនាំសិស្សឱ្យប្រើវចនានុក្រមនៅពេលចង់ដឹងន័យផ្សេងទៀតរបស់ពាក្យ និងមានគ្រូ ៣៥.១០% បានណែនាំសិស្សឱ្យប្រើវចនានុក្រមនៅពេលជួបពាក្យថ្មី។ សរុបមកគ្រូបានណែនាំសិស្សឱ្យប្រើវចនានុក្រមនៅពេលជួបពាក្យថ្មីច្រើនជាងគេ។ បន្ទាប់មក គឺនៅពេលមិនអាចស្មានន័យតាមវិធីផ្សេងៗបាន និងចង់ដឹងន័យផ្សេងទៀតរបស់ពាក្យ។

#### ៤.២.២.២. ទិន្នន័យដែលបានពីសិស្សានុសិស្ស

**ក. កម្រិតនៃការយល់ដឹងលើអំណានរហ័សសម្រាប់ស្វែងរកព័ត៌មានជាក់លាក់ណាមួយ**( Scanning )

តារាង ៤.៣៖ កម្រិតនៃការយល់ដឹងលើអំណានរហ័សសម្រាប់ស្វែងរកព័ត៌មានជាក់លាក់ណាមួយ ( Scanning )

| ខ្លឹមសារវិធីសាស្ត្រអានជាភាសាអង់គ្លេស | មធ្យម | គំលាតស្តង់ដា | កម្រិត |
|---|---|---|---|
| ១. ខ្ញុំជ្រាបគោលបំណងនៃការអាននៅពេលខ្ញុំអានរាល់ពេល | ២.៦៩ | ០.៧៨ | មធ្យម |
| ២. ខ្ញុំពិនិត្យមើលអត្ថបទជាមុនសិន ដោយកត់សម្គាល់អំពីលក្ខណៈពិសេសនៃអត្ថបទដូចជាចំណងជើង រូបភាព ទំហំ និងការរៀបចំ។ | ២.៧៦ | ០.៨១ | មធ្យម |
| ៣. ខ្ញុំធ្វើសញ្ញាដូចជា ការគូសបន្ទាត់ពីក្រោម ឬគូសរង្វង់លើព័ត៌មាននៅក្នុងអត្ថបទ ដើម្បីជួយឱ្យខ្ញុំចងចាំព័ត៌មាននោះ។ | ២.៥៨ | ០.៩៥ | មធ្យម |
| ៤. នៅពេលអត្ថបទលំបាកខ្ញុំបន្ថែមការយកចិត្តទុកដាក់លើអ្វីដែលខ្ញុំកំពុងអាន។ | ២.៥៤ | ០.៨៧ | មធ្យម |
| ៥. ខ្ញុំប្រើប្រាស់លក្ខណៈពិសេសនៃការរៀបចំអត្ថបទ ដូចជាអក្សរដិត និងអក្សរទ្រេត ដើម្បីកំណត់ព័ត៌មានសំខាន់ៗ។ | ២.៧១ | ០.៨៨ | មធ្យម |
| **សរុប** | **២.៦៦** | **០.៧២** | **មធ្យម** |

តាមរយៈតារាង៤.៣ ខាងលើបង្ហាញពីកម្រិតនៃការប្រើវិធីសាស្ត្រអាន Scanning របស់សិស្សមានតម្លៃមធ្យមពី ២.៦៦ ដែលស្ថិតក្នុងកម្រិតមធ្យម។ ក្នុងនោះខ្លឹមសារទី២ មានតម្លៃមធ្យម ២.៧៦ ខ្ពស់ជាងខ្លឹមសារផ្សេងទៀត មានន័យថាក្នុងការអាន Scanning ដើម្បីរកព័ត៌មានជាក់លាក់ណាមួយសិស្សប្រើការសម្គាល់អំពីលក្ខណៈពិសេសនៃអត្ថបទដូចជាចំណងជើង រូបភាព ទំហំ និងការរៀបចំច្រើនជាងគេ។ ចំណែកខ្លឹមសារទី៤ នៅពេលអត្ថបទលំបាកខ្ញុំបន្ថែមការយកចិត្តទុកដាក់លើអ្វីដែលខ្ញុំកំពុងអាន មានតម្លៃមធ្យមទាបជាងគេគឺ ២.៥៤ មានន័យថាក្នុងការអានដើម្បីរកព័ត៌មានជាក់លាក់សិស្សមិនសូវបន្ថែមការយកចិត្តទុកដាក់លើអ្វីដែលពួកគេកំពុងអានទេ។

## ខ. កម្រិតនៃការយល់ដឹងលើអំណានរហ័សសម្រាប់ស្វែងរកគោលគំនិតសំខាន់ ( Skimming )

តារាង ៤.៤៖ កម្រិតនៃការយល់ដឹងលើអំណានរហ័សសម្រាប់ស្វែងរកគោលគំនិតសំខាន់( Skimming )

| ខ្លឹមសារវិធីសាស្ត្រអានជាភាសាអង់គ្លេស | មធ្យម | គំលាតស្តង់ដា | កម្រិត |
|---|---|---|---|
| ៦. ខ្ញុំអានត្រួសៗជាមុន ដើម្បីពិនិត្យមើលថា តើអត្ថបទនោះនឹងទាក់ទងជាមួយអ្វី។ | ២.៦៩ | ០.៨៨ | មធ្យម |
| ៧. នៅពេលដែលអត្ថបទមានការពិបាក ខ្ញុំអានឮៗ ដើម្បីធ្វើឱ្យយល់អំពីអ្វីដែលខ្ញុំអាន។ | ២.៨៨ | ០.៨៨ | មធ្យម |
| ៨. ខ្ញុំវិភាគមើលថា ខ្លឹមសារនៃអត្ថបទដែលខ្ញុំអានត្រូវជាមួយនឹងបំណងនៃការអានរបស់ខ្ញុំដែរឬទេ។ | ២.៩៧ | ០.៨២ | មធ្យម |
| ៩. នៅពេលអាន ខ្ញុំសម្រេចចិត្តលើអ្វីដែលត្រូវអាន ឱ្យបានជិតដល់ និងអ្វីដែលត្រូវរំលងចោល។ | ២.៩២ | ០.៨១ | មធ្យម |
| ១០. ខ្ញុំប្រើប្រាស់តារាងតួលេខ រូបភាពនៅក្នុងអត្ថបទ និងចំណងជើងក្រោមរូបភាព ដើម្បីបង្កើនការយល់ដឹងរបស់ខ្ញុំ។ | ២.៨៩ | ០.៨៩ | មធ្យម |
| **សរុប** | **២.៨៧** | **០.៧១** | **មធ្យម** |

តាមរយៈតារាង៤.៤ខាងលើបង្ហាញថា វិធីសាស្ត្រអាន Skimming ដែលជាអំណានរហ័សសម្រាប់ស្វែងរកគោលគំនិតសំខាន់មានតម្លៃមធ្យម ២.៨៧ ស្ថិតក្នុងកម្រិតមធ្យម។ ខ្លឹមសារទី ៨ មានតម្លៃមធ្យម ២.៩៧ ខ្ពស់ជាងខ្លឹមសារផ្សេងទៀត មានន័យថាក្នុងការអានរហ័សដើម្បីស្វែងរកគោលគំនិតសំខាន់សិស្សវិភាគខ្លឹមសារអត្ថបទដែលត្រូវជាមួយនឹងបំណងនៃការអានរបស់ពួកគេញឹកញាប់ជាងគេ។ ចំណែកខ្លឹមសារទី៦ មានតម្លៃមធ្យម ២.៦៩ ទាបជាងគេ មានន័យថាក្នុងការអាន Skimming សិស្សអានត្រួសៗដើម្បីពិនិត្យមើលថាអត្ថបទនោះទាក់ទងជាមួយអ្វីក្នុងកម្រិតតិចជាងគេ។

## គ. កម្រិតនៃការយល់ដឹងលើការអានដើម្បីស្វែងរកព័ត៌មានមកអះអាងបញ្ជាក់

( Reading to conform information )

តារាង ៤.៥៖ កម្រិតនៃការយល់ដឹងលើការអានដើម្បីស្វែងរកព័ត៌មានមកអះអាងបញ្ជាក់ ( Reading to conform information )

| ខ្លឹមសារវិធីសាស្ត្រអានជាភាសាអង់គ្លេស | មធ្យម | គំលាតស្តង់ដា | កម្រិត |
|---|---|---|---|
| ១១. ខ្ញុំកត់ត្រាខណៈពេលកំពុងអាន ដើម្បីជួយឱ្យយល់អំពីអ្វីដែលខ្ញុំអាន។ | ២.៦០ | ០.៩៥ | មធ្យម |
| ១២. ខ្ញុំគិតដល់អ្វីដែលខ្ញុំបានដឹងរួចហើយ ដើម្បីធ្វើឲ្យយល់អំពីអ្វីដែលខ្ញុំអាន។ | ២.៨៦ | ០.៨១ | មធ្យម |
| ១៣. ខ្ញុំពិនិត្យមើលការយល់ដឹងរបស់ខ្ញុំ នៅពេលខ្ញុំឃើញព័ត៌មានថ្មីៗ។ | ២.៨៤ | ០.៨៨ | មធ្យម |
| ១៤. ខ្ញុំដាក់សំណួរដល់ខ្លួនឯង ដើម្បីស្វែងរកចម្លើយដែលខ្ញុំចង់បាននៅក្នុងអត្ថបទ។ | ២.៩៨ | ០.៨៩ | មធ្យម |
| ១៥. ខ្ញុំពិនិត្យមើលថាតើការប៉ាន់ស្មានរបស់ខ្ញុំ អំពីអត្ថបទដែលអានត្រឹមត្រូវ ឬមិនត្រឹមត្រូវ។ | ២.៨៥ | ០.៨៦ | មធ្យម |
| **សរុប** | **២.៨៤** | **០.៧៥** | **មធ្យម** |

តាមរយៈតារាង៤.៥ ខាងលើបង្ហាញពី Reading to conform information ការប្រើវិធីសាស្ត្រអានដើម្បីស្វែងរកព័ត៌មានមកអះអាងបញ្ជាក់មានតម្លៃមធ្យម ២.៨៤ ស្ថិតក្នុងកម្រិតមធ្យម។ ក្នុងនោះខ្លឹមសារទី១៤ មានតម្លៃមធ្យម ២.៩៨ ខ្ពស់ជាងខ្លឹមសារផ្សេងទៀត មានន័យថាក្នុងការអានដើម្បីស្វែងរកព័ត៌មានមកអះអាងបញ្ជាក់សិស្សប្រើវិធីសាស្ត្រអានដោយដាក់សំណួរដល់ខ្លួនឯងដើម្បីស្វែងរកចម្លើយដែលពួកគេចង់បាននៅក្នុងអត្ថបទក្នុងកម្រិតច្រើនជាងគេ។ ចំណែកខ្លឹមសារទី១១ មានតម្លៃមធ្យម ២.៦០ ទាបជាងគេមានន័យថា សិស្សមិនសូវបានកត់ត្រាខណៈពេលកំពុងអាន ដើម្បីជួយឱ្យយល់អំពីអ្វីដែលពួកគេកំពុងអានទេ។

**ឃ. កម្រិតនៃការយល់ដឹងលើការអានយ៉ាងលម្អិត ដើម្បីឱ្យយល់ពីគំនិតសំខាន់នៃអត្ថបទទាំងមូល** ( Reading for main idea )

តារាង ៤.៦៖ កម្រិតនៃការប្រើការអានយ៉ាងលម្អិតដើម្បីឱ្យយល់ពីគំនិតសំខាន់នៃអត្ថបទទាំងមូល ( Reading for main idea )

| ខ្លឹមសារវិធីសាស្ត្រអានជាភាសាអង់គ្លេស | មធ្យម | គំលាតស្តង់ដា | កម្រិត |
|---|---|---|---|
| ១៦. ខ្ញុំឈប់ម្តងម្កាល រួចគិតអំពីអ្វីដែលខ្ញុំកំពុងអាន។ | ២.៧៦ | ០.៨៤ | មធ្យម |
| ១៧. ខ្ញុំប្រើប្រាស់តម្រុយនៃបរិបទ ដើម្បីជួយខ្ញុំឱ្យយល់កាន់តែប្រសើរអំពីអ្វីដែលខ្ញុំកំពុងអាន។ | ២.៨២ | ០.៨១ | មធ្យម |
| ១៨. ខ្ញុំអានអត្ថបទម្តងហើយម្តងទៀតដើម្បីស្វែងរកទំនាក់ទំនងនៃគំនិតគោលនៅក្នុងអត្ថបទ។ | ២.៦៩ | ០.៨៧ | មធ្យម |
| ១៩. ខ្ញុំព្យាយាមប៉ាន់ស្មានថាតើបរិបទនៃអត្ថបទនិយាយអំពីអ្វីនៅពេលខ្ញុំអាន។ | ២.៧៩ | ០.៨៥ | មធ្យម |
| ២០. នៅពេលអត្ថបទមានការលំបាក ខ្ញុំអានវាឡើងវិញ ដើម្បីបង្កើនការយល់ដឹងរបស់ខ្ញុំ។ | ២.៦៩ | ០.៩៤ | មធ្យម |
| **សរុប** | **២.៧៥** | **០.៧៣** | **មធ្យម** |

តាមរយៈតារាង៤.៦ បង្ហាញថា Reading for main idea វិធីសាស្ត្រអានយ៉ាងលម្អិត ដើម្បីឱ្យយល់ពីគំនិតសំខាន់នៃអត្ថបទទាំងមូល មានតម្លៃមធ្យម ២.៧៥ ស្ថិតក្នុងកម្រិតមធ្យម។ ក្នុងនោះខ្លឹមសារទី១៧ មានតម្លៃមធ្យម ២.៨២ ខ្ពស់គេ មានន័យថា សិស្សប្រើប្រាស់តម្រុយនៃបរិបទ ដើម្បីជួយពួកគេឱ្យយល់កាន់តែប្រសើរអំពីអ្វីដែលពួកគេកំពុងអានក្នុងកម្រិតខ្ពស់ជាងខ្លឹមសារផ្សេងទៀត។ ចំណែកខ្លឹមសារទី១៨ និង២០ មានតម្លៃមធ្យមស្មើគ្នាគឺ ២.៦៩ មានន័យថា សិស្សមិនសូវបានអានអត្ថបទម្តងហើយម្តងទៀត ដើម្បីស្វែងរកទំនាក់ទំនងនៃគំនិតគោលនៅក្នុងអត្ថបទញឹកញាប់ទេ ហើយនៅពេលដែលអត្ថបទមានការលំបាកពួកគេក៏មិនសូវបានអានអត្ថបទឡើងវិញ ដើម្បីបង្កើនការយល់ដឹងដែរ។

**ខ. កម្រិតនៃការប្រើការអានយ៉ាងល្អិតល្អន់ ដើម្បីពិនិត្យមើលអត្ថន័យជាក់លាក់របស់អត្ថបទទាំងមូល** ( Reading for specific information )

តារាង ៤.៧៖ កម្រិតនៃការប្រើការអានយ៉ាងល្អិតល្អន់ ដើម្បីពិនិត្យមើលអត្ថន័យជាក់លាក់របស់អត្ថបទទាំងមូល ( Reading for specific information )

| ខ្លឹមសារវិធីសាស្រ្តអានជាភាសាអង់គ្លេស | មធ្យម | គំលាតស្តង់ដា | កម្រិត |
|---|---|---|---|
| ២១. ខ្ញុំអានយ៉ាងយឺតៗ និងប្រុងប្រយ័ត្នដើម្បីឱ្យប្រាកដថាខ្ញុំយល់អំពីអ្វីដែលខ្ញុំកំពុងអាន។ | ២.៤៤ | ០.៩៥ | ទាប |
| ២២. ខ្ញុំព្យាយាមត្រឡប់មកអានត្រង់កន្លែង ដែលខ្ញុំបានបាត់បង់ការផ្តោតអារម្មណ៍វិញ។ | ២.៤២ | ០.៩១ | ទាប |
| ២៣. ខ្ញុំកែសម្រួលល្បឿនអានរបស់ខ្ញុំ យោងតាមអ្វីដែលខ្ញុំកំពុងអាន។ | ២.៥៧ | ០.៩៧ | មធ្យម |
| ២៤. ខ្ញុំប្រើប្រាស់ឯកសារយោង( ឧទាហរណ៍ វចនានុក្រម ) ដើម្បី ធ្វើឱ្យខ្ញុំចងចាំព័ត៌មាននោះ។ | ២.៣៨ | ១.០៦ | ទាប |
| ២៥. ខ្ញុំព្យាយាមបង្កើតរូបភាព ឬយល់ជារូបភាពអំពីព័ត៌មានដើម្បីជួយឱ្យខ្ញុំចងចាំអំពីអ្វីដែលខ្ញុំអាន។ | ២.៨៣ | ១.០៩ | មធ្យម |
| **សរុប** | **២.៥៣** | **០.៨៤** | **មធ្យម** |

តាមរយៈតារាង៤.៧ខាងលើបង្ហាញថា Reading for specific information ជាការអានយ៉ាងល្អិតល្អន់ ដើម្បីពិនិត្យមើលអត្ថន័យជាក់លាក់របស់អត្ថបទទាំងមូលមានតម្លៃមធ្យម ២.៥៣ ស្ថិតនៅក្នុងកម្រិតមធ្យម។ ក្នុងនោះខ្លឹមសារទី២៥ មានតម្លៃមធ្យម ២.៨៣ ខ្ពស់ជាងតម្លៃមធ្យមផ្សេងទៀត មានន័យថាសិស្សបានព្យាយាមបង្កើតរូបភាព ឬយល់ជារូបភាពអំពីព័ត៌មានដើម្បីជួយឱ្យពួកគេចងចាំអំពីអ្វីដែលពួកគេបានអាន។ ចំណែកខ្លឹមសារទី២១ មានតម្លៃមធ្យម ២.៤៤ ខ្លឹមសារទី២២ មានតម្លៃមធ្យម ២.៤២ និងខ្លឹមសារទី២៤មានតម្លៃមធ្យម ២.៣៨ ស្ថិតក្នុងកម្រិតទាប មានន័យថាសិស្សមិនសូវបានអានយ៉ាងយឺតៗ និងប្រុងប្រយ័ត្នដើម្បីឱ្យប្រាកដថាពួកគេយល់អំពីអ្វីដែលខ្លួនកំពុងអាន មិនសូវបានត្រឡប់មកអានត្រង់

កន្លែងដែលពួកគេបានបាត់បង់ការផ្តោតអារម្មណ៍វិញ និងមិនសូវបានប្រើឯកសារយោង ដូចជាវចនានុក្រម ដើម្បីជួយឱ្យចងចាំព័ត៌មាននោះទេ។

**ច.កម្រិតនៃការប្រើការអានលម្អិតដើម្បីធ្វើការវិនិច្ឆ័យលើការយល់ដឹងទៅលើ អត្ថបទទាំងមូល** ( Reading for Detailed Comprehension )

តារាង ៤.៨៖ កម្រិតនៃការប្រើការអានលម្អិតដើម្បីធ្វើការវិនិច្ឆ័យលើការយល់ដឹងទៅលើអត្ថបទទាំងមូល ( Reading for Detailed Comprehension )

| ខ្លឹមសារវិធីសាស្ត្រអានជាភាសាអង់គ្លេស | មធ្យម | គំលាតស្តង់ដា | កម្រិត |
|---|---|---|---|
| ២៦. ខ្ញុំរៀបរៀងឃ្លា (ដោយប្រើពាក្យពេចន៍ផ្ទាល់របស់ខ្ញុំ) ដើម្បីយល់ដឹងកាន់តែប្រសើរអំពីអ្វីដែលខ្ញុំអាន។ | ២.៧៨ | ០.៨៤ | មធ្យម |
| ២៧. ខ្ញុំវិភាគ និងវាយតម្លៃយ៉ាងល្អិតល្អន់លើព័ត៌មានដែលបង្ហាញនៅក្នុងអត្ថបទ។ | ២.៨៩ | ០.៨៤ | មធ្យម |
| ២៨. នៅពេលណាខ្ញុំអាន ខ្ញុំស្មានអត្ថន័យរបស់ពាក្យ ឬឃ្លាដែលខ្ញុំមិនដឹងជាមុន។ | ២.៧៣ | ០.៨៨ | មធ្យម |
| ២៩. នៅពេលអាន ខ្ញុំបកប្រែពីភាសាអង់គ្លេសជាភាសាខ្មែរ។ | ២.៦៣ | ០.៩៣ | មធ្យម |
| ៣០. នៅពេលអាន ខ្ញុំគិតអំពីអ្វីដែលមានជាភាសាអង់គ្លេស និង ជាភាសាខ្មែរ។ | ២.៧៣ | ០.៩៤ | មធ្យម |
| **សរុប** | **២.៧៥** | **០.៧៥** | **មធ្យម** |

តាមរយៈតារាង៤.៨ខាងលើបង្ហាញថា វិធីសាស្ត្រអាន Reading for Detailed Comprehension ការអានលម្អិតដើម្បីធ្វើការវិនិច្ឆ័យលើការយល់ដឹងទៅលើអត្ថបទទាំងមូលមានតម្លៃមធ្យម ២.៧៥ ស្ថិតក្នុងកម្រិតមធ្យម។ ក្នុងនោះខ្លឹមសារទី២៧ មានតម្លៃមធ្យម ២.៨៩ ខ្ពស់ជាងខ្លឹមសារផ្សេងទៀត មានន័យថាសិស្សវិភាគ និងវាយតម្លៃយ៉ាងល្អិតល្អន់លើព័ត៌មានដែលបង្ហាញនៅក្នុងអត្ថបទញឹកញាប់។ ចំណែកខ្លឹមសារទី២៩ មានតម្លៃមធ្យម ២.៦៣ ទាបជាងគេមានន័យថានៅពេលអានសិស្សមិនសូវបានបកប្រែពីភាសាអង់គ្លេសមកជាភាសាខ្មែរទេ។

តារាង ៤.៩៖ តារាងសរុបទិន្នន័យពីសិស្ស និងគ្រូលើការប្រើវិធីសាស្ត្រទាំង ៦

| ខ្លឹមសារវិធីសាស្ត្រអានជាភាសាអង់គ្លេស | មធ្យមរបស់សិស្ស | មធ្យមរបស់គ្រូ | មធ្យមរួម | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១. អំណាន រហ័សសម្រាប់ស្វែងរកព័ត៌មានជាក់លាក់ណាមួយ( Scanning ) | ២.៦៦ | ២.៧៣ | ២.៦៩ | មធ្យម |
| ២. អំណានរហ័សសម្រាប់ស្វែងរកគោលគំនិតសំខាន់( Skimming ) | ២.៨៧ | ២.៦៦ | ២.៧៦ | មធ្យម |
| ៣. ការអានដើម្បីស្វែងរកព័ត៌មានមកអះអាងបញ្ជាក់( Reading to conform information ) | ២.៨៤ | ២.៦៦ | ២.៧៥ | មធ្យម |
| ៤. ការអានយ៉ាងលម្អិត ដើម្បីឱ្យយល់ពីគំនិតសំខាន់នៃអត្ថបទទាំងមូល( Reading for main idea ) | ២.៧៥ | ២.៧៣ | ២.៧៤ | មធ្យម |
| ៥. ការអានយ៉ាងល្អិតល្អន់ដើម្បីពិនិត្យមើលអត្ថន័យជាក់លាក់របស់អត្ថបទទាំងមូល ( Reading for specific information ) | ២.៥៣ | ២.៧៣ | ២.៦៣ | មធ្យម |
| ៦. ការអានលម្អិត ដើម្បីធ្វើការវិនិច្ឆ័យលើការយល់ដឹងទៅលើអត្ថបទទាំងមូល( Reading for detailed comprehension ) | ២.៧៥ | ២.៨០ | ២.៧៧ | មធ្យម |
| **សរុប** | **២.៧៣** | **២.៧២** | **២.៧២** | **មធ្យម** |

តាមរយៈតារាង៤.៩ បង្ហាញថាទិន្នន័យសរុបដែលបានពីគ្រូ និងសិស្សទៅលើវិធីសាស្ត្រអានទាំង៦ឆ្លើយថា សិស្សមានការយល់ដឹងលើវិធីសាស្ត្រទាំង៦ក្នុងកម្រិតមធ្យម ដោយតម្លៃមធ្យមរួម ២.៧២។ ក្នុងនោះការអានលម្អិត ដើម្បីធ្វើការវិនិច្ឆ័យលើការយល់ដឹងទៅលើអត្ថបទទាំងមូល( Reading for detailed comprehension ) មានមធ្យមភាគ២.៧៧ ខ្ពស់ជាងគេ។ ចំណែកការអានយ៉ាងល្អិតល្អន់ដើម្បីពិនិត្យមើលអត្ថន័យជាក់លាក់របស់អត្ថបទទាំងមូល( Reading for specific information ) មានមធ្យមភាគ ២.៦៣ ទាបជាងគេ។

### ៤.២.២.៣. និន្នន័យបែបគុណវិស័យ

បើតាមការឆ្លើយតបរបស់គ្រូបង្រៀនភាសាអង់គ្លេស និងសិស្សានុសិស្សក៏បានបង្ហាញផងដែរថា ការយល់ដឹងលើវិធីសាស្ត្រអានរបស់សិស្សនៅកម្រិតមធ្យមសិក្សាទុតិយភូមិក្នុងខេត្តតាកែវ មានកម្រិតមធ្យមដោយគ្រូ៩០%បានឆ្លើយថា សិស្សមិនសូវយល់ដឹងទៅលើការប្រើប្រាស់វិធីសាស្ត្រនីមួយៗបានច្បាស់លាស់ទេ។ នៅពេលអានសិស្សមិនសូវយល់ពីវិធីសាស្ត្រដែលត្រូវប្រើ និងមិនអាចរកចម្លើយបានត្រឹមត្រូវគ្រប់សំណួរទេ។ សិស្សមិនសូវបានផ្តោតការយកចិត្តទុកដាក់ទៅលើខ្លឹមសារជាក់លាក់របស់អត្ថបទទាំងមូល និងមិនបានកត់ត្រាពាក្យ ឬខ្លឹមសារសំខាន់ៗសម្រាប់ជំនួយដល់ការចងចាំ និងយល់ខ្លឹមសារ។

ចំពោះសិស្សវិញ តាមរយៈចម្លើយទៅលើការប្រើ Scanning មានសិស្ស ៤៣នាក់ ស្មើនឹង៣៣% ដែលយល់ច្បាស់លាស់ពីការប្រើវិធីសាស្ត្រនេះ មានសិស្ស ៦១នាក់ ស្មើនឹង៤៧% មិនសូវយល់បានច្បាស់លាស់ទេ និងមានសិស្ស២៧នាក់ ស្មើនឹង២០% ដែលមិនយល់ពីការប្រើវិធីសាស្ត្រនេះ។ ចំពោះវិធីសាស្ត្រ Skimming មានសិស្ស ៥១នាក់ ស្មើនឹង៣៩%យល់ច្បាស់ពីការប្រើ Skimming មានសិស្ស ៣២នាក់ ស្មើនឹង២៤%មិនទាន់យល់ច្បាស់ពីការប្រើ និងមានសិស្ស៤៨នាក់ស្មើនឹង ៣៧%មិនទាន់យល់ពីការប្រើនេះទេ។ ចំពោះវិធីសាស្ត្រ Reading to conform information មានសិស្ស៣៣នាក់ ស្មើនឹង២៥% យល់ច្បាស់ពីការប្រើវិធីសាស្ត្រនេះ មានសិស្ស៥៨នាក់ ស្មើនឹង៤៤% យល់មិនសូវច្បាស់ និងមានសិស្ស៤០នាក់ ស្មើនឹង៣១% មិនទាន់យល់ពីការប្រើវិធីសាស្ត្រអានដើម្បីស្វែងរកព័ត៌មានមកអះអាងបញ្ជាក់នេះទេ។ ចំពោះវិធីសាស្ត្រអាន Reading for main idea មានសិស្ស៤៥នាក់ ស្មើនឹង៣៤%យល់ពីការអានយ៉ាងលម្អិតដើម្បីឱ្យយល់ពីគំនិតសំខាន់នៃអត្ថបទទាំងមូលនេះច្បាស់ មានសិស្ស ៤៨នាក់ ស្មើនឹង៣៧% យល់ពីការប្រើវិធីសាស្ត្រនេះតិចតួច និងមានសិស្សចំនួន៣៨នាក់ ស្មើនឹង២៩% មិនទាន់យល់ពីការប្រើវិធីសាស្ត្រនេះទេ។ ចំពោះវិធីសាស្ត្រ . Reading for specific information មានសិស្ស៥០នាក់ ស្មើនឹង៣៨% យល់បានច្បាស់លាស់ទៅលើការប្រើការអានយ៉ាងល្អិតល្អន់ ដើម្បីពិនិត្យមើលអត្ថន័យជាក់លាក់របស់អត្ថបទទាំងមូលនេះ មានសិស្ស៣២នាក់ស្មើនឹង២៥%យល់ដឹងពីការប្រើវិធីសាស្ត្រនេះតិចតួច និងមានសិស្ស

៤៩នាក់ស្មើនឹង៣៧%មិនទាន់យល់ពីការប្រើវិធីសាស្ត្រនេះទេ។ ចំពោះវិធីសាស្ត្រអាន Reading for Detailed Comprehension មានសិស្ស ៤៧នាក់ ស្មើនឹង៣៦% យល់ច្បាស់ពីការប្រើការអានលម្អិតដើម្បីធ្វើការវិនិច្ឆ័យលើការយល់ដឹងទៅលើអត្ថបទទាំងមូលនេះ មានសិស្ស៥៤នាក់ស្មើនឹង៤១%យល់បានតិចតួចទៅលើការប្រើប្រាស់វិធីសាស្ត្រនេះ និងមានសិស្សចំនួន៣០នាក់ស្មើនឹង២៣%មិនទាន់យល់ពីការប្រើវិធីសាស្ត្រអាន Reading for Detailed Comprehension នេះទេ។

### ៤.២.២.៤. ការពិភាក្សាសំណួរស្រាវជ្រាវទី១

សំណួរស្រាវជ្រាវទី១ ៖ តើសិស្សនៅមធ្យមសិក្សាទុតិយភូមិក្នុងខេត្តតាកែវ មានការយល់ដឹងលើការប្រើប្រាស់វិធីសាស្ត្រនៃបំណិនអានភាសាអង់គ្លេសក្នុងកម្រិតណា?

ភាសាអង់គ្លេស គឺជាភាសាអន្តរជាតិមួយ ដែលត្រូវបានកំណត់អោយប្រើប្រាស់ក្នុងបណ្តាញទំនាក់ទំនង ធុរៈកិច្ច និងការងារផ្សេងៗ ក្នុងបណ្តាប្រទេសជាសមាជិកសហគមន៍អាស៊ាន។ បំណិនអានភាសាអង់គ្លេស គឺជាផ្នែកមួយនៃដំណើរការបង្រៀន មុខវិជ្ជាភាសាអង់គ្លេសនៅតាមមធ្យមសិក្សាចំណេះទូទៅ។ ការបង្រៀនមុខវិជ្ជាភាសាអង់គ្លេសគឺផ្តោតលើជំនាញការអាន ជំនាញការសរសេរ ជំនាញការស្តាប់ និងជំនាញការនិយាយ ដោយទាមទារឱ្យផ្តោតលើដំណើរការបង្រៀននៃជំនាញនីមួយៗ ឱ្យកាន់តែមានភាពច្បាស់លាស់ ដើម្បីលើកកម្ពស់កិច្ចវិជ្ជាជីវៈដោយគ្របដណ្តប់ទាំងការងាររដ្ឋបាលសិក្សា វិធីសាស្ត្របង្រៀន និងវង្វាយតម្លៃសិស្សក្នុងថ្នាក់រៀន។ បំណិនអានភាសាអង់គ្លេស ត្រូវគោរពទៅតាមក្របខណ្ឌនៃភាសាវិទ្យា និងបទដ្ឋានជាសាកលមួយលើសូរសៀង ការបញ្ចេញសំឡេងទៅតាមអក្ខរក្រមទាំង២៦តួ ព្រមទាំងពាក្យ និងវេយ្យាករណ៍ក្នុងភាសាអង់គ្លេស។ តាមនិយាមកម្មវិធីសិក្សា មុខវិជ្ជាភាសាអង់គ្លេសតម្រូវឱ្យដំណើរការបង្រៀនចំនួន៣៥សប្តាហ៍ក្នុងមួយឆ្នាំសិក្សាទៅតាមកម្រិតភូមិសិក្សានីមួយៗ។ លទ្ធផលសិក្សារបស់សិស្ស និងវិធីសាស្ត្របង្រៀនរបស់គ្រូមុខវិជ្ជាភាសាអង់គ្លេស គឺជាកត្តាចម្បងក្នុងការធានានូវប្រសិទ្ធភាពថ្នាក់រៀន ព្រមទាំងឆ្លើយតបទៅនឹងគុណភាពសាលារៀនផងដែរ។

ដើម្បីធ្វើការពិភាក្សាទៅលើលទ្ធផលនៃសំណួរស្រាវជ្រាវទី១ អ្នកសិក្សាសូមលើកយកនូវមធ្យមទិន្នន័យឆ្លើយតបរវាងសិស្ស ហើយនិងគ្រូទៅលើវិធីសាស្ត្រនៃបំណិនអានភាសាអង់គ្លេសរបស់សិស្សមកដាក់បញ្ចូលគ្នាដើម្បីរកមធ្យមរួមមួយសម្រាប់ធ្វើការបកស្រាយលទ្ធផលដែលបានរកឃើញ។

តាមរយៈតារាង៤.៩បង្ហាញថា ទិន្នន័យសរុបដែលបានពីគ្រូ និងសិស្សទៅលើវិធីសាស្ត្រអានទាំង៦ឆ្លើយថាការអានលម្អិត ដើម្បីធ្វើការវិនិច្ឆ័យលើការយល់ដឹងទៅលើអត្ថបទទាំងមូល(Reading for detailed comprehension) មានមធ្យមភាគ២.៧៧ ខ្ពស់ជាងគេ។ ចំណែកការអានយ៉ាងល្អិតល្អន់ដើម្បីពិនិត្យមើលអត្ថន័យជាក់លាក់របស់អត្ថបទទាំងមូល(Reading for specific information) មានមធ្យមភាគ ២.៦៣ ទាបជាងគេ។ ចំពោះលទ្ធផលសរុបទាំង៦វិធីសាស្ត្រអានភាសាអង់គ្លេស ទាំងទិន្នន័យរបស់សិស្ស និងទិន្នន័យរបស់គ្រូទទួលបានលទ្ធផលមធ្យមសរុប ២.៧២ មានន័យថាសិស្សនៅមធ្យមសិក្សាទុតិយភូមិក្នុងខេត្តតាកែវ មានការយល់ដឹងលើការប្រើប្រាស់វិធីសាស្ត្រនៃបំណិនអានភាសាអង់គ្លេសក្នុងកម្រិតមធ្យម។

លទ្ធផលដែលធ្វើឱ្យសិស្សនៅមធ្យមសិក្សាទុតិយភូមិក្នុងខេត្តតាកែវ មានការយល់ដឹងលើការប្រើប្រាស់វិធីសាស្ត្រនៃបំណិនអានជាភាសាអង់គ្លេសក្នុងកម្រិតមធ្យមនេះគឺយើងអាចពិនិត្យទៅលើ សូចនាករនីមួយៗនៅក្នុងវិធីសាស្ត្រអានទាំង៦។ តាមរយៈទិន្នន័យតារាង ៤.៩ ខាងលើបង្ហាញថាខ្លឹមសារទី ៥ ដែលផ្តោតទៅលើការអានយ៉ាងល្អិតល្អន់ដើម្បីពិនិត្យមើលអត្ថន័យជាក់លាក់របស់អត្ថបទទាំងមូល(Reading for specific information)ដែលមានមធ្យម ២.៦៣ ស្ថិតក្នុងកម្រិតទាបជាងគេ មានន័យថាសិស្សមិនសូវបានប្រើការអានយ៉ាងល្អិតល្អន់ ដើម្បីពិនិត្យមើលអត្ថន័យជាក់លាក់របស់អត្ថបទទាំងមូល(Reading for specific information)។ អ្នកសិក្សាពិនិត្យទៅលើសូចនាករទាំងអស់របស់វិធីសាស្ត្រអានទី៥នោះឃើញថាខ្លឹមសារទី២១មានមធ្យម ២.៤៤ មានន័យថាក្នុងការអានសិស្សមិនបានអានយ៉ាងយឺតៗ និងប្រុងប្រយ័ត្ន ដើម្បីឱ្យប្រាកដថាពួកគេយល់អ្វីដែលកំពុងអាននោះទេ។ ការអានទាមទារឱ្យអ្នកអានត្រូវមានការយកចិត្តទុកដាក់ និងតាំងចិត្តខ្ពស់ ព្រោះវាក៏អាចជួយអ្នកអានឱ្យចេះវាក្យស័ព្ទ និងមានគំនិតច្រើន ទទួល

បានព័ត៌មានច្រើន ជំនួយដល់សមត្ថភាពនិយាយ និងសមត្ថភាពសរសេរ ព្រមទាំងអាចជួយដល់ការនិយាយភាសាអង់គ្លេសឱ្យកាន់តែប្រសើរ នេះបើយោងតាមសៀវភៅរបស់លោក Patrici L, Carrell, J Devine, DE Eskey ដែលមានចំណងជើងថា Interactive Approaches to Second Languages Reading ក្នុងឆ្នាំ ១៩៩៨។ ហេតុនេះ ដើម្បីឱ្យការអានអាចផ្តល់ចំណេះដឹង ព័ត៌មាន គំនិត និងវាក្យស័ព្ទដល់អ្នកអានបានគ្រប់គ្រាន់ អ្នកអានត្រូវតែផ្តោតយកចិត្តទុកដាក់លើការអានដោយប្រុងប្រយ័ត្នដើម្បីឱ្យយល់ពីអ្វីដែលខ្លួនកំពុងអាន។ ម៉្យាងវិញទៀតនៅក្នុងខ្លឹមសារទី២២ មានមធ្យម ២.៤២ស្ថិតក្នុងកម្រិតទាប មានន័យថា នៅពេលបាត់បង់ការផ្តោតអារម្មណ៍សិស្សមិនបានព្យាយាមត្រឡប់មកអានត្រង់កន្លែងដែលខ្លួនបាត់បង់ការផ្តោតអារម្មណ៍វិញនោះទេ ដែលជាហេតុធ្វើឱ្យសិស្សមិនយល់អត្ថបទ។ គោលបំណងសំខាន់នៃការអានជាភាសាអង់គ្លេស មិនថាជាភាសាទី២(ESL) ឬជាភាសាបរទេស (EFL)គឺការអានដើម្បីរៀន មិនមែនរៀនដើម្បីអាននោះទេ សិស្សត្រូវអានអត្ថបទដើម្បីស្រង់យកខ្លឹមសារសម្រាប់រៀនសូត្រ ទទួលបាននូវប្រធានបទថ្មីៗ គំនិតនៃការពិភាក្សាផ្សេងៗ និងមេរៀនល្អៗផងដែរ ដែលទាំងអស់នោះមានសារៈប្រយោជន៍ ជួយដល់បំណិនសរសេររបស់សិស្សថែមទៀតផង។ នេះបើតាមអត្ថបទបោះពុម្ពផ្សាយរបស់លោក PL Carrell ដែលមានចំណងជើងថា Can reading strategies be successfully taught ក្នុងឆ្នាំ១៩៩៨។ ចំណែកខ្លឹមសារទី២៤ មានមធ្យម ២.៣៨ ស្ថិតក្នុងកម្រិតទាប មានន័យថាក្នុងពេលអាន សិស្សមិនបានប្រើប្រាស់ឯកសារយោង ដើម្បីធ្វើឱ្យចងចាំព័ត៌មាននោះទេ។ អំណានគឺមិនមែនជាបំណិនដែលអកម្មនោះទេ អ្នកអានត្រូវរៀនឱ្យយល់ពីអត្ថន័យនៃពាក្យ ខ្លឹមសារ រូបភាព និងរចនាបថនៃទម្រង់ដែលអ្នកនិពន្ធសរសេរ ដើម្បីជំនួយដល់ការយល់ខ្លឹមសារ និងការចងចាំអត្ថន័យរបស់អត្ថបទឱ្យបានយូរ។ ប្រសិនបើសិស្សមិនបានប្រើឯកសារយោងដើម្បីជំនួយដល់ការចងចាំនោះទេ ពួកគេនឹងភ្លេចព័ត៌មាននោះទៅវិញយ៉ាងឆាប់រហ័ស។ នេះបើតាមគោលការណ៍បង្រៀបអំណានរបស់លោក Jeremy Harmer ឆ្នាំ ២០០២ ដែលសរសេរក្នុងសៀវភៅដែលមានចំណងជើងថា How to teach English។

លទ្ធផលដែលសិស្សទទួលបានពិន្ទុទាបនេះគឺឆ្លុះបញ្ចាំងពីការរៀនរបស់សិស្ស ការបង្រៀនរបស់គ្រូ និងការគ្រប់គ្រងគ្រូលើមុខវិជ្ជាភាសាអង់គ្លេសរបស់សាលារៀននៅមានកម្រិតនៅឡើយ។ សិស្សភាគច្រើនខ្សោយមូលដ្ឋានគ្រឹះផ្នែកភាសាអង់គ្លេសតាំងពីថ្នាក់ក្រោម ដោយសារខ្វះគ្រូភាសាអង់គ្លេសនៅកម្រិតបឋមសិក្សា ហើយសិស្សភាគច្រើនមិនទាន់មានទម្លាប់ក្នុងការអាន។ ការខ្វះមូលដ្ឋានគ្រឹះនេះជាមូលហេតុធ្វើឱ្យសិស្សរៀនខ្សោយ និងមិនចង់រៀនមុខវិជ្ជាភាសាអង់គ្លេស។ ចំណែកការបង្រៀនរបស់គ្រូក៏មានបញ្ហាមួយចំនួនដែរ ដោយសារគ្រូមិនបានប្តូរវិធីសាស្ត្របង្រៀន មិនសូវជំរុញឱ្យសិស្សអាន និងបង្រៀនមិនសូវប្រើសម្ភារឧបទេស ធ្វើឱ្យសិស្សមានអារម្មណ៍ធុញទ្រាន់លើការរៀនភាសាអង់គ្លេសនៅសាលារដ្ឋ។ ចំណែកការគ្រប់គ្រងគ្រូមុខវិជ្ជាភាសាអង់គ្លេសក៏នៅមានកម្រិតដែរ ដោយសារតែគ្រូភាសាអង់គ្លេសមិនដែលបានទទួលការបំប៉នផ្នែកវិធីសាស្ត្របង្រៀន ការចាត់តាំងគ្រូខុសឯកទេសឱ្យទៅបង្រៀនមុខវិជ្ជាភាសាអង់គ្លេស និងការខ្វះខាតឯកសារសម្រាប់អានបន្ថែមនៅក្នុងបណ្ណាល័យ។ តាមរយៈរបាយការណ៍នៅក្នុងសន្និបាតអប់រំឆ្នាំ២០១៤ក៏បានលើកឡើងអំពីបញ្ហាទាំងអស់នេះដែរ នៅក្នុងបញ្ហាប្រឈមត្រង់ចំណុចការងារនៅបឋមសិក្សាគឺខ្វះគ្រូបង្រៀនភាសាអង់គ្លេស ត្រង់ចំណុចកម្មវិធីសិក្សាគឺមិនទាន់បានបំប៉នគ្រូភាសាបរទេសនៅកម្រិតបឋមសិក្សា កង្វះគ្រូជំនាញតាមមុខវិជ្ជាឯកទេសមួយចំនួន កង្វះសម្ភារសិក្សា និងឯកសារសម្រាប់គ្រូស្រាវជ្រាវ ខ្វះសៀវភៅគ្រូគ្រប់មុខវិជ្ជា បណ្ណាល័យភាគច្រើនមិនទាន់សមស្របតាមស្តង់ដា ខ្វះសម្ភាររូបវន្ត និងសៀវភៅសម្រាប់អានបន្ថែម សិស្សភាគច្រើនមិនទាន់មានទម្លាប់ក្នុងការអាន ហើយគណៈគ្រប់គ្រងមួយចំនួនមិនបានជំរុញឱ្យសិស្សចូលបណ្ណាល័យ។ ហេតុនេះ ដើម្បីឱ្យសិស្សាមានសមត្ថភាពអានល្អប្រសើរ ត្រូវមានការចូលរួមពីលោកគ្រូ អ្នកគ្រូ គណៈគ្រប់គ្រង និងសិស្សខ្លួនឯងផ្ទាល់ផងដែរ។ លោកគ្រូ អ្នកគ្រូត្រូវផ្លាស់ប្តូរវិធីសាស្ត្របង្រៀនឱ្យបានច្រើន និងប្រើប្រាស់សម្ភារឧបទេសក្នុងការបង្រៀនដើម្បីទាក់ទាញការចាប់អារម្មណ៍របស់សិស្សឱ្យចង់រៀនឡើងវិញ បង្រៀនមូលដ្ឋានគ្រឹះនៃការរៀនភាសាអង់គ្លេសដល់សិស្ស ជាពិសេសវិធីសាស្ត្រអាន ប្រើអត្ថបទដែលមានភាពទាក់ទាញ និងជំរុញសិស្សឱ្យចូលចិត្តអាន។ ចំណែកគណៈគ្រប់គ្រងត្រូវរៀបចំបណ្ណាល័យឱ្យមានដំណើរការល្អ មានឯកសារសម្រាប់សិស្ស

អាន និងសិក្សាស្រាវជ្រាវគ្រប់គ្រាន់ លើកទឹកចិត្តគ្រូឱ្យប្រើប្រាស់សម្ភារឧបទេសក្នុងការបង្រៀនឱ្យបានទៀងទាត់។ ចំពោះសិស្សវិញត្រូវយកចិត្តទុកដាក់ក្នុងការរៀនសូត្រ បណ្តុះទម្លាប់អាន និងសិក្សាស្រាវជ្រាវបន្ថែមនៅក្នុងបណ្ណាល័យជាប្រចាំ ដោយសិក្សាទៅលើពាក្យថ្មីៗ កត់ត្រាដើម្បីជំនួយការចងចាំ និងហ្វឹកហាត់អានរឿង ឬអត្ថបទផ្សេងៗជាភាសាអង់គ្លេសបន្ថែមដោយខ្លួនឯងនៅផ្ទះ។

### ៤.២.៣. សំណួរស្រាវជ្រាវទី២

សំណួរស្រាវជ្រាវទី២បង្កើតឡើងដើម្បីឆ្លើយតបទៅនឹងគោលបំណងទី២ របស់ការស្រាវជ្រាវដែលចង់ដឹងថាមានភាពដូចគ្នា ឬខុសគ្នាដែរឬទេ ក្នុងការប្រើប្រាស់វិធីសាស្ត្របំណិនអានភាសាអង់គ្លេសរបស់សិស្សនៅកម្រិតមធ្យមសិក្សាទុតិយភូមិក្នុងខេត្តតាកែវ ដោយយោងទៅលើ ភេទ ចំនួនឆ្នាំដែលសិស្សបានរៀនភាសាអង់គ្លេស និងចំនួនម៉ោងដែលពួកគេបានអានភាសាអង់គ្លេស។

ខាងក្រោមនេះ អ្នកសិក្សានឹងធ្វើការបង្ហាញពីលទ្ធផលបានពីការវិភាគទិន្នន័យដែលប្រមូលបានពីភាគសំណាកមកធ្វើការប្រៀបធៀបដោយប្រើកម្មវិធី SPSS និងប្រើកម្មវិធី Excel សម្រាប់សង់តារាង។ ចំពោះការប្រៀបធៀបទៅលើការយល់ដឹងពីវិធីសាស្ត្រដោយយោងទៅលើភេទ អ្នកសិក្សាបានវិភាគតាម Independent-sample t-Test។ ចំណែកការប្រៀបធៀបការយល់ដឹងលើការប្រើប្រាស់វិធីសាស្ត្រអានដោយផ្អែកទៅលើ ចំនួនឆ្នាំដែលសិស្សបានរៀនភាសាអង់គ្លេស អ្នកសិក្សាបានប្រើការវិភាគតាម One Way ANOVA។ ចំពោះការប្រៀបធៀបការប្រើប្រាស់វិធីសាស្ត្របំណិនអានរបស់សិស្សដោយយោងទៅលើចំនួនម៉ោងដែលពួកគេបានអាន អ្នកសិក្សាបានវិភាគតាម Independent-sample t-Test។ លទ្ធផលនៃការវិភាគនឹងត្រូវបានបង្ហាញជាបន្តបន្ទាប់ ដូចខាងក្រោម៖

### ៤.២.៣.១. ការប្រៀបធៀបរវាងសិស្សភេទប្រុស និងសិស្សភេទស្រីទៅលើការប្រើប្រាស់វិធីសាស្ត្រនៃជំណិនអានភាសាអង់គ្លេស

### ក. ការប្រើប្រាស់អំណានរហ័សសម្រាប់ស្វែងរកព័ត៌មានជាក់លាក់ណាមួយ

( Scanning )

តារាង ៤.១០៖ ប្រៀបធៀបរវាងសិស្សភេទប្រុស និងសិស្សភេទស្រីទៅលើការប្រើប្រាស់អំណានរហ័សសម្រាប់ស្វែងរកព័ត៌មានជាក់លាក់ណាមួយ( Scanning )

| ខ្លឹមសារ | ភេទ | | | | t | p- value |
|---|---|---|---|---|---|---|
| | ស្រី(៨៩នាក់) | | ប្រុស(៤២នាក់) | | | |
| | មធ្យម | SD | មធ្យម | SD | | |
| ១. ខ្ញុំជ្រាបគោលបំណងនៃការអាននៅពេលខ្ញុំអានរាល់ពេល។ | ២.៧២ | 0.៨០ | ២.៦៤ | 0.៧៦ | 0.៥២ | 0.៦១ |
| ២. ខ្ញុំពិនិត្យមើលអត្ថបទជាមុនសិនដោយកត់សម្គាល់អំពី លក្ខណៈពិសេសនៃអត្ថបទដូចជាចំណងជើង រូបភាព ទំហំ និង ការរៀបចំ។ | ២.៧៨ | 0.៨៩ | ២.៧៤ | 0.៦៣ | 0.២៨ | 0.៧៩ |
| ៣. ខ្ញុំធ្វើសញ្ញាដូចជា ការគូសបន្ទាត់ពីក្រោម ឬ គូសរង្វង់លើព័ត៌មាននៅក្នុងអត្ថបទ ដើម្បីជួយឱ្យខ្ញុំចងចាំព័ត៌មាននោះ។ | ២.៧៤ | 0.៦៣ | ២.៦២ | 0.៧៦ | -0.៣៦ | 0.៧២ |
| ៤. នៅពេលអត្ថបទលំបាកខ្ញុំបន្ថែមការយកចិត្តទុកដាក់លើអ្វីដែលខ្ញុំកំពុងអាន។ | ២.៥៤ | 0.៩៤ | ២.៥៥ | 0.៧១ | -0.0៥ | 0.៩៦ |
| ៥. ខ្ញុំប្រើប្រាស់លក្ខណៈពិសេសនៃការរៀបចំអត្ថបទ ដូចជា អក្សរដិត និងអក្សរទ្រេត ដើម្បីកំណត់ព័ត៌មានសំខាន់ៗ។ | ២.៧០ | 0.៩៧ | ២.៧៤ | 0.៦៧ | -0.២៩ | 0.៧៨ |
| **សរុប** | **២.៦៦** | **0.៧៩** | **២.៦៦** | **0.៥៤** | **0.0១** | **0.៩៩** |

តាមរយៈតារាង៤.១០ បង្ហាញថាកម្រិតនៃការប្រើប្រាស់ អំណានរហ័សសម្រាប់ស្វែងរកព័ត៌មានជាក់លាក់ណាមួយ( Scanning ) របស់សិស្សប្រុស និងសិស្សស្រីមិនមានភាពខុសប្លែកគ្នាទេ ដោយសារ

តម្លៃ P = 0.៩៩ > 0.0៥។ ក្នុងនោះការយល់ដឹងទៅលើខ្លឹមសារទាំង៥ក៏មិនមានភាពខុសប្លែកគ្នាដែរ ដោយសារតម្លៃ P សុទ្ធតែធំជាង 0.0៥។

**ខ. ការប្រើប្រាស់អំណានរហ័ស សម្រាប់ស្វែងរកគោលគំនិតសំខាន់** (Skimming)

តារាង ៤.១១៖ ប្រៀបធៀបរវាងសិស្សភេទប្រុស និងសិស្សភេទស្រីទៅលើការប្រើប្រាស់អំណានរហ័សសម្រាប់ស្វែងរកគោលគំនិតសំខាន់ (Skimming)

| ខ្លឹមសារ | ភេទ | | | | t | p-value |
|---|---|---|---|---|---|---|
| | ស្រី(៨៩នាក់) | | ប្រុស(៤២នាក់) | | | |
| | មធ្យម | SD | មធ្យម | SD | | |
| ៦. ខ្ញុំអានគ្រួសៗជាមុន ដើម្បីពិនិត្យមើលថា តើអត្ថបទនោះនឹងទាក់ទងជាមួយនឹងអ្វី។ | ២.៦៥ | 0.៩២ | ២.៧៩ | 0.៧៨ | -0.៨២ | 0.៤២ |
| ៧. នៅពេលដែលអត្ថបទមានការពិបាក ខ្ញុំអានឮៗ ដើម្បីធ្វើឲ្យយល់អំពីអ្វីដែលខ្ញុំអាន។ | ២.៧៨ | 0.៩១ | ២.៧៨ | 0.៩១ | ១.៩៧ | 0.0៥ |
| ៨. ខ្ញុំវិភាគមើលថា ខ្លឹមសារនៃអត្ថបទដែលខ្ញុំអានត្រូវជាមួយនឹងបំណងនៃការអានរបស់ខ្ញុំដែរឬទេ។ | ២.៨៩ | 0.៨៧ | ៣.១៤ | 0.៦៨ | ១.៦៧ | 0.១0 |
| ៩. នៅពេលអាន ខ្ញុំសម្រេចចិត្តលើអ្វីដែលត្រូវអានឱ្យបានដិតដល់ និងអ្វីដែលត្រូវរំលងចោល។ | ២.៩៣ | 0.៨៨ | ២.៩0 | 0.៦៩ | 0.១៨ | 0.៨៦ |
| ១0. ខ្ញុំប្រើប្រាស់តារាងតួលេខ រូបភាពនៅក្នុងអត្ថបទ និងចំណងជើងក្រោមរូបភាព ដើម្បីបង្កើនការយល់ដឹងរបស់ខ្ញុំ។ | ២.៩0 | 0.៩៨ | ២.៨៦ | 0.៦៨ | 0.២៨ | 0.៧៨ |
| **សរុប** | **២.៨៣** | **0.៧៧** | **២.៩៦** | **0.៥៦** | **-១.0៧** | **0.២៩** |

តាមរយៈតារាង៤.១១បង្ហាញថា ការប្រើប្រាស់អំណានរហ័សសម្រាប់ស្វែងរកគោលគំនិតសំខាន់ (Skimming) រវាងសិស្សភេទប្រុស និងសិស្សភេទស្រីមិនមានភាពខុសប្លែកគ្នាទេ ដោយសារតែតម្លៃ

P = 0.២៩ > 0.0៥។ ក្នុងនោះ ខ្លឹមសារទី៦ ខ្ញុំអានត្រួសៗជាមុន ដើម្បីពិនិត្យមើលថា តើអត្ថបទនោះនឹងទាក់ទងជាមួយនឹងអ្វីមានតម្លៃ P= 0.៤២ > 0.0៥។ ខ្លឹមសារទី៧ មានតម្លៃ P= 0.0៥។ ខ្លឹមសារទី៨ មានតម្លៃ P= 0.១០ > 0.0៥។ ខ្លឹមសារទី៩ មានតម្លៃ P= 0.៨៦ > 0.0៥។ ខ្លឹមសារទី១០ ដែលឃើញមានតម្លៃ P= 0.៧៩ > 0.0៥។

### គ. ការប្រើប្រាស់វិធីសាស្ត្រអានដើម្បីស្វែងរកព័ត៌មានមកអះអាងបញ្ជាក់ (Reading to conform information)

តារាង ៤.១២៖ ប្រៀបធៀបរវាងសិស្សភេទប្រុស និងសិស្សភេទស្រីទៅលើការប្រើប្រាស់វិធីសាស្ត្រអានដើម្បីស្វែងរកព័ត៌មានមកអះអាងបញ្ជាក់ (Reading to conform information)

| ខ្លឹមសារ | ភេទ | | | | t | p-value |
|---|---|---|---|---|---|---|
| | ស្រី(៨៩នាក់) | | ប្រុស(៤២នាក់) | | | |
| | មធ្យម | SD | មធ្យម | SD | | |
| ១១. ខ្ញុំកត់ត្រា ខណៈពេលកំពុងអានដើម្បីជួយឱ្យយល់ អំពីអ្វីដែលខ្ញុំអាន។ | ២.៥៥ | 0.៩៩ | ២.៧១ | 0.៨៦ | -0.៩២ | 0.៣៦ |
| ១២. ខ្ញុំគិតដល់អ្វីដែលខ្ញុំបានដឹងរួចហើយដើម្បីធ្វើឱ្យយល់អំពីអ្វីដែលខ្ញុំអាន។ | ២.៨៣ | 0.៩១ | ២.៩៣ | 0.៥៦ | -0.៦៤ | 0.៥៣ |
| ១៣. ខ្ញុំពិនិត្យមើលការយល់ដឹងរបស់ខ្ញុំ នៅពេលខ្ញុំឃើញព័ត៌មានថ្មីៗ។ | ២.៨0 | 0.៩៤ | ២.៩៣ | 0.៧១ | -0.៨៨ | 0.៣៨ |
| ១៤. ខ្ញុំដាក់សំណួរដល់ខ្លួនឯង ដើម្បីស្វែងរកចម្លើយដែលខ្ញុំចង់បាននៅក្នុងអត្ថបទ។ | ៣.0៨ | ១.២៨ | ៣.00 | 0.៦៦ | 0.៤៦ | 0.៦៤ |
| ១៥. ខ្ញុំពិនិត្យមើលថាតើការប៉ាន់ស្មានរបស់ខ្ញុំអំពីអត្ថបទដែលអានត្រឹមត្រូវ ឬ មិនត្រឹមត្រូវ។ | ២.៨0 | 0.៩៣ | ២.៩៨ | 0.៦៨ | -១.២៣ | 0.២១ |
| **សរុប** | **២.៨១** | **0.៨៤** | **២.៩១** | **0.៥៣** | **-0.៨២** | **0.៤២** |

តាមរយៈតារាង៤.១២បង្ហាញថា ការប្រើប្រាស់វិធីសាស្ត្រអានដើម្បីស្វែងរកព័ត៌មានមកអះអាងបញ្ជាក់ (Reading to conform information) របស់សិស្សភេទប្រុស និងសិស្សភេទស្រីមិនមានភាពខុស

ប្លែកគ្នាទេ ដោយតម្លៃ P = 0.៤២ > 0.0៥។ ក្នុងនោះខ្លឹមសារទាំងអស់សុទ្ធតែមានតម្លៃ P > 0.0៥ ទាំងអស់ តែបើពិនិត្យទៅលើខ្លឹមសារទី១១ អ្នកសិក្សាឃើញថាតម្លៃមធ្យមរបស់សិស្សភេទស្រីទាបជាងតម្លៃមធ្យមរបស់សិស្សភេទប្រុស (២.៥៥ < ២.៧១) មានន័យថាក្នុងការកត់ត្រាខណៈពេលកំពុងអាន ដើម្បីជួយឱ្យយល់អំពីអ្វីខ្លួនអានរវាងសិស្សស្រី និងសិស្សប្រុសមានភាពខុសប្លែកគ្នាដោយសិស្សស្រីមានការយល់ដឹងទាបជាងសិស្សប្រុសលើការកត់ត្រាខណៈពេលកំពុងអានដើម្បីជួយឱ្យយល់ពីអ្វីដែលខ្លួនអាន។

### ឃ. ការប្រើប្រាស់វិធីសាស្ត្រនៃការអានយ៉ាងលម្អិត ដើម្បីឱ្យយល់ពីគំនិតសំខាន់នៃអត្ថបទទាំងមូល (Reading for main idea)

តារាង ៤.១៣៖ ប្រៀបធៀបរវាងសិស្សភេទប្រុស និងសិស្សភេទស្រីទៅលើការប្រើប្រាស់វិធីសាស្ត្រនៃការអានយ៉ាងលម្អិត ដើម្បីឱ្យយល់ពីគំនិតសំខាន់នៃអត្ថបទទាំងមូល (Reading for main idea)

| ខ្លឹមសារ | ភេទ | | | | t | p-value |
|---|---|---|---|---|---|---|
| | ស្រី(៨៩នាក់) | | ប្រុស(៤២នាក់) | | | |
| | មធ្យម | SD | មធ្យម | SD | | |
| ១៦. ខ្ញុំឈប់ម្តងម្កាល រួចគិតអំពីអ្វីដែលខ្ញុំកំពុងអាន។ | ២.៧៤ | 0.៨៩ | ២.៨១ | 0.៧៤ | -0.៤៣ | 0.៦៧ |
| ១៧. ខ្ញុំប្រើប្រាស់តម្រុយនៃបរិបទដើម្បីជួយខ្ញុំឱ្យយល់កាន់តែប្រសើរអំពីអ្វីដែលខ្ញុំកំពុងអាន។ | ២.៧៨ | 0.៩១ | ២.៩0 | 0.៥៣ | -១.0១ | 0.៣១ |
| ១៨. ខ្ញុំអានអត្ថបទម្តងហើយម្តងទៀត ដើម្បីស្វែងរកទំនាក់ទំនងនៃគំនិតគោលនៅក្នុងអត្ថបទ។ | ២.៦៣ | 0.៩២ | ២.៨៣ | 0.៧៦ | -១.៣៣ | 0.១៩ |
| ១៩. ខ្ញុំព្យាយាមប៉ាន់ស្មានថា តើបរិបទនៃអត្ថបទនិយាយអំពីអ្វី នៅពេលខ្ញុំអាន។ | ២.៧៥ | 0.៩0 | ២.៨៦ | 0.៧៥ | -0.៦៥ | 0.៥១ |
| ២0. នៅពេលអត្ថបទមានការលំបាកខ្ញុំអានវាឡើងវិញដើម្បីបង្កើនការយល់ដឹងរបស់ខ្ញុំ។ | ២.៥៨ | 0.៩៩ | ២.៩៣ | 0.៨១ | -២.១១ | 0.0៤ |

| | | | | | | |
|---|---|---|---|---|---|---|
| សរុប | ២.៦៩ | ០.៨១ | ២.៨៦ | ០.៥៣ | -១.៤៤ | ០.១៥ |

តាមតារាង៤.១៣ បង្ហាញថាការប្រើប្រាស់វិធីសាស្ត្រអានយ៉ាងលម្អិត ដើម្បីឱ្យយល់ពីគំនិតសំខាន់នៃអត្ថបទទាំងមូល (Reading for main idea) រវាងសិស្សភេទប្រុស និងសិស្សភេទស្រីមិនមានភាពខុសប្លែកគ្នាទេ ដោយតម្លៃ P = ០.១៥ > ០.០៥។ ក្នុងនោះ ខ្លឹមសារទី ២០ មានតម្លៃ P = ០.០៤ < ០.០៥ ដោយតម្លៃមធ្យមរបស់សិស្សស្រីទាបជាងតម្លៃមធ្យមរបស់សិស្សប្រុស ( ២.៥៨ < ២.៩៣)មានន័យថា នៅពេលអត្ថបទមានការលំបាក សិស្សស្រីមានការយល់ដឹងទាបជាងសិស្សប្រុស សិស្សស្រីមិនសូវបានអានអត្ថបទឡើងវិញដើម្បីបង្កើនការយល់ដឹងរបស់ខ្លួនទេ។ ក្រៅពីនេះខ្លឹមសារទី១៨ក៏សិស្សភេទស្រីមានតម្លៃមធ្យមទាបជាងសិស្សភេទប្រុសដែរ (២.៦៣ < ២.៨៣) មានន័យថាសិស្សភេទស្រីមិនសូវបានអានអត្ថបទម្តងហើយម្តងទៀត ដើម្បីស្វែងរកទំនាក់ទំនងនៃគំនិតគោលនៅក្នុងអត្ថបទញឹកញាប់ដូចសិស្សប្រុសទេ។

## ខ. ការប្រើប្រាស់វិធីសាស្ត្រអានយ៉ាងល្អិតល្អន់ ដើម្បីពិនិត្យមើលអត្ថន័យជាក់លាក់របស់អត្ថបទទាំងមូល (Reading for specific information)

តារាង ៤.១៤៖ ប្រៀបធៀបរវាងសិស្សភេទប្រុស និងសិស្សភេទស្រីទៅលើការប្រើប្រាស់វិធីសាស្ត្រអានយ៉ាងល្អិតល្អន់ ដើម្បីពិនិត្យមើលអត្ថន័យជាក់លាក់របស់អត្ថបទទាំងមូល (Reading for specific information)

| ខ្លឹមសារ | ភេទ | | | | t | p-value |
|---|---|---|---|---|---|---|
| | ស្រី(៨៩នាក់) | | ប្រុស(៤២នាក់) | | | |
| | មធ្យម | SD | មធ្យម | SD | | |
| ២១. ខ្ញុំអានយ៉ាងយឺតៗនិងប្រុងប្រយ័ត្ន ដើម្បីឱ្យប្រាកដថា ខ្ញុំយល់អំពីអ្វីដែលខ្ញុំកំពុងអាន។ | ២.៤២ | ១.០៣ | ២.៥០ | ០.៧៧ | -០.៤៧ | ០.៦៤ |
| ២២. ខ្ញុំព្យាយាមត្រឡប់មកអានត្រង់កន្លែង ដែលខ្ញុំបានបាត់បង់ការផ្តោតអារម្មណ៍វិញ។ | ២.៣៨ | ០.៩៥ | ២.៥០ | ០.៨៣ | -០.៦៩ | ០.៤៩ |

| | | | | | | |
|---|---|---|---|---|---|---|
| ២៣. ខ្ញុំកែសម្រួលល្បឿនអានរបស់ខ្ញុំ យោងតាមអ្វីដែលខ្ញុំកំពុងអាន។ | ២.៥៧ | ០.៩៩ | ២.៥៧ | ០.៩៤ | ០.0១ | ០.៩៩ |
| ២៤. ខ្ញុំប្រើប្រាស់ឯកសារយោង (ឧទាហរណ៍ វចនានុក្រម) ដើម្បីធ្វើឱ្យខ្ញុំចងចាំព័ត៌មាននោះ។ | ២.៣៥ | ១.១១ | ២.៤៥ | ០.៩៤ | -០.៥៣ | ០.៦០ |
| ២៥. ខ្ញុំព្យាយាមបង្កើតរូបភាព ឬយល់ជារូបភាពអំពីព័ត៌មាន ដើម្បីជួយឱ្យខ្ញុំចងចាំអំពីអ្វីដែលខ្ញុំអាន។ | ២.៩៣ | ១.១៦ | ២.៦២ | ០.៨៨ | ១.៥៦ | ០.១២ |
| **សរុប** | **២.៥៣** | **០.៨៨** | **២.៥២** | **០.៧៥** | **០.0១** | **០.៩៩** |

តាមតារាង៤.១៤បង្ហាញថាការប្រើប្រាស់វិធីសាស្ត្របំណិនអានយ៉ាងល្អិតល្អន់ ដើម្បីពិនិត្យមើលអត្ថន័យជាក់លាក់របស់អត្ថបទទាំងមូល (Reading for specific information) រវាងសិស្សភេទប្រុស និងសិស្សភេទស្រីមិនមានភាពខុសប្លែកគ្នាទេដោយតម្លៃ P = ០. ៩៩ > 0.0៥។ ក្នុងនោះបើពិនិត្យទៅលើខ្លឹមសារទី២៥ អ្នកសិក្សាឃើញថា តម្លៃមធ្យមរបស់សិស្សភេទស្រីធំជាងតម្លៃមធ្យមរបស់សិស្សភេទប្រុស (២.៩៣ >២.៦២) មានន័យថាក្នុងការព្យាយាមបង្កើតរូបភាព ឬយល់ជារូបភាពអំពីព័ត៌មាន ដើម្បីជួយឱ្យចងចាំអំពីអ្វីដែលខ្ញុំអាន សិស្សស្រីមានការយល់ដឹងខ្ពស់ជាងសិស្សប្រុស។

## ច. ការប្រើប្រាស់វិធីសាស្ត្រអានលម្អិតដើម្បីធ្វើការវិនិច្ឆ័យលើការយល់ដឹងទៅលើអត្ថបទទាំងមូល (Reading for Detailed Comprehension )

តារាង ៤.១៥៖ ប្រៀបធៀបរវាងសិស្សភេទប្រុស និងសិស្សភេទស្រីទៅលើការប្រើប្រាស់វិធីសាស្ត្រអានលម្អិតដើម្បីធ្វើការវិនិច្ឆ័យលើការយល់ដឹងទៅលើអត្ថបទទាំងមូល(Reading for Detailed Comprehension)

| ខ្លឹមសារ | ភេទ | | | | t | p-value |
|---|---|---|---|---|---|---|
| | ស្រី(៨៩នាក់) | | ប្រុស(៤២នាក់) | | | |
| | មធ្យម | SD | មធ្យម | SD | | |
| ២៦. ខ្ញុំរៀបរៀងឃ្លា (ដោយប្រើពាក្យពេចន៍ផ្ទាល់របស់ខ្ញុំ) ដើម្បីយល់ដឹងកាន់តែប្រសើរអំពីអ្វីដែលខ្ញុំអាន។ | ២.៧២ | ០.៩០ | ២.៩០ | ០.៦៦ | -១.៣៣ | ០.១៩ |

| | | | | | | |
|---|---|---|---|---|---|---|
| ២៧. ខ្ញុំវិភាគ និងវាយតម្លៃយ៉ាងល្អិតល្អន់លើព័ត៌មានដែលបង្ហាញនៅក្នុងអត្ថបទ។ | ២.៨៩ | ០.៩១ | ២.៨៨ | ០.៦៧ | ០.០៤ | ០.៩៧ |
| ២៨. នៅពេលណាខ្ញុំអាន ខ្ញុំស្មានអត្ថន័យរបស់ពាក្យ ឬឃ្លាដែលខ្ញុំមិនដឹងជាមុន។ | ២.៦៤ | ០.៩២ | ២.៩៣ | ០.៧៥ | -១.៩១ | ០.០៦ |
| ២៩. នៅពេលអាន ខ្ញុំបកប្រែពីភាសាអង់គ្លេសជាភាសាខ្មែរ។ | ២.៥២ | ០.៩៦ | ២.៨៨ | ០.៨៣ | -២.២២ | ០.០៣ |
| ៣០. នៅពេលអាន ខ្ញុំគិតអំពីអ្វីដែលមានជាភាសាអង់គ្លេស និងជាភាសាខ្មែរ។ | ២.៦៦ | ០.៩៩ | ២.៨៨ | ០.៧៧ | -១.៣៦ | ០.១៧ |
| **សរុប** | **២.៦៨** | **០.៧៨** | **២.៨៩** | **០.៦២** | **-១.៥០** | **០.១៣** |

តាមតារាង៤.១៥បង្ហាញថា ការប្រើប្រាស់វិធីសាស្ត្រអានលម្អិតដើម្បីធ្វើការវិនិច្ឆ័យលើការយល់ដឹងទៅលើអត្ថបទទាំងមូល (Reading for Detailed Comprehension ) រវាងសិស្សភេទប្រុស និងសិស្សភេទស្រីមានលក្ខណៈមិនខុសប្លែកគ្នាទេ ដោយតម្លៃ P = ០.១៣ > 0.0៥។ ក្នុងនោះ ខ្លឹមសារទី២៩ មានតម្លៃ P = 0. ០៣ < 0.0៥ ដោយសារលទ្ធផលតម្លៃមធ្យមរបស់សិស្សស្រីទាបជាងតម្លៃមធ្យមរបស់សិស្សប្រុស (២.៥២ < ២.៨៨) មានន័យថានៅពេលអានសិស្សប្រុសបកប្រែពីភាសាអង់គ្លេសជាភាសាខ្មែរច្រើនជាងសិស្សស្រី។ មួយវិញទៀតក្នុងខ្លឹមសារទី២៨ និងខ្លឹមសារទី៣០ តម្លៃមធ្យមរបស់សិស្សស្រីទាបជាងតម្លៃមធ្យមរបស់សិស្សប្រុស(២.៦៤ <២.៩៣ និង ២.៦៦ < ២.៨៨) មានន័យថានៅពេលអានសិស្សភេទប្រុសស្មានអត្ថន័យរបស់ពាក្យ ឬឃ្លាដែលមិនដឹងជាមុន និងគិតអំពីអ្វីដែលមានជាភាសាអង់គ្លេស និងជាភាសាខ្មែរច្រើនជាងសិស្សភេទស្រី។

## ឆ. ការប្រើប្រាស់វិធីសាស្ត្រអានទាំង៦

តារាង ៤.១៦៖ ប្រៀបធៀបរវាងសិស្សភេទស្រី និងសិស្សភេទប្រុសទៅលើការប្រើប្រាស់វិធីសាស្ត្របំណិនអានភាសាអង់គ្លេសទាំង៦

| ខ្លឹមសារ | ភេទ | | | | t | p-value |
|---|---|---|---|---|---|---|
| | ស្រី(៨៩នាក់) | | ប្រុស(៤២នាក់) | | | |
| | មធ្យម | SD | មធ្យម | SD | | |
| ១. អំណាន រហ័សសម្រាប់ស្វែងរកព័ត៌មានជាក់លាក់ណាមួយ (Scanning) | ២.៦៦ | ០.៧៩ | ២.៦៦ | ០.៥៤ | ០.០១ | ០.៩៩ |
| ២. អំណានរហ័សសម្រាប់ស្វែងរកគោលគំនិតសំខាន់(Skimming) | ២.៨៣ | ០.៧៧ | ២.៩៦ | ០.៥៦ | -១.០៧ | ០.២៩ |
| ៣. ការអានដើម្បីស្វែងរកព័ត៌មានមកអះអាងបញ្ជាក់(Reading to conform information) | ២.៨១ | ០.៨៤ | ២.៩១ | ០.៥៣ | -០.៨២ | ០.៤២ |
| ៤. ការអានយ៉ាងលម្អិត ដើម្បីឱ្យយល់ពីគំនិតសំខាន់នៃអត្ថបទទាំងមូល (Reading for main idea) | ២.៦៩ | ០.៨១ | ២.៨៦ | ០.៥៣ | -១.៤៤ | ០.១៥ |
| ៥. ការអានយ៉ាងល្អិតល្អន់ដើម្បីពិនិត្យមើលអត្ថន័យជាក់លាក់របស់អត្ថបទទាំងមូល(Reading for specific information) | ២.៥៣ | ០.៨៨ | ២.៥២ | ០.៧៥ | ០.០១ | ០.៩៩ |
| ៦. ការអានលម្អិត ដើម្បីធ្វើការវិនិច្ឆ័យលើការយល់ដឹងទៅលើអត្ថបទទាំងមូល(Reading for detailed comprehension ) | ២.៦៨ | ០.៨០ | ២.៨៩ | ០.៦២ | -១.៥០ | ០.១៣ |

| | | | | | | |
|---|---|---|---|---|---|---|
| សរុប | ២.៧០ | ០.៧៥ | ២.៨០ | ០.៤៧ | -០.៩៣ | ០.៣៥ |

តាមរយៈតារាង៤.១៦ បង្ហាញថាការប្រើប្រាស់វិធីសាស្ត្របំណិនអានភាសាអង់គ្លេសទាំង៦ រវាងសិស្សភេទប្រុស និងសិស្សភេទស្រីជារួមមិនមានភាពខុសប្លែកគ្នាទេ ដោយតម្លៃ P = 0.៣៥ > 0.0៥។ ក្នុងនោះវិធីសាស្ត្រទាំងអស់សុទ្ធតែមានតម្លៃ P > 0.0៥ ទាំងអស់ ប៉ុន្តែបើពិនិត្យទៅលើតម្លៃមធ្យមលើវិធីសាស្ត្រអានទី៤ ការអានយ៉ាងលម្អិត ដើម្បីឱ្យយល់ពីគំនិតសំខាន់នៃអត្ថបទទាំងមូល (Reading for main idea) និងវិធីសាស្ត្រអានទី៦ ការអានលម្អិត ដើម្បីធ្វើការវិនិច្ឆ័យលើការយល់ដឹងទៅលើអត្ថបទទាំងមូល (Reading for detailed comprehension) តម្លៃមធ្យមរបស់សិស្សភេទស្រី និងសិស្សភេទប្រុសមានភាពខុសគ្នា។ ដោយលទ្ធផលតម្លៃមធ្យមរបស់សិស្សភេទស្រី ទាបជាងតម្លៃមធ្យមរបស់សិស្សភេទប្រុស (២.៦៩ < ២.៨៦ និង ២.៦៨ < ២.៨៩) មានន័យថារវាងសិស្សភេទស្រី និងសិស្សភេទប្រុសមានការយល់ដឹងទៅលើវិធីសាស្ត្រអានយ៉ាងលម្អិត ដើម្បីឱ្យយល់ពីគំនិតសំខាន់នៃអត្ថបទទាំងមូល (Reading for main idea) និងការអានលម្អិតដើម្បីធ្វើការវិនិច្ឆ័យលើការយល់ដឹងទៅលើអត្ថបទទាំងមូល (Reading for detailed comprehension)មានភាពខុសប្លែកគ្នា ដោយសិស្សស្រីមានការយល់ដឹងទៅលើវិធីសាស្ត្រអានទាំងពីរនេះទាបជាងសិស្សភេទប្រុស។

សរុបមក ការប្រៀបធៀបរវាងសិស្សភេទស្រី និងសិស្សភេទប្រុសទៅលើការប្រើប្រាស់វិធីសាស្ត្រនៃបំណិនអានភាសាអង់គ្លេសទាំង៦ នៅកម្រិតមធ្យមសិក្សាទុតិយភូមិក្នុងខេត្តតាកែវជារួមឃើញថា មិនមានភាពខុសប្លែកគ្នាទេដោយតម្លៃ P = 0. ៣៥ > 0.0៥។ បើពីនិត្យទៅលើមធ្យមភាគការប្រើប្រាស់វិធីសាស្ត្រចំនួន៤មិនមានការប្រែប្រួលទេគឺអំណានរហ័សសម្រាប់ស្វែងរកព័ត៌មានជាក់លាក់ណាមួយ(Scanning) អំណានរហ័សសម្រាប់ស្វែងរកគោលគំនិតសំខាន់ (Skimming) ការអានដើម្បីស្វែងរកព័ត៌មានមកអះអាងបញ្ជាក់(Reading to conform information) និងការអានយ៉ាងល្អិតល្អន់ដើម្បីពិនិត្យមើលអត្ថន័យជាក់លាក់របស់អត្ថបទទាំងមូល(Reading for specific information) ហើយក៏មានវិធីសាស្ត្រចំនួន

២ដែលមានមធ្យមភាគប្រែប្រួលតិចតួច គឺការអានយ៉ាងលម្អិត ដើម្បីឱ្យយល់ពីគំនិតសំខាន់នៃអត្ថបទទាំងមូល (Reading for main idea) និងការអានលម្អិតដើម្បីធ្វើការវិនិច្ឆ័យលើការយល់ដឹងទៅលើអត្ថបទទាំងមូល( Reading for detailed comprehension )។

### ៤.២.៣.២. ការប្រៀបធៀបការយល់ដឹងលើវិធីសាស្ត្របំណិនអានភាសាអង់គ្លេសរបស់សិស្សដោយយោងទៅតាមចំនួនឆ្នាំដែលពួកគេបានរៀនភាសាអង់គ្លេស

តារាង ៤.១៧៖ ការប្រៀបធៀបការយល់ដឹងលើវិធីសាស្ត្របំណិនអានភាសាអង់គ្លេសរបស់សិស្សដោយយោងទៅតាមចំនួនឆ្នាំដែលពួកគេបានរៀនភាសាអង់គ្លេស

| ខ្លឹមសារ | រយៈពេល | មធ្យម | គំលាតស្តង់ដា | ការប្រែប្រួល | Sum of Square | d f | Mean Square | F | P |
|---|---|---|---|---|---|---|---|---|---|
| ១. Scanning | តិចជាង៣ឆ្នាំ២៣នាក់ | ២.៥៨ | ០.៨១ | ចន្លោះក្រុម | ០.២៦ | ២ | ០.១៣ | ០.២៤ | ០.៧៨ |
| | ៣ទៅ៥ឆ្នាំ ៦៧នាក់ | ២.៦៥ | ០.៦៥ | ក្នុងក្រុម | ៦៧ | ១២៨ | ០.៥២ | | |
| | ច្រើនជាង៥ឆ្នាំ៤១នាក់ | ២.៧១ | ០.៧៨ | សរុប | ០.២៤ | ១៣០ | | | |
| ២. Skimming | តិចជាង៣ឆ្នាំ២៣នាក់ | ២.៧២ | ០.៧៦ | ចន្លោះក្រុម | ១.៣២ | ២ | ០.៦៦ | ១.៣១ | ០.២៧ |
| | ៣ទៅ៥ឆ្នាំ ៦៧នាក់ | ២.៨៤ | ០.៦៦ | ក្នុងក្រុម | ៦៥ | ១២៨ | ០.៥០ | | |
| | ច្រើនជាង៥ឆ្នាំ៤១នាក់ | ៣.០០ | ០.៧៧ | សរុប | ៦៦ | ១៣០ | | | |
| ៣. Reading To Confirm Information | តិចជាង៣ឆ្នាំ២៣នាក់ | ២.៧៧ | ០.៨៨ | ចន្លោះក្រុម | ០.១៩ | ២ | ០.១០ | ០.១៧ | ០.៨៤ |
| | ៣ទៅ៥ឆ្នា ៦៧នាក់ | ២.៨៤ | ០.៦៧ | ក្នុងក្រុម | ៧៣ | ១២៨ | ០.៥៧ | | |
| | ច្រើនជាង៥ឆ្នាំ៤១នាក់ | ២.៨៩ | ០.៨២ | សរុប | ៧៣ | ១៣០ | | | |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ៤. Reading For Main Idea | តិចជាង៣ ឆ្នាំ២៣នាក់ | ២.៥៥ | 0.៨៦ | ចន្លោះ ក្រុម | ១.៥១ | ២ | 0.៧៦ | ១.៤២ | 0.២៤ |
| | ៣ទៅ៥ឆ្នាំ ៦៧នាក់ | ២.៧៥ | 0.៦៣ | ក្នុងក្រុម | ៦៨ | ១២៨ | 0.៥៣ | | |
| | ច្រើនជាង៥ ឆ្នាំ៤១នាក់ | ២.៨៧ | 0.៨១ | សរុប | ៧0 | ១៣0 | | | |
| ៥. Reading For Specific Information | តិចជាង៣ ឆ្នាំ២៣នាក់ | ២.៤៦ | .៩៣ | ចន្លោះ ក្រុម | 0.៣៧ | ២ | 0.១៩ | 0.២៦ | 0.៧៧ |
| | ៣ទៅ៥ឆ្នាំ ៦៧នាក់ | ២.៥១ | 0.៧៣ | ក្នុងក្រុម | ៩១ | ១២៨ | 0.៧១ | | |
| | ច្រើនជាង៥ ឆ្នាំ៤១នាក់ | ២.៦0 | 0.៩៥ | សរុប | ៩១ | ១៣0 | | | |
| ៦. Reading For Detailed Comprehension | តិចជាង៣ ឆ្នាំ២៣នាក់ | ២.៥៩ | 0.៨៥ | ចន្លោះ ក្រុម | 0.៨៤ | ២ | 0.៤២ | 0.៧៥ | 0.៤៧ |
| | ៣ទៅ៥ឆ្នាំ ៦៧នាក់ | ២.៧៦ | 0.៦៤ | ក្នុងក្រុម | ៧២ | ១២៨ | 0.៥៦ | | |
| | ច្រើនជាង៥ ឆ្នាំ៤១នាក់ | ២.៨៣ | 0.៨៥ | សរុប | ៧៣ | ១៣0 | | | |
| សរុប | តិចជាង៣ ឆ្នាំ២៣នាក់ | ២.៦១ | 0.៧៩ | ចន្លោះ ក្រុម | 0.៦៣ | ២ | 0.៣២ | 0.៦៩ | 0.៥0 |
| | ៣ទៅ៥ឆ្នាំ ៦៧នាក់ | ២.៧២ | 0.៥៩ | ក្នុងក្រុម | ៥៨ | ១២៨ | 0.៤៦ | | |
| | ច្រើនជាង៥ ឆ្នាំ៤១នាក់ | ២.៨២ | 0.៧៤ | សរុប | ៥៩ | ១៣0 | | | |

តាមតារាង៤.១៧ខាងលើបង្ហាញថា ការយល់ដឹងលើវិធីសាស្ត្របំណិនអានភាសាអង់គ្លេសរបស់សិស្សដោយយោងទៅតាមចំនួនឆ្នាំដែលពួកគេបានរៀនភាសាអង់គ្លេសជារួមមិនមានភាពខុសប្លែកគ្នាទេ ដោយសារតម្លៃ P = 0.៥0 > 0.0៥ ប៉ុន្តែបើយើងមើលទៅលើមធ្យមភាគរវាងសិស្សដែលរៀនភាសា

អង់គ្លេសតិចជាង៣ឆ្នាំ សិស្សដែលរៀនភាសាអង់គ្លេសពី៣ទៅ៥ឆ្នាំ និងសិស្សដែលរៀនភាសាអង់គ្លេសច្រើនជាង៥ឆ្នាំឃើញថាមានការប្រែប្រួលគ្រប់វិធីសាស្ត្រទាំងអស់ ដោយសិស្សដែលរៀនភាសាអង់គ្លេសច្រើនជាង៥ឆ្នាំមានមធ្យមភាគខ្ពស់ជាងគេ បន្ទាប់មកគឺសិស្សដែលរៀនភាសាអង់គ្លេសពី៣ទៅ៥ឆ្នាំ ហើយសិស្សដែលរៀនភាសាអង់គ្លេសតិចជាង៣ឆ្នាំមានមធ្យមភាគទាបជាងគេ (២.៦១ < ២.៧២ < ២.៨២)។ មធ្យមភាគដែលប្រែប្រួលទាំងនេះមានន័យថាសិស្សដែលរៀនភាសាអង់គ្លេសច្រើនឆ្នាំមានការយល់ដឹងទៅលើ ការប្រើប្រាស់ វិធីសាស្ត្រនៃបំណិនអានភាសាអង់គ្លេសច្រើនជាងសិស្សដែលរៀនភាសាអង់គ្លេសតិចឆ្នាំ ប៉ុន្តែការយល់ដឹងនេះមានការប្រែប្រួលបន្តិចបន្តួចប៉ុណ្ណោះ ដោយសារតម្លៃមធ្យមមានការប្រែប្រួលបន្តិចបន្តួចពីក្រុមសិស្សដែលរៀនភាសាអង់គ្លេសតិចជាង៣ឆ្នាំ ទៅក្រុមសិស្សដែលរៀនភាសាអង់គ្លេសពី៣ទៅ៥ឆ្នាំ និងទៅក្រុមសិស្សដែលរៀនភាសាអង់គ្លេសច្រើនជាង៥ឆ្នាំ។

### ៤.២.៣.៣. ការប្រៀបធៀបការយល់ដឹងពីវិធីសាស្ត្របំណិនអានភាសាអង់គ្លេសរបស់សិស្សយោងទៅតាមចំនួនម៉ោងដែលពួកគេបានអានភាសាអង់គ្លេស

### ក. ការយល់ដឹងពីវិធីសាស្ត្រអំណានរហ័សសម្រាប់ស្វែងរកព័ត៌មានជាក់លាក់ណាមួយ (Scanning)

តារាង ៤.១៨៖ ការយល់ដឹងទៅលើអំណានរហ័សសម្រាប់ស្វែងរកព័ត៌មានជាក់លាក់ណាមួយ (Scanning) យោងទៅតាមចំនួនម៉ោងដែលសិស្សអាន

| ខ្លឹមសារ | ចំនួនម៉ោងដែលបានអានភាសាអង់គ្លេស | | | | t | p-value |
|---|---|---|---|---|---|---|
| | តិចជាង១ម៉ោង (៣៥នាក់) | | ពី១ទៅ២ម៉ោង (៩៦នាក់) | | | |
| | M | SD | M | SD | | |
| ១. ខ្ញុំជ្រាបគោលបំណងនៃការអាននៅពេលខ្ញុំអានរាល់ពេល។ | ២.៤៩ | 0.៦១ | ២.៧៧ | 0.៨៣ | -១.៨៦ | 0.0៧ |
| ២. ខ្ញុំពិនិត្យមើលអត្ថបទជាមុនសិនដោយកត់សម្គាល់អំពី លក្ខណៈ | ២.៤៩ | 0.៦៦ | ២.៨៦ | 0.៨៤ | -២.៤១ | 0.0២ |

| | | | | | | |
|---|---|---|---|---|---|---|
| ពិសេសនៃអត្ថបទដូចជាចំណងជើង រូបភាព ទំហំ និងការរៀបចំ។ | | | | | | |
| ៣. ខ្ញុំធ្វើសញ្ញាដូចជា ការគូសបន្ទាត់ពីក្រោម ឬ គូសរង្វង់លើ ព័ត៌មាននៅក្នុងអត្ថបទ ដើម្បីជួយឱ្យខ្ញុំចងចាំព័ត៌មាននោះ។ | ២.៣៤ | ០.៨០ | ២.៦៧ | ០.៩៩ | -១.៧៤ | ០.០៩ |
| ៤. នៅពេលអត្ថបទលំបាកខ្ញុំបន្ថែមការយកចិត្តទុកដាក់លើអ្វីដែលខ្ញុំកំពុងអាន។ | ២.៣៤ | ០.៧៧ | ២.៦១ | ០.៩០ | -១.៥៩ | ០.១១ |
| ៥. ខ្ញុំប្រើប្រាស់លក្ខណៈពិសេសនៃការរៀបចំអត្ថបទ ដូចជាអក្សរដិត និងអក្សរទ្រេត ដើម្បីកំណត់ព័ត៌មានសំខាន់ៗ។ | ២.៤០ | ០.៩៨ | ២.៨២ | ០.៨២ | -២.២៩ | ០.០៣ |
| **សរុប** | **២.៤១** | **០.៥៩** | **២.៧៥** | **០.៧៥** | **-២.៤១** | **០.០២** |

តាមរយៈតារាង៤.១៨ បង្ហាញថា ការយល់ដឹងពីវិធីសាស្ត្រ អំណានរហ័សសម្រាប់ស្វែងរកព័ត៌មានជាក់លាក់ណាមួយ (Scanning) ដោយយោងទៅតាមចំនួនម៉ោងដែលសិស្សអានភាសាអង់គ្លេសក្នុងមួយថ្ងៃ មានលក្ខណៈខុសប្លែកគ្នា ដោយតម្លៃ P = 0. 0២ < 0.0៥។ ដោយចំនួនម៉ោងដែលសិស្សអាន ពី ១ម៉ោង ទៅ២ម៉ោងក្នុងមួយថ្ងៃ មានតម្លៃមធ្យម ២.៧៥ > ២.៤១ ដែលជាតម្លៃមធ្យមរបស់សិស្សដែលចំណាយពេលអានតិចជាង ១ម៉ោងក្នុងមួយថ្ងៃ មានន័យថាសិស្សដែលចំណាយពេលអានពី ១ទៅ២ម៉ោងក្នុងមួយថ្ងៃមានការយល់ដឹងពីវិធីសាស្ត្រអានច្រើនជាងសិស្សដែលចំណាយពេលអាន Scanning តិចជាង ១ម៉ោងក្នុងមួយថ្ងៃ។

## ខ. ការយល់ដឹងពីវិធីសាស្ត្រអំណានរហ័ស សម្រាប់ស្វែងរកគោលគំនិតសំខាន់ (Skimming)

តារាង ៤.១៩៖ ការយល់ដឹងពីវិធីសាស្ត្រអំណានរហ័ស សម្រាប់ស្វែងរកគោលគំនិតសំខាន់ (Skimming) យោងទៅតាមចំនួនម៉ោងដែលសិស្សអាន

| ខ្លឹមសារ | ចំនួនម៉ោងដែលបានអានភាសាអង់គ្លេស | | | | t | p-value |
|---|---|---|---|---|---|---|
| | តិចជាង១ម៉ោង៣៥ នាក់ | | ពី១ទៅ២ម៉ោង៩៦ នាក់ | | | |
| | M | SD | M | SD | | |
| ៦. ខ្ញុំអានត្រួសៗជាមុន ដើម្បីពិនិត្យមើលថា តើអត្ថបទ នោះនឹងទាក់ទងជាមួយនឹងអ្វី។ | ២.៤០ | ០.៧៨ | ២.៨០ | ០.៨៩ | -២.៣៧ | ០.០២ |
| ៧. នៅពេលដែលអត្ថបទមានការពិបាក ខ្ញុំអានឮៗដើម្បីធ្វើឲ្យយល់អំពីអ្វីដែលខ្ញុំអាន។ | ២.៦៦ | ០.៨៧ | ២.៩៦ | ០.៨៧ | -១.៧៥ | ០.០៨ |
| ៨. ខ្ញុំវិភាគមើលថា ខ្លឹមសារនៃអត្ថបទដែលខ្ញុំអានត្រូវជាមួយនឹងបំណងនៃការអាន របស់ ខ្ញុំដែរឬទេ។ | ២.៧១ | ០.៨៣ | ៣.០៦ | ០.៨១ | -២.១៨ | ០.០៣ |
| ៩. នៅពេលអាន ខ្ញុំសម្រេចចិត្តលើអ្វីដែលត្រូវអានឱ្យបានជិតដល់ និងអ្វីដែលត្រូវរំលងចោល។ | ២.៨៣ | ០.៨២ | ២.៩៦ | ០.៨២ | -០.៨០ | ០.៤៣ |
| ១០. ខ្ញុំប្រើប្រាស់តារាងតួលេខ រូបភាពនៅក្នុងអត្ថបទ និង ចំណងជើងក្រោមរូបភាព ដើម្បីបង្កើនការយល់ដឹងរបស់ខ្ញុំ។ | ២.៦៦ | ០.៨៤ | ២.៩៧ | ០.៩០ | -១.៧៩ | ០.០៨ |
| **សរុប** | **២.៦៥** | **០.៦៦** | **២.៩៥** | **០.៧២** | **-២.១៥** | **០.០៣** |

តាមរយៈតារាង៤.១៩បង្ហាញថា ការយល់ដឹងពីវិធីសាស្ត្រអំណានរហ័សសម្រាប់ស្វែងរកគោលគំនិតសំខាន់ (Skimming) ដោយយោងទៅតាមចំនួនម៉ោងដែលសិស្សអានមានលក្ខណៈខុសប្លែកគ្នាដោយសារតម្លៃ P = 0.0៣ < 0.0៥។ ដោយសារសិស្សដែលអាន ពី១ម៉ោង ទៅ២ម៉ោងមានតម្លៃមធ្យម ២.៩៥ > ២.៦៥ ដែលជាតម្លៃមធ្យមរបស់សិស្សដែលចំណាយពេលអានតិចជាង១ម៉ោងក្នុងមួយថ្ងៃមានន័យថាសិស្សដែលចំណាយពេលអានពី១ទៅ២ម៉ោងក្នុងមួយថ្ងៃមានការយល់ដឹងពីវិធីសាស្ត្រអាន Skimming ច្រើនជាងសិស្សដែលចំណាយពេលអានតិចជាង ១ម៉ោងក្នុងមួយថ្ងៃ។

**គ. ការយល់ដឹងពីវិធីសាស្ត្រអានដើម្បីស្វែងរកព័ត៌មានមកអះអាងបញ្ជាក់** (Reading to conform information)

តារាង ៤.២០៖ ការយល់ដឹងពីវិធីសាស្ត្រ អានដើម្បីស្វែងរកព័ត៌មានមកអះអាងបញ្ជាក់ (Reading to conform information) យោងទៅតាមចំនួនម៉ោងដែលសិស្សអាន

| ខ្លឹមសារ | ចំនួនម៉ោងដែលបានអានភាសាអង់គ្លេស | | | | t | p-value |
|---|---|---|---|---|---|---|
| | តិចជាង១ម៉ោង (៣៥នាក់) | | ពី១ទៅ២ម៉ោង (៩៦នាក់) | | | |
| | M | SD | M | SD | | |
| ១១. ខ្ញុំកត់ត្រា ខណៈពេលកំពុងអានដើម្បីជួយឱ្យយល់អំពីអ្វីដែលខ្ញុំអាន។ | ២.៣១ | 0.៨0 | ២.៧១ | 0.៩៨ | -២.១៣ | 0.0៤ |
| ១២. ខ្ញុំគិតដល់អ្វីដែលខ្ញុំបានដឹងរួចហើយ ដើម្បីធ្វើឲ្យយល់អំពីអ្វីដែលខ្ញុំអាន។ | ២.៦៦ | 0.៦៨ | ២.៩៤ | 0.៨៤ | -១.៧៧ | 0.0៨ |
| ១៣. ខ្ញុំពិនិត្យមើលការយល់ដឹងរបស់ខ្ញុំ នៅពេលខ្ញុំឃើញព័ត៌មានថ្មីៗ។ | ២.៤៣ | 0.៧៤ | ២.៩៩ | 0.៨៨ | -៣.៣៧ | 0.00 |
| ១៤. ខ្ញុំដាក់សំណួរដល់ខ្លួនឯង ដើម្បីស្វែងរកចម្លើយដែលខ្ញុំចង់បាននៅក្នុងអត្ថបទ។ | ២.៧៧ | 0.៨១ | ៣.0៥ | 0.៩១ | -១.៦១ | 0.១១ |

| | | | | | | |
|---|---|---|---|---|---|---|
| ១៥. ខ្ញុំពិនិត្យមើលថាតើការប៉ាន់ស្មានរបស់ខ្ញុំអំពីអត្ថបទដែលអានត្រឹមត្រូវ ឬ មិនត្រឹមត្រូវ។ | ២.៤៣ | ០.៦៦ | ៣.០១ | ០.៨៨ | -៣.៥៨ | 0.00 |
| **សរុប** | **២.៥២** | **០.៥៨** | **២.៩៦** | **០.៧៧** | **-៣.០៧** | **0.00** |

តាមរយៈតារាង៤.២០ បង្ហាញថា ការយល់ដឹងពីវិធីសាស្ត្រអានដើម្បីស្វែងរកព័ត៌មានមកអះអាងបញ្ជាក់ (Reading to conform information) យោងទៅតាមចំនួនម៉ោងដែលសិស្សអានភាសាអង់គ្លេសមានភាពខុសប្លែកគ្នា ដោយតម្លៃ P = 0. 00៣ < 0.0៥។ ដោយចំនួនម៉ោងដែលសិស្សអាន ពី១ម៉ោង ទៅ២ម៉ោងក្នុងមួយថ្ងៃ មានតម្លៃមធ្យម ២.៩៦ > ២.៥២ ដែលជាតម្លៃមធ្យមរបស់សិស្សដែលចំណាយពេលអានតិចជាង១ម៉ោងក្នុងមួយថ្ងៃមានន័យថា សិស្សដែលចំណាយពេលអានពី ១ម៉ោងទៅ២ម៉ោងក្នុងមួយថ្ងៃមានការយល់ដឹងពីវិធីសាស្ត្រអានដើម្បីស្វែងរកព័ត៌មានមកអះអាងបញ្ជាក់ (Reading to conform information) ច្រើនជាងសិស្សដែលចំណាយពេលអានតិចជាង ១ម៉ោងក្នុងមួយថ្ងៃ។

**ឃ. ការយល់ដឹងពីវិធីសាស្ត្រអានយ៉ាងលម្អិត ដើម្បីឱ្យយល់ពីគំនិតសំខាន់នៃអត្ថបទទាំងមូល** (Reading for main idea)

តារាង ៤.២១៖ ការយល់ដឹងពីវិធីសាស្ត្រអានយ៉ាងលម្អិត ដើម្បីឱ្យយល់ពីគំនិតសំខាន់នៃអត្ថបទទាំងមូល (Reading for main idea) តាមចំនួនម៉ោងដែលសិស្សអាន

| **ខ្លឹមសារ** | **ចំនួនម៉ោងដែលបានអានភាសាអង់គ្លេស** | | | | t | p-value |
|---|---|---|---|---|---|---|
| | **តិចជាង១ម៉ោង (៣៥នាក់)** | | **ពី១ទៅ២ម៉ោង (៩៦នាក់)** | | | |
| | M | SD | M | SD | | |
| ១៦. ខ្ញុំឈប់មួងម្កាល រួចគិតអំពីអ្វីដែលខ្ញុំកំពុងអាន។ | ២.៦៣ | ០.៦៥ | ២.៨១ | ០.៩០ | -១.១១ | ០.២៧ |
| ១៧. ខ្ញុំប្រើប្រាស់តម្រុយនៃបរិបទដើម្បីជួយខ្ញុំឱ្យយល់កាន់តែប្រសើរអំពីអ្វីដែលខ្ញុំកំពុងអាន។ | ២.៦០ | ០.៧៨ | ២.៩០ | ០.៨១ | -១.៨៦ | ០.០៧ |

| | | | | | | |
|---|---|---|---|---|---|---|
| ១៨. ខ្ញុំអានអត្ថបទម្តងហើយម្តងទៀត ដើម្បីស្វែងរកទំនាក់ទំនងនៃគំនិតគោលនៅក្នុងអត្ថបទ។ | ២.៤៩ | 0.៨២ | ២.៧៧ | 0.៨៩ | -១.៦៦ | 0.១០ |
| ១៩. ខ្ញុំព្យាយាមប៉ាន់ស្មានថា តើបរិបទនៃអត្ថបទនិយាយអំពីអ្វី នៅពេលខ្ញុំអាន។ | ២.៤០ | 0.៨៨ | ២.៩៣ | 0.៨0 | -៣.២៥ | 0.00 |
| ២០. នៅពេលអត្ថបទមានការលំបាក ខ្ញុំអានវាឡើងវិញ ដើម្បីបង្កើនការយល់ដឹងរបស់ខ្ញុំ។ | ២.៤៩ | 0.៩២ | ២.៧៧ | 0.៩៥ | -១.៥៤ | 0.១៣ |
| **សរុប** | **២.៥២** | **0.៦៣** | **២.៨៤** | **0.៧៥** | **-២.២២** | **0.0៣** |

តាមរយៈតារាង៤.២១ បង្ហាញថាការយល់ដឹងពីវិធីសាស្ត្រអានយ៉ាងលម្អិត ដើម្បីឱ្យយល់ពីគំនិតសំខាន់នៃអត្ថបទទាំងមូល (Reading for main idea) យោងទៅតាមចំនួនម៉ោងដែលសិស្សអានភាសាអង់គ្លេសក្នុង១ថ្ងៃមានលក្ខណៈខុសប្លែកគ្នា ដោយសារតែយើងឃើញតម្លៃ P = 0. 0៣ < 0.05។ ដោយចំនួនម៉ោងដែលសិស្សអាន ពី១ម៉ោង ទៅ២ម៉ោង មានតម្លៃមធ្យម ២.៨៤ > ២.៥២ ដែលជាតម្លៃមធ្យមរបស់សិស្សដែលចំណាយពេលអាន តិចជាង១ម៉ោងក្នុងមួយថ្ងៃ មានន័យថាសិស្សដែលចំណាយពេលអានដោយប្រើរយៈពេលពី១ទៅ២ម៉ោងក្នុងមួយថ្ងៃមានការយល់ដឹងពីវិធីសាស្ត្រអាន Reading for Main idea ច្រើនជាងសិស្សដែលចំណាយពេលអានតិចជាង១ម៉ោងក្នុងមួយថ្ងៃ។

**ខ. ការយល់ដឹងពីវិធីសាស្ត្រអានយ៉ាងល្អិតល្អន់ ដើម្បីពិនិត្យមើលអត្ថន័យជាក់លាក់របស់អត្ថបទទាំងមូល** (Reading for specific information)

តារាង ៤.២២៖ ការយល់ដឹងពីវិធីសាស្ត្រអានយ៉ាងល្អិតល្អន់ ដើម្បីពិនិត្យមើលអត្ថន័យជាក់លាក់របស់អត្ថបទទាំងមូល (Reading for specific information) Reading for Specific Information យោងទៅតាមចំនួនម៉ោងដែលសិស្សអាន

| ខ្លឹមសារ | ចំនួនម៉ោងដែលបានអានភាសាអង់គ្លេស | | | | t | p-value |
|---|---|---|---|---|---|---|
| | តិចជាង១ម៉ោង (៣៥នាក់) | | ពី១ទៅ២ម៉ោង (៩៦នាក់) | | | |
| | M | SD | M | SD | | |
| ២១. ខ្ញុំអានយ៉ាងយឺតៗនិងប្រុងប្រយ័ត្ន ដើម្បីឱ្យប្រាកដថាខ្ញុំយល់អំពីអ្វីដែលខ្ញុំកំពុងអាន។ | ២.០៦ | ០.៨០ | ២.៥៨ | ០.៩៧ | -២.៨៧ | ០.0១ |
| ២២. ខ្ញុំព្យាយាមត្រឡប់មកអានត្រង់កន្លែង ដែលខ្ញុំបានបាត់បង់ការផ្តោតអារម្មណ៍វិញ។ | ២.១៤ | ០.៩១ | ២.៥២ | ០.៨៩ | -២.១៣ | ០.0៤ |
| ២៣. ខ្ញុំកែសម្រួលល្បឿនអានរបស់ខ្ញុំយោងតាមអ្វីដែលខ្ញុំកំពុងអាន។ | ២.២០ | ០.៩០ | ២.៧១ | ០.៩៦ | -២.៧២ | ០.0១ |
| ២៤. ខ្ញុំប្រើប្រាស់ឯកសារយោង (ឧទាហរណ៍ វចនានុក្រម)ដើម្បីធ្វើឱ្យខ្ញុំចងចាំព័ត៌មាននោះ | ១.៩១ | ០.៩២ | ២.៥៥ | ១.0៦ | -៣.១៦ | 0.00 |
| ២៥. ខ្ញុំព្យាយាមបង្កើតរូបភាព ឬយល់ជារូបភាពអំពីព័ត៌មាន ដើម្បីជួយឱ្យខ្ញុំចងចាំអំពីអ្វីដែលខ្ញុំអាន។ | ២.៤៦ | ១.១២ | ២.៩៧ | ១.0៤ | -២.៤៤ | 0.0២ |
| **សរុប** | **២.១៥** | **០.៧៧** | **២.៦៧** | **០.៨៣** | **-៣.២០** | **0.00** |

តាមរយៈតារាង៤.២២បង្ហាញថា ការយល់ដឹងពីវិធីសាស្ត្រអានយ៉ាងល្អិតល្អន់ ដើម្បីពិនិត្យមើលអត្ថន័យជាក់លាក់របស់អត្ថបទទាំងមូល (Reading for specific information) យោងទៅតាមចំនួនម៉ោងដែលសិស្សអានភាសាអង់គ្លេសមានលក្ខណៈខុសប្លែកគ្នា ដោយតម្លៃ P = 0.00 < 0.0៥។ ដោយចំនួនម៉ោងដែលសិស្សអាន ពី១ម៉ោង ទៅ ២ម៉ោងក្នុងមួយថ្ងៃមានតម្លៃមធ្យម ២.៦៧ > ២.១៥ ដែលជាតម្លៃមធ្យមរបស់សិស្សដែលចំណាយពេលអានតិចជាង ១ម៉ោងក្នុងមួយថ្ងៃ មានន័យថាសិស្សដែលចំណាយពេលអានពី ១ម៉ោង ទៅ២ម៉ោងក្នុងមួយថ្ងៃមានការយល់ដឹងពីវិធីសាស្ត្រអានយ៉ាងល្អិតល្អន់ ដើម្បីពិនិត្យមើលអត្ថន័យជាក់លាក់របស់អត្ថបទទាំងមូល (Reading for specific information) ច្រើនជាងសិស្សដែលចំណាយពេលអានតិចជាង ១ម៉ោងក្នុងមួយថ្ងៃ។

**ច. ការយល់ដឹងពីវិធីសាស្ត្រអានលម្អិតដើម្បីធ្វើការវិនិច្ឆ័យលើការយល់ដឹងទៅលើអត្ថបទទាំងមូល** ( Reading for Detailed Comprehension )

តារាង ៤.២៣៖ ការយល់ដឹងពីវិធីសាស្ត្រអានលម្អិតដើម្បីធ្វើការវិនិច្ឆ័យលើការយល់ដឹងទៅលើ អត្ថបទទាំងមូល ( Reading for Detailed Comprehension ) យោងទៅតាមចំនួនម៉ោងដែលសិស្សអាន

| ខ្លឹមសារ | ចំនួនម៉ោងដែលបានអានភាសាអង់គ្លេស | | | | t | p-value |
|---|---|---|---|---|---|---|
| | តិចជាង១ម៉ោង (៣៥នាក់) | | ពី១ទៅ២ម៉ោង (៩៦នាក់) | | | |
| | M | SD | M | SD | | |
| ២៦. ខ្ញុំរៀបរៀងឃ្លា (ដោយប្រើពាក្យពេចន៍ផ្ទាល់របស់ខ្ញុំ) ដើម្បីយល់ដឹងកាន់តែប្រសើរអំពីអ្វីដែលខ្ញុំអាន។ | ២.៣៤ | ០.៨០ | ២.៩៤ | ០.៧៩ | -៣.៧៩ | 0.00 |
| ២៧. ខ្ញុំវិភាគ និងវាយតម្លៃយ៉ាងល្អិតល្អន់លើព័ត៌មានដែលបង្ហាញនៅក្នុងអត្ថបទ។ | ២.៥៧ | ០.៨៨ | ៣.00 | ០.៨០ | -២.៦៥ | ០.0១ |
| ២៨. នៅពេលណាខ្ញុំអាន ខ្ញុំស្មានអត្ថន័យរបស់ពាក្យ ឬឃ្លាដែលខ្ញុំមិនដឹងជាមុន។ | ២.៣៤ | ០.៨៧ | ២.៨៨ | ០.៨៤ | -៣.១៩ | ០.00 |
| ២៩. នៅពេលអាន ខ្ញុំបកប្រែពីភាសាអង់គ្លេសជាភាសាខ្មែរ។ | ២.៤៩ | ០.៨២ | ២.៦៩ | ០.៩៧ | -១.១០ | ០.២៧ |
| ៣០. នៅពេលអាន ខ្ញុំគិតអំពីអ្វីដែលមានជាភាសាអង់គ្លេស និងជាភាសាខ្មែរ។ | ២.៤៩ | ០.៨៩ | ២.៨២ | ០.៩៤ | -១.៨៤ | ០.0៧ |
| **សរុប** | **២.៤៥** | **០.៧១** | **២.៨៦** | **០.៧៤** | **-២.៩២** | **០.00** |

តាមតារាង៤.២៣បង្ហាញថា ការយល់ដឹងពីវិធីសាស្ត្រអានលម្អិតដើម្បីធ្វើការវិនិច្ឆ័យលើការយល់ដឹងទៅលើអត្ថបទទាំងមូល ( Reading for Detailed Comprehension ) យោងទៅតាមចំនួនម៉ោងដែលសិស្សអានភាសាអង់គ្លេសមានភាពខុសប្លែកគ្នា ដោយតម្លៃ P = 0.00 < 0.0៥។ ដោយចំនួនម៉ោងដែលសិស្សអាន ពី១ម៉ោងទៅ២ម៉ោងក្នុងមួយថ្ងៃ មានតម្លៃមធ្យម ២.៨៦ > ២.៤៥ ដែលជាតម្លៃមធ្យមរបស់សិស្សដែលចំណាយពេលអានតិចជាង ១ម៉ោងក្នុងមួយថ្ងៃ មានន័យថាសិស្សដែលចំណាយពេលអានពី ១

ទៅ២ម៉ោងក្នុងមួយថ្ងៃមានការយល់ដឹងពីវិធីសាស្ត្រអានលម្អិតដើម្បីធ្វើការវិនិច្ឆ័យលើការយល់ដឹងទៅលើអត្ថបទទាំងមូល ច្រើនជាងសិស្សដែលចំណាយពេលអានតិចជាង ១ម៉ោងក្នុងមួយថ្ងៃ។

## ឆ. ការយល់ដឹងពីវិធីសាស្ត្រអានទាំង ៦

តារាង ៤.២៤៖ ការយល់ដឹងពីវិធីសាស្ត្រអានទាំង៦ យោងទៅតាមចំនួនម៉ោងដែលសិស្សអាន

| ខ្លឹមសារ | ចំនួនម៉ោងដែលបានអានភាសាអង់គ្លេស | | | | t | p-value |
|---|---|---|---|---|---|---|
| | តិចជាង១ម៉ោង (៣៥នាក់) | | ពី១ទៅ២ម៉ោង (៩៦នាក់) | | | |
| | M | SD | M | SD | | |
| ១. អំណានរហ័សសម្រាប់ស្វែងរកព័ត៌មានជាក់លាក់ណាមួយ (Scanning) | ២.៤១ | ០.៥៩ | ២.៧៥ | ០.៧៥ | -២.៤១ | ០.០២ |
| ២. អំណានរហ័សសម្រាប់ស្វែងរកគោលគំនិតសំខាន់(Skimming) | ២.៦៥ | ០.៦៦ | ២.៩៥ | ០.៧២ | -២.១៥ | ០.០៣ |
| ៣. ការអានដើម្បីស្វែងរកព័ត៌មានមកអះអាងបញ្ជាក់(Reading to conform information) | ២.៥២ | ០.៥៨ | ២.៩៦ | ០.៧៧ | -៣.០៧ | ០.០០ |
| ៤. ការអានយ៉ាងលម្អិត ដើម្បីឱ្យយល់ពីគំនិតសំខាន់នៃអត្ថបទទាំងមូល(Reading for main idea) | ២.៥២ | ០.៦៣ | ២.៨៤ | ០.៧៥ | -២.២២ | ០.០៣ |
| ៥. ការអានយ៉ាងល្អិតល្អន់ដើម្បីពិនិត្យមើលអត្ថន័យជាក់លាក់របស់អត្ថបទទាំងមូល(Reading for specific information) | ២.១៥ | ០.៧៧ | ២.៦៧ | ០.៨៣ | -៣.២០ | ០.០០ |
| ៦. ការអានលម្អិត ដើម្បីធ្វើការវិនិច្ឆ័យលើការយល់ដឹងទៅលើអត្ថបទទាំងមូល(Reading for detailed comprehension) | ២.៤៥ | ០.៧១ | ២.៨៦ | ០.៧៣ | -២.៩២ | ០.០០ |
| **សរុប** | **២.៤៥** | **០.៥៦** | **២.៨៤** | **០.៦៨** | **-៣.០០** | **០.០០** |

តាមតារាង៤.២៤ ខាងលើបង្ហាញថាការយល់ដឹងពីវិធីសាស្ត្រទាំង៦ ដោយយោងទៅតាមចំនួនម៉ោងដែលសិស្សបានអានភាសាអង់គ្លេសក្នុងមួយថ្ងៃឃើញថា មានភាពខុសប្លែកគ្នា ដោយសារតម្លៃរបស់ P = 0.00 < 0.05។ ដោយចំនួនម៉ោងដែលសិស្សអាន ពី១ម៉ោង ទៅ២ម៉ោង មានតម្លៃមធ្យមស្មើនឹង ២.៨៤ > ២.៤៥ ដែលជាតម្លៃមធ្យមរបស់សិស្សដែលចំណាយពេលអានតិចជាង ១ម៉ោងក្នុងមួយថ្ងៃ មានន័យថាសិស្សដែលចំណាយពេលអានពី ១ទៅ២ម៉ោងក្នុងមួយថ្ងៃមានការយល់ដឹងពីវិធីសាស្ត្រអានទាំង៦ ច្រើនជាងសិស្សដែលចំណាយពេលអានតិចជាង ១ម៉ោងក្នុងមួយថ្ងៃ។

### ៤.២.៣.៤. និន្នន័យបែបគុណវិស័យ

បើតាមការលើកឡើងរបស់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សក៏បានបង្ហាញផងដែរថា ការយល់ដឹងរបស់សិស្សភេទប្រុស និងសិស្សភេទស្រីមានលក្ខណៈមិនខុសប្លែកគ្នាទេ ដោយសារពួកគេមិនសូវយល់ច្បាស់ពីការប្រើប្រាស់វិធីសាស្ត្រអាន។ សិស្សដែលរៀនច្រើនឆ្នាំ និងសិស្សដែលរៀនតិចឆ្នាំក៏មានការយល់ដឹងទៅលើវិធីសាស្ត្រអានមិនខុសប្លែកគ្នាដែរ ពួកគេប្រើវិធីសាស្ត្រអានដដែលៗ និងមិនសូវបានស្វែងយល់ច្រើនទៅលើការប្រើវិធីសាស្ត្រខុសៗគ្នាទៅតាមគោលបំណងនៃការអានធ្វើឱ្យចំណេះដឹង លើការប្រើប្រាស់វិធីសាស្ត្រអានរបស់ពួកគេមានភាពប្រែប្រួលតែបន្តិចបន្តួចប៉ុណ្ណោះក្នុងការរៀនតិចឆ្នាំ និងការរៀនច្រើនឆ្នាំ។ ចំពោះការចំណាយពេលអានពី១ម៉ោងទៅ២ម៉ោងក្នុងមួយថ្ងៃបានធ្វើឱ្យការយល់ដឹងរបស់ពួកគេ ទៅលើវិធីសាស្ត្រអានមានភាពល្អប្រសើរជាងសិស្សដែលចំណាយពេលអានតិចជាង ១ម៉ោងក្នុងមួយថ្ងៃ។ ការអានច្រើនធ្វើឱ្យពួកគេយល់បានកាន់តែច្រើនទាំងវិធីសាស្ត្រអាន និងទទួលបានចំណេះដឹងច្រើនផងដែរ។

### ៤.២.៣. ការពិភាក្សាសំណួរស្រាវជ្រាវទី២

សំណួរស្រាវជ្រាវទី២៖ តើមានភាពដូចគ្នា ឬខុសគ្នាដែរឬទេចំពោះការយល់ដឹងពីវិធីសាស្ត្របំណិនអានភាសាអង់គ្លេសរបស់សិស្ស បើយោងទៅតាម ភេទ ចំនួនឆ្នាំដែលពួកគេបានរៀនភាសាអង់គ្លេស និងចំនួនម៉ោងដែលពួកគេបានអានភាសាអង់គ្លេស ?

ភាសាអង់គ្លេស គឺជាមុខវិជ្ជាជីវភាសាសម្រាប់តម្រូវឱ្យសិស្សសិក្សាជាភាសាបរទេសក្នុងគោលបំណងឱ្យសិស្សស្គាល់សញ្ញាណដំបូងនៃភាសាបរទេស អាចទំនាក់ទំនងគ្នាដោយប្រើឃ្លាល្បះខ្លីៗផ្សារភ្ជាប់ទៅនឹងការរស់នៅ មានសមត្ថភាពសរសេរកថាខណ្ឌខ្លីៗ ត្រឹមត្រូវតាមក្បួនវេយ្យាករណ៍ ចេះអាន និងយល់អត្ថបទខ្លីៗ ងាយៗ ចេះកត់ត្រាទុក និងរៀបចំល្បះ ឆ្លើយសំណួរ ឬរៀបរាប់ឡើងវិញនូវអ្វីដែលគេបានឮ ជាពិសេសវាជាទុនដើម្បីបង្កើនចំណេះដឹង ឬបន្តការសិក្សាទៅថ្នាក់ខ្ពស់ទៀតបាន។ ការកែលម្អកម្មវិធីសិក្សាភាសាអង់គ្លេស គឺជាកត្តាចាំបាច់ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងក្នុងការសិក្សាស្រាវជ្រាវដើម្បីទទួលយកចំណេះដឹងថ្មីៗ ពីបច្ចេកវិទ្យាទំនើប ក៏ដូចជាទំនាក់ទំនងផ្នែកវប្បធម៌ ការទូត ពាណិជ្ជកម្ម សេដ្ឋកិច្ច និងនយោបាយក្នុងតំបន់ និងលើសាកលលោក។

## ក. ការប្រៀបធៀបការប្រើប្រាស់វិធីសាស្ត្របំណិនអានភាសាអង់គ្លេសរបស់សិស្សដោយយោងទៅតាមភេទស្រី និងភេទប្រុស

តាមរយៈទិន្នន័យតារាង៤.១៦បានបង្ហាញថា ការយល់ដឹងលើបំណិនអានភាសាអង់គ្លេសទាំង៦របស់សិស្សភេទស្រី និងសិស្សភេទប្រុសមិនមានភាពខុសប្លែកគ្នាទេដោយតម្លៃ P = 0. ៣៥ > 0.0៥។ បើពិនិត្យទៅលើមធ្យមភាគតាមបំណិនអាននីមួយៗ ក្នុងនោះមានវិធីសាស្ត្រចំនួន ៤ដែលសិស្សភេទស្រី និងសិស្សភេទប្រុស មានការយល់ដឹងមិនខុសប្លែកគ្នាគឺវិធីសាស្ត្រទី១ អំណានរហ័សសម្រាប់ស្វែងរកព័ត៌មានជាក់លាក់ណាមួយ(Scanning) វិធីសាស្ត្រទី២ អំណានរហ័សសម្រាប់ស្វែងរកគោលគំនិតសំខាន់ (Skimming) វិធីសាស្ត្រទី៣ ការអានដើម្បីស្វែងរកព័ត៌មានមកអះអាងបញ្ជាក់(Reading to conform information) និងវិធីសាស្ត្រទី៥ ការអានយ៉ាងល្អិតល្អន់ដើម្បីពិនិត្យមើលអត្ថន័យជាក់លាក់របស់អត្ថបទទាំងមូល(Reading for specific information) មានន័យថាសិស្សភេទស្រី និងសិស្សភេទប្រុសមានការយល់ដឹងមិនខុសប្លែកគ្នាទេទៅលើការអានរហ័សសម្រាប់ស្វែងរកព័ត៌មានជាក់លាក់ ស្វែងរកគោលគំនិតសំខាន់ ស្វែងរកព័ត៌មានមកអះអាងបញ្ជាក់ និងការអានយ៉ាងល្អិតល្អន់ដើម្បីពិនិត្យមើលអត្ថន័យជាក់លាក់របស់អត្ថបទទាំងមូល។ ចំពោះ វិធីសាស្ត្រអានទី៤ ការអានយ៉ាងលម្អិត ដើម្បីឱ្យយល់ពីគំនិតសំខាន់នៃអត្ថ

បទទាំងមូល (Reading for main idea) និងវិធីសាស្ត្រអានទី៦ ការអានលម្អិត ដើម្បីធ្វើការវិនិច្ឆ័យលើការយល់ដឹងទៅលើអត្ថបទទាំងមូល (Reading for detailed comprehension)រវាងសិស្សភេទស្រី និងសិស្សភេទប្រុសមានភាពខុសប្លែកគ្នា ដោយសារតម្លៃមធ្យមរបស់សិស្សភេទស្រីទាបជាងតម្លៃមធ្យមរបស់សិស្សភេទប្រុស។ ក្នុងនោះបំណិនអានទី៤ សិស្សស្រីមានតម្លៃមធ្យម ២.៦៩ < ២.៨៦ តម្លៃមធ្យមរបស់សិស្សភេទប្រុស និងបំណិនអានទី៦ សិស្សស្រីមានតម្លៃមធ្យម ២.៦៨ < ២.៨៩ តម្លៃមធ្យមរបស់សិស្សភេទប្រុស មានន័យថាសិស្សភេទស្រីមានការយល់ដឹងលើវិធីសាស្ត្រអានទាំងពីរនេះទាបជាងសិស្សប្រុស។ យើងអាចពិនិត្យទៅលើសូចនាករក្នុងវិធីសាស្ត្រអានទាំងពីរនោះ។ នៅក្នុងវិធីសាស្ត្រអានទី៤ ខ្លឹមសារទី២០ មានតម្លៃ P = 0.0៤ < 0.0៥ ដោយតម្លៃមធ្យមរបស់សិស្សស្រីទាបជាងតម្លៃមធ្យមរបស់សិស្សប្រុស ( ២.៥៨ < ២.៩៣)មានន័យថានៅពេលអត្ថបទមានការលំបាក សិស្សស្រីមានការយល់ដឹងទាបជាងសិស្សប្រុស សិស្សស្រីមិនសូវបានអានអត្ថបទឡើងវិញដើម្បីបង្កើនការយល់ដឹងរបស់ខ្លួនទេ។ ក្រៅពីនេះខ្លឹមសារទី១៨ក៏សិស្សភេទស្រីមានតម្លៃមធ្យមទាបជាងសិស្សភេទប្រុសដែរ (២.៦៣ < ២.៨៣) មានន័យថាសិស្សភេទស្រីមិនសូវបានអានអត្ថបទម្តងហើយម្តងទៀត ដើម្បីស្វែងរកទំនាក់ទំនងនៃគំនិតគោលដែលនៅក្នុងអត្ថបទញឹកញាប់ដូចសិស្សប្រុសនោះទេ។ ចំពោះវិធីសាស្ត្រអានទី៦ ខ្លឹមសារទី២៩ មានតម្លៃ P = 0.0៣ < 0.0៥ ដោយតម្លៃមធ្យមសិស្សស្រីទាបជាងតម្លៃមធ្យមសិស្សភេទប្រុស (២.៥២ < ២.៨៨) មានន័យថានៅពេលអានសិស្សប្រុសបកប្រែពីភាសាអង់គ្លេសជាភាសាខ្មែរច្រើនជាងសិស្សស្រី។ មួយវិញទៀតក្នុងខ្លឹមសារទី២៨ និងខ្លឹមសារទី៣០ តម្លៃមធ្យមរបស់សិស្សស្រីទាបជាងតម្លៃមធ្យមរបស់សិស្សប្រុស (២.៦៤ <២.៩៣ និង ២.៦៦ < ២.៨៨) មានន័យថានៅពេលអានសិស្សភេទប្រុសស្មានអត្ថន័យរបស់ពាក្យ ឬឃ្លាដែលមិនដឹងជាមុន និងគិតអំពីអ្វីដែលមានជាភាសាអង់គ្លេស និងជាភាសាខ្មែរច្រើនជាងសិស្សភេទស្រី។ លទ្ធផលនៃវិធីសាស្ត្រទាំងពីរនេះ គឺឃើញថាមានលក្ខណៈប្រហាក់ប្រហែលគ្នាជាមួយនឹងការរកឃើញរបស់លោក Keshavarz និងលោក Ashtarian ឆ្នាំ ២០០៨ ដែលបានលើកឡើងថាក្រៅពីយុទ្ធសាស្ត្រក្នុងការអាន ដែលប្រើប្រាស់ដោយអ្នកអាន ចំណេះដឹងមានស្រាប់របស់ពួកគេ ការលើកទឹកចិត្ត

ឥរិយាបថ អាយុ និងភេទក៏មានឥទ្ធិពលក្នុងការអានរបស់សិស្សផងដែរ តែលោកបានបញ្ជាក់ថាសិស្សស្រីមានសមត្ថភាពក្នុងការអាន ឬការយល់ដឹងអំពីអត្ថបទអំណានខ្ពស់ជាងសិស្សប្រុស។ មួយវិញទៀត បើតាមលោក Brown និង Baker ឆ្នាំ ១៩៨៣ បានបញ្ជាក់ក្នុងសៀវភៅគាត់ថា ចាប់តាំងពីដើមទសវត្សរ៍ឆ្នាំ ១៩៧០មក ការស្រាវជ្រាវមួយចំនួននៅក្នុងវិស័យអានបានផ្តោតលើយុទ្ធសាស្ត្រដែលជួយសម្រួលដល់ការអាន ហើយការប្រើប្រាស់យុទ្ធសាស្ត្រផ្សេងៗត្រូវបានគេរកឃើញថាមានប្រសិទ្ធភាពក្នុងការកែលម្អការចេះអានរបស់សិស្សថែមទៀត។

សរុបមក ការប្រៀបធៀបរវាងសិស្សភេទស្រី និងសិស្សភេទប្រុសទៅលើការយល់ដឹងលើវិធីសាស្ត្រអានទាំង៦ ជារួមគឺមិនមានភាពខុសប្លែកគ្នាទេ ដោយតម្លៃ P = ០.៣៥ > ០.០៥។ តាមរយៈមធ្យមភាគលើសូចនាករនីមួយៗឃើញថាមិនមានភាពខុសប្លែកគ្នាទៅលើវិធីសាស្ត្រអានចំនួន៤ និងមានភាពខុសប្លែកគ្នាបន្តិចបន្តួចទៅលើវិធីសាស្ត្រអានចំនួន២ ដែលអាចបង្ហាញថាវិធីសាស្ត្រដែលប្រើប្រាស់ដោយអ្នកអានចំណេះដឹងមានស្រាប់របស់ពួកគេ ការលើកទឹកចិត្ត ឥរិយាបថ អាយុ និងភេទក៏មានឥទ្ធិពលក្នុងការអានរបស់សិស្សដែរ។

### ខ. ការប្រៀបធៀបការប្រើប្រាស់វិធីសាស្ត្របំណិនអានភាសាអង់គ្លេសរបស់សិស្សដោយយោងទៅតាមចំនួនឆ្នាំដែលសិស្សបានរៀនភាសាអង់គ្លេស

តាមរយៈទិន្នន័យរបស់តារាង៤.១៧ បានបង្ហាញថាការយល់ដឹងលើការប្រើប្រាស់វិធីសាស្ត្រនៃបំណិនអាន ដោយយោងទៅតាមចំនួនឆ្នាំដែលសិស្សបានរៀនភាសាអង់គ្លេសរបស់សិស្សមធ្យមសិក្សាទុតិយភូមិក្នុងខេត្តតាកែវមិនមានភាពខុសប្លែកគ្នាទេដោយតម្លៃ P = ០.៥០ > ០.០៥ ប៉ុន្តែបើពិនិត្យទៅលើមធ្យមភាគរវាងសិស្សដែលរៀនភាសាអង់គ្លេសតិចជាង៣ឆ្នាំ សិស្សដែលរៀនភាសាអង់ គ្លេសពី៣ទៅ៥ឆ្នាំ និងសិស្សដែលរៀនភាសាអង់គ្លេសច្រើនជាង៥ឆ្នាំឃើញថា មានការប្រែប្រួលតិចតួចគ្រប់វិធីសាស្ត្រទាំងអស់ដោយសិស្សដែលរៀនភាសាអង់គ្លេសច្រើនជាង៥ឆ្នាំ មានមធ្យមភាគខ្ពស់ជាងគេ បន្ទាប់មកគឺសិស្សដែលរៀនភាសាអង់គ្លេសពី៣ទៅ៥ឆ្នាំ ហើយសិស្សដែលរៀនភាសាអង់គ្លេសតិចជាង៣ឆ្នាំមានមធ្យមភាគ

ទាបជាងគេ។ មធ្យមភាគដែលប្រែប្រួលទាំងនេះមានន័យថា សិស្សដែលរៀនភាសាអង់គ្លេសច្រើនឆ្នាំមានការយល់ដឹងទៅលើ ការប្រើប្រាស់វិធីសាស្ត្រនៃបំណិនអានភាសាអង់គ្លេសច្រើនជាងសិស្សដែលបានរៀនភាសាអង់គ្លេសក្នុងរយៈពេលតិចឆ្នាំ ប៉ុន្តែការយល់ដឹងទាំងនេះមានការប្រែប្រួលតែបន្តិចបន្តួចប៉ុណ្ណោះ ដោយសារតម្លៃមធ្យមមានការប្រែប្រួលបន្តិចបន្តួចពីក្រុមសិស្សដែលរៀនភាសាអង់គ្លេសតិចជាង៣ឆ្នាំទៅក្រុមសិស្សដែលរៀនភាសាអង់គ្លេសពី៣ទៅ៥ឆ្នាំ និងទៅក្រុមសិស្សដែលរៀនភាសាអង់ គ្លេសច្រើនជាង៥ឆ្នាំ(២.៦១ < ២.៧២ < ២.៨២)។ នេះអាចបង្ហាញថាការសិក្សាភាសាអង់គ្លេសច្រើនឆ្នាំអាចបង្កើនសមត្ថភាពអានរបស់សិស្សបានដោយអាចឱ្យសិស្សមានបទពិសោធ និងចំណេះដឹងបន្ថែម។ យោងលោក Keshavarz និងលោក Ashtarian ឆ្នាំ ២០០៨ ដែលបានលើកឡើងថា ចំណេះដឹងមានស្រាប់របស់សិស្ស ការលើកទឹកចិត្ត ឥរិយាបថ អាយុ និងភេទក៏មានឥទ្ធិពលក្នុងការអានរបស់សិស្សផងដែរ។ ក្រៅពីនេះ លោក Jill Hadfiekd និង លោក Charles Hadfield ក៏បានពន្យល់ផងដែរថា អ្នកអានដែលពូកែគឺជាអ្នកអានដែលមានយុទ្ធសាស្ត្រច្រើនបំផុត។ ពួកគេប្រើយុទ្ធសាស្ត្រអានខុសៗគ្នាគឺអាស្រ័យទៅលើប្រភេទអត្ថបទដែលពួកគេកំពុងអាន និងមូលហេតុនៃការអានរបស់ពួកគេ។ បន្ទាប់មកពួកគេ ទទួលបានអត្ថន័យពីក្នុងអត្ថបទដោយយុទ្ធសាស្ត្រយល់ដឹងទាំងនោះស្ថិតក្រោមការត្រួតពិនិត្យរបស់អ្នកអាន ដែលបានធ្វើការសម្រេចចិត្តទៅលើយុទ្ធសាស្ត្រអ្វីដែលត្រូវប្រើប្រាស់ និងពេលណាដែលត្រូវប្រើវា។

### គ. ការប្រៀបធៀបការប្រើប្រាស់វិធីសាស្ត្របំណិនអានភាសាអង់គ្លេសរបស់សិស្សដោយយោងទៅតាមចំនួនម៉ោងដែលសិស្សបានអានភាសាអង់គ្លេស

តាមរយៈទិន្នន័យរបស់តារាង៤.២៤ បានបង្ហាញថាការយល់ដឹងលើវិធីសាស្ត្របំណិនអានភាសាអង់គ្លេសរបស់សិស្ស ដោយយោងទៅតាមចំនួនម៉ោងដែលសិស្សអានភាសាអង់គ្លេសក្នុងមួយថ្ងៃមានភាពខុសប្លែកគ្នាដោយសារតម្លៃ P = 0.00 < 0.05។ ដោយចំនួនម៉ោងដែលសិស្សអាន ពី១ម៉ោង ទៅ២ម៉ោង មានតម្លៃមធ្យម ២.៨៤ > ២.៤៥ ដែលជាតម្លៃមធ្យមរបស់សិស្សដែលចំណាយពេលអានតិចជាង១ម៉ោងក្នុងមួយថ្ងៃ មានន័យថាសិស្សដែលចំណាយពេលអានពី ១ទៅ២ម៉ោងក្នុងមួយថ្ងៃមានការយល់ដឹង

ពីវិធីសាស្ត្រអានទាំង៦ ច្រើនជាងសិស្សដែលចំណាយពេលអានតិចជាង ១ម៉ោងក្នុងមួយថ្ងៃ។ យោងតាមការស្រាវជ្រាវរបស់ លោក Jill Hadfiekd និង លោក Charles Hadfield ក្នុងឆ្នាំ ២០០៨ បានពន្យល់ថា អ្នកអានត្រូវការជំនាញអានផ្សេងៗដើម្បីជួយឱ្យការអានរបស់ពួយគេទទួលបានជោគជ័យ ព្រមទាំងប្រើប្រាស់ចំណេះដឹងមានស្រាប់របស់ពួកគេទៅលើអត្ថបទដើម្បីប៉ាន់ស្មានពីអត្ថន័យនៅក្នុងអត្ថបទ។ ផ្ទុយទៅវិញ អ្នកដែលមិនពូកែអានច្រើនតែមិនសូវមានចំណេះដឹងមានស្រាប់ទាក់ទងនឹងប្រធានបទ ឬចនាបទនៃអត្ថបទឱ្យបានគ្រប់គ្រាន់ជាហេតុធ្វើឱ្យពួកគេមិនងាយយល់ពីអត្ថបទនៅពេលដែលពួកគេអាន។ ហេតុនេះ សិស្សដែលចំណាយពេលអានច្រើននឹងទទួលបានចំណេះដឹងច្រើន សម្រាប់ជំនួយដល់ការអានរបស់ពួកគេ។ ដូច្នេះការដាក់កិច្ចការផ្ទះទាក់ទងទៅនឹងការអានដល់សិស្ស និងការលើកទឹកចិត្តឱ្យសិស្សអានមានសារសំខាន់ណាស់ក្នុងការជួយឱ្យសិស្សមានសមត្ថភាពអានកាន់តែប្រសើរឡើង។

សរុបមក ការប្រៀបធៀបកម្រិតនៃការយល់ដឹងពីវិធីសាស្ត្របំណិនអានភាសាអង់គ្លេសរបស់សិស្សនៅកម្រិតមធ្យមសិក្សាទុតិយភូមិក្នុងខេត្តតាកែវ រវាងសិស្សភេទស្រី និងសិស្សភេទប្រុស ជារួមមិនមានភាពខុសប្លែកគ្នាទេ។ បើពិនិត្យទៅលើការប្រើប្រាស់វិធីសាស្ត្រទី១ វិធីសាស្ត្រទី២ វិធីសាស្ត្រទី៣ និងវិធីសាស្ត្រទី៥ គឺមិនមានភាពខុសប្លែកគ្នាទេ ប៉ុន្តែមានភាពខុសប្លែកគ្នាតិចតួចទៅលើការប្រើប្រាស់វិធីសាស្ត្រទី៤ និងវិធីសាស្ត្រទី៦ ដោយសិស្សភេទប្រុសមានការយល់ដឹងច្រើនជាងសិស្សភេទស្រី។ ចំពោះការប្រៀបធៀបចំនួនឆ្នាំដែលសិស្សបានរៀនភាសាអង់គ្លេស លទ្ធផលបង្ហាញថាមិនមានភាពខុសប្លែកគ្នាទេគ្រាន់តែមានការប្រែប្រួលទៅលើមធ្យមភាគតិចតួច ចំពោះសិស្សដែលរៀនភាសាអង់គ្លេសច្រើនជាង ៥ឆ្នាំ សិស្សដែលរៀនភាសាអង់គ្លេសពី៣ទៅ៥ឆ្នាំ និងសិស្សដែលរៀនភាសាអង់គ្លេសតិចជាង៣ឆ្នាំ។ ចំណែកការប្រៀបធៀបការយល់ដឹងពីវិធីសាស្ត្របំណិនអានភាសាអង់គ្លេស ទៅតាមចំនួនម៉ោងដែលសិស្សអានភាសាអង់គ្លេសក្នុងមួយថ្ងៃ លទ្ធផលបង្ហាញថាសិស្សដែលចំណាយពេលអានពី១ម៉ោងទៅ២ម៉ោងក្នុងមួយថ្ងៃមានការយល់ដឹងទៅលើការប្រើប្រាស់វិធីសាស្ត្របំណិនអាន ច្រើនជាងសិស្សដែលចំណាយពេលអានតិចជាង១ម៉ោងក្នុងមួយថ្ងៃ។

# ជំពូកទី ៥

# សេចក្តីសន្និដ្ឋាន និងសំណូមពរ

# ជំពូកទី ៥

# សេចក្តីសន្និដ្ឋាន និងសំណូមពរ

## ៥.១. សេចក្តីសន្និដ្ឋាន

ការសិក្សាស្រាវជ្រាវទៅលើប្រធានបទដែលមានចំណងជើងថា « ការយល់ដឹងពីវិធីសាស្ត្រនៃការអានភាសាអង់គ្លេសរបស់សិស្សនៅកម្រិតមធ្យមសិក្សាទុតិយភូមិក្នុងខេត្តតាកែវ» មានគោលបំណងរកឱ្យឃើញពីកម្រិតនៃការយល់ដឹងរបស់សិស្សលើការប្រើប្រាស់វិធីសាស្ត្រនៃបំណិនអានភាសាអង់គ្លេស និងធ្វើការសិក្សាប្រៀបធៀបការយល់ដឹងរបស់សិស្សនៅក្នុងខេត្តតាកែវ ចំពោះបំណិនអានជាភាសាអង់គ្លេសដោយចែកទៅតាមភេទ ចំនួនឆ្នាំដែលរៀនភាសា និងចំនួនម៉ោងដែលបានអានភាសាអង់គ្លេស។ ការសិក្សានេះប្រើប្រាស់វិធីសាស្ត្របែបបរិមាណវិស័យ និងគុណវិស័យដោយប្រើប្រាស់ភាគសំណាកសិស្ស ១៣១នាក់ និងគ្រូបង្រៀនភាសាអង់គ្លេសចំនួន១៥នាក់ក្នុងកម្រិតថ្នាក់ទី១០ ថ្នាក់ទី១១ និងថ្នាក់ទី១២នៃវិទ្យាល័យចំនួន៨នៅក្នុងខេត្តតាកែវ។ ទិន្នន័យដែលប្រមូលបាន ត្រូវបានវិភាគដោយប្រើកម្មវិធី SPSS និង Microsoft Excel សម្រាប់សង់ក្រាប និងតារាង ព្រមទាំងប្រមូលផ្តុំគំនិតទស្សនៈការយល់ឃើញនានារបស់អ្នកផ្តល់បទសម្ភាសន៍ដោយចាប់បញ្ចូលនូវចំណុចដែលដូច ឬក៏មានលក្ខណៈប្រហាក់ប្រហែលគ្នាដើម្បីបន្ថែមព័ត៌មាន និងបង្ហាញគំនិតគាំទ្រចំពោះទិន្នន័យនៃការវិភាគតាមបែបបរិមាណវិស័យ។

តាមរយៈទិន្នន័យដែលប្រមូលបាន និងឆ្លងកាត់ការវិភាគរួចមក លទ្ធផលបានបង្ហាញថាសិស្សមានការយល់ដឹងលើវិធីសាស្ត្រអានក្នុងកម្រិតមធ្យម( តម្លៃមធ្យម ២.៧២ )។ សិស្សមានការយល់ដឹងទៅលើការអានលម្អិត ដើម្បីធ្វើការវិនិច្ឆ័យលើការយល់ដឹងទៅលើអត្ថបទទាំងមូលក្នុងកម្រិតខ្ពស់ជាងគេ( តម្លៃមធ្យម ២.៧៧) និងមានការយល់ដឹងតិចជាងគេលើការអានល្អិតល្អន់ ដើម្បីពិនិត្យមើលអត្ថន័យជាក់លាក់របស់អត្ថបទទាំងមូល( តម្លៃមធ្យម២.៦៣ )។ សិស្សមិនសូវបានប្រើការអានយ៉ាងល្អិតល្អន់ដើម្បីពិនិត្យមើលអត្ថន័យជាក់លាក់របស់អត្ថបទទាំងមូល ដោយមិនសូវបានអានយ៉ាងយឺតៗ និងប្រុងប្រយ័ត្នដើម្បីឱ្យប្រាកដថាពួកគេបានយល់អ្វីដែលកំពុងអាន( តម្លៃមធ្យម២.៤៤ ) មិនព្យាយាមត្រឡប់មកអានត្រង់កន្លែងដែល

បាត់បង់ការផ្តោតអារម្មណ៍(តម្លៃមធ្យម ២.៤២) និងមិនបានប្រើប្រាស់ឯកសារយោងដើម្បីធ្វើឱ្យចងចាំព័ត៌មាន(តម្លៃមធ្យម ២.៣៨)។ ការប្រៀបធៀបកម្រិតយល់ដឹងបំណិនអានភាសាអង់គ្លេសរបស់សិស្សដោយបែងចែកទៅតាមភេទ និងចំនួនឆ្នាំដែលសិស្សបានរៀនភាសាអង់គ្លេសមិនមានភាពខុសប្លែកគ្នាទេដោយតម្លៃ P > 0.05 ប៉ុន្តែបើពិនិត្យទៅលើមធ្យមភាគតាមសូចនាករនីមួយៗបានបង្ហាញពីភាពខុសប្លែកគ្នាខ្លះដោយសិស្សភេទប្រុសមានការយល់ដឹងច្រើនជាងសិស្សភេទស្រីទៅលើ ការអានយ៉ាងលម្អិតដើម្បីឱ្យយល់ពីគំនិតសំខាន់នៃអត្ថបទទាំងមូល និងការអានលម្អិត ដើម្បីធ្វើការវិនិច្ឆ័យលើការយល់ដឹងទៅលើអត្ថបទទាំងមូល។ ចំណែកការប្រៀបធៀបទៅលើចំនួនឆ្នាំដែលសិស្សរៀនភាសាក៏មិនមានភាពខុសប្លែកគ្នាដែរដោយP = 0.50 > 0.05។ តម្លៃមធ្យមមានការប្រែប្រួលបន្តិចបន្តួចពីក្រុមសិស្សដែលរៀនភាសាអង់គ្លេសតិចជាង៣ឆ្នាំ ទៅក្រុមសិស្សដែលរៀនភាសាអង់គ្លេសពី៣ទៅ៥ឆ្នាំ និងទៅក្រុមសិស្សដែលរៀនភាសាអង់គ្លេសច្រើនជាង៥ឆ្នាំ(២.៦១ < ២.៧២ < ២.៨២)។ ចំពោះការយល់ដឹង លើបំណិនអានភាសាអង់គ្លេសតាមរយៈចំនួនម៉ោង ដែលសិស្សអានក្នុងមួយថ្ងៃមានលក្ខណៈខុសប្លែកគ្នាដោយតម្លៃ P < 0.05 សិស្សដែលចំណាយពេលអានពី១ម៉ោង ទៅ២ម៉ោងក្នុងមួយថ្ងៃមានការយលដឹងលើបំណិនអានខ្ពស់ជាងសិស្សដែលចំណាយពេលអានតិចជាង ១ម៉ោងក្នុងមួយថ្ងៃ។

តាមរយៈលទ្ធផលនេះ អ្នកសិក្សាអាចសន្និដ្ឋានបានថា ការយល់ដឹងពីវិធីសាស្ត្រនៃការអានភាសាអង់គ្លេសរបស់សិស្សនៅកម្រិតមធ្យមសិក្សាទុតិយភូមិក្នុងខេត្តតាកែវ មិនទាន់បានល្អប្រសើរ(តម្លៃមធ្យម ២.៧២)។ ការយល់ដឹងទៅលើការប្រើវិធីសាស្ត្រមួយចំនួនស្ថិតក្នុងកម្រិតទាប ទាំងសិស្សប្រុស និងសិស្សស្រីមិនទាន់បានយល់ច្បាស់ពីការប្រើប្រាស់វិធីសាស្ត្រអានឱ្យត្រូវនឹងគោលបំណងនៃការអាន(តម្លៃក្រោមមធ្យម ២.៣៨ ២.៤២ និង២.៤៤)។ ម្យ៉ាងវិញទៀត តាមរយៈលទ្ធផលនេះអ្នកសិក្សាក៏អាចសន្និដ្ឋានបានទៀតថាការបង្រៀនវិធីសាស្ត្របំណិនអានដល់សិស្សរបស់លោកគ្រូ អ្នកគ្រូ និងការគ្រប់គ្រងគ្រូបង្រៀនភាសាអង់គ្លេសនៅតាមសាលានីមួយៗក៏មិនទាន់បានល្អប្រសើរដែរ (សិស្សមានសមត្ថភាពអានក្នុងកម្រិតមធ្យមត្រឹមតែ ២.៧២)។ រយៈពេលសិក្សាច្រើនឆ្នាំមានឥទ្ធិពលដល់ការយល់ដឹងពីវិធីសាស្ត្រអានរបស់

សិស្ស (សិស្សដែលរៀនភាសាអង់គ្លេសតិចជាង៣ឆ្នាំមានមធ្យមភាគ ២.៦១ សិស្សដែលរៀនពី៣ទៅ៥ឆ្នាំ មានមធ្យមភាគ ២.៧២ និងសិស្សរៀនច្រើនជាង៥ឆ្នាំ ២.៨២)។ ការចំណាយពេលអានកាន់តែច្រើន សិស្សទទួលបានការយល់ដឹងលើបំណិនអានកាន់តែច្រើន (មធ្យមភាគសិស្សដែលអានតិចជាង១ម៉ោង ក្នុងមួយថ្ងៃគឺ២.៤៥ មធ្យមភាគសិស្សដែលអានពី១ទៅ២ម៉ោងក្នុងមួយថ្ងៃ គឺ២.៨៤)។

## ៥.២. សំណូមពរ

យោងតាមលទ្ធផលនៃការស្រាវជ្រាវ និងដើម្បីរួមចំណែកក្នុងការជួយឱ្យសិស្សមានបំណិនអានភាសាអង់គ្លេសកាន់តែល្អប្រសើរឡើង អ្នកសិក្សាសូមលើកឡើងនូវគំនិតយោបល់ ព្រមទាំងសំណូមពរមួយចំនួនសម្រាប់ភាគីពាក់ព័ន្ធ ដូចខាងក្រោម៖

### ៥.២.១. សម្រាប់អ្នកអនុវត្ត

#### ក. ចំពោះសិស្ស

សិស្សគប្បីបង្កើនការយល់ដឹងលើបំណិនអានដូចជា បង្កើតគោលដៅអានសៀវភៅ និងព្យាយាមកំណត់ពេលវេលាអានសៀវភៅសម្រាប់ខ្លួនឯងជារៀងរាល់ថ្ងៃ។ ត្រូវបណ្ដុះទម្លាប់អានដោយខ្លួនឯង ដោយចាប់ផ្ដើមពីការអានអត្ថបទខ្លីៗដែលខ្លួនចូលចិត្តអាន បន្ទាប់មកទើបចាប់ផ្ដើមអានអត្ថបទណាដែលខ្លួនគិតថាមានប្រយោជន៍ និងអាចផ្ដល់ចំណេះដឹងដល់យើងបាន។ ពេលអានត្រូវយកចិត្តទុកដាក់អានយ៉ាងល្អិតល្អន់ដើម្បីពិនិត្យមើលអត្ថន័យជាក់លាក់របស់អត្ថបទទាំងមូល ត្រូវប្រាកដថាយល់ពីអ្វីដែលខ្លួនកំពុងអាន ត្រឡប់មកអានត្រង់កន្លែងណាដែលបាត់បង់ការផ្ដោតអារម្មណ៍ និងចេះប្រើប្រាស់ឯកសារយោងដូចជាវចនានុក្រមជាដើម ដើម្បីជំនួយដល់ការចងចាំព័ត៌មាន។

#### ខ. ចំពោះគ្រូ

គ្រូបង្រៀន សូមបង្រៀនសិស្សឱ្យគ្រប់បំណិនអាន និងធ្វើការសិក្សាស្រាវជ្រាវជាប្រចាំដើម្បីអភិវឌ្ឍចំណេះដឹង និងវិធីសាស្ត្របង្រៀនថ្មីៗ។ សូមដាក់កិច្ចការស្រាវជ្រាវដែលទាក់ទងនឹងការអាន ជាមួយគោលបំណងផ្សេងៗ និងច្បាស់លាស់ដល់សិស្សឱ្យបានញឹកញាប់ លើកទឹកចិត្តសិស្សឱ្យចូលចិត្តអានដើម្បីឱ្យ

សិស្សអាចអនុវត្តនូវបំណិនអានដែលបានរៀន ព្រមទាំងប្រើប្រាស់សម្ភារឧបទេសស្របទៅតាមខ្លឹមសារមេរៀនដើម្បីទាក់ទាញការចាប់អារម្មណ៍របស់សិស្សឱ្យចង់រៀនភាសាអង់គ្លេស។

### គ. ចំពោះគណៈគ្រប់គ្រង

សូមរៀបចំបណ្ណាល័យដែលមានឯកសារសម្រាប់សិស្សចូលអាន និងសិក្សាស្រាវជ្រាវដោយមានទាំងឯកសារជាភាសាខ្មែរ និងភាសាអង់គ្លេស ព្រមទាំងត្រួតពិនិត្យមើលដំណើរការបណ្ណាល័យជាប្រចាំ ជួយគាំទ្រ និងជួយសម្របសម្រួលបំផុសចលនាប្រកួតប្រណាំងការអានជាភាសាបរទេសក្នុងសាលា និងធ្វើអធិការកិច្ចណែនាំពីវិធីសាស្ត្របង្រៀនថ្មីៗដល់លោកគ្រូ អ្នកគ្រូ ដែលបង្រៀនភាសាអង់គ្លេសនៅក្នុងសាលារបស់ខ្លួន ព្រមទាំងផ្តល់ជំនួយផ្នែកសម្ភារឧបទេសដែលជាតម្រូវការក្នុងការបង្រៀន និងរៀនភាសាអង់គ្លេសដល់គ្រូឱ្យបានគ្រប់គ្រាន់។

### ឃ. ចំពោះមន្ទីរអប់រំ យុវជន និងកីឡា

សូមពិនិត្យតាមដានការបង្រៀន និងរៀនភាសាអង់គ្លេសពិសេសការបង្រៀនវិធីសាស្ត្រអានរបស់គ្រូនៅតាមសាលារៀននីមួយៗ តាមរយៈនាយកសាលា និងលទ្ធផលនៃការធ្វើអធិការកិច្ច។

### ង. ចំពោះក្រសួងអប់រំ យុវជន និងកីឡា

សូមជួយផ្គត់ផ្គង់សៀវភៅ និងឯកសារជាភាសាអង់គ្លេសដល់សាលារៀនឱ្យបានគ្រប់គ្រាន់។ សូមជួយបំប៉នគ្រូលើមុខវិជ្ជាភាសាអង់គ្លេសជាប្រចាំ ដើម្បីឱ្យពួកគាត់ទទួលបាននូវចំណេះដឹងថ្មីៗទាក់ទងនឹងការរីកចម្រើននៃភាសាអង់គ្លេស និងវិធីសាស្ត្របង្រៀនថ្មីៗ។

## ៥.២.២. សម្រាប់អ្នកស្រាវជ្រាវបន្ត

សូមឱ្យអ្នកសិក្សាស្រាវជ្រាវក្រោយៗ ដែលមានបំណងចង់ធ្វើការសិក្សាស្រាវជ្រាវទៅលើប្រធានបទនេះ ឬប្រហាក់ប្រហែលនេះ សូមពង្រីកវិសាលភាពនៃការស្រាវជ្រាវឱ្យកាន់តែធំ ផ្លាស់ប្តូរករណីសិក្សាទៅខេត្តផ្សេង ឬធ្វើទូទាំងប្រទេសដោយបន្ថែមភាគសំណាកគណៈគ្រប់គ្រង និងបន្ថែមចំនួនភាគសំណាកឱ្យបានច្រើនជាងនេះ ដើម្បីធានាបាននូវព័ត៌មានជាក់លាក់ជាងនេះ។

# ឯកសារយោង

# ឯកសារយោង


ក្រសួងអប់រំ យុវជន និង កីឡា (២០១៨). *កម្មវិធីសិក្សាលម្អិត មុខវិជ្ជាភាសាខ្មែរសម្រាប់មធ្យមសិក្សាបឋមភូមិ ទំព័រទី ៤ដល់៩.* ភ្នំពេញ: ក្រសួងអប់រំ យុវជន និង កីឡា។

ក្រសួងអប់រំ យុវជន និងកីឡា (២០១៩). *ផែនទីបង្ហាញផ្លូវគោលដៅអភិវឌ្ឍប្រកបដោយចីរភាពឆ្នាំ ២០៣០ស្ដីពីការអប់រំនៅកម្ពុជា.* ភ្នំពេញ: ក្រសួងអប់រំ យុវជន និងកីឡា។

ក្រសួងអប់រំ យុវជន និង កីឡា (២០០៥). *ការកំណត់មុខវិជ្ជាភាសាបរទេសជាភាសាតាមស្ម័គ្រសម្រាប់ការប្រឡងមធ្យមសិក្សាបឋមភូមិ និង ទុតិយភូមិចាប់ពីឆ្នាំសិក្សា២០០៥ - ២០០៦.* ភ្នំពេញ: ក្រសួងអប់រំ យុវជន និង កីឡា។

ក្រសួងអប់រំ យុវជន និង កីឡា. (២០១៩). *លទ្ធផលទូទាំងប្រទេសនៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ និង បំពេញវិជ្ជា សម័យប្រឡង៖ ១៩ សីហា ២០១៩.* ភ្នំពេញ: ក្រសួងអប់រំ យុវជន និង កីឡា។

ក្រសួងអប់រំ យុវជន និង កីឡា (២០១៨). *កម្មវិធីសិក្សាលម្អិត មុខវិជ្ជា អក្សរសាស្ត្រខ្មែរ សម្រាប់កម្រិតមធ្យមសិក្សាទុតិយភូមិ ទំព័រទី ៥.* ភ្នំពេញ: ក្រសួងអប់រំ យុវជន និង កីឡា។

ក្រសួងអប់រំ យុវជន និង កីឡា (២០១៨). *កម្មវិធីសិក្សាលម្អិត មុខវិជ្ជាភាសាអង់គ្លេស សម្រាប់មធ្យមសិក្សាទុតិយភូមិ.* ភ្នំពេញ: ក្រសួងអប់រំ យុវជន និង កីឡា។

ក្រសួងអប់រំ យុវជន និង កីឡា (២០១៩). *គោលដៅអភិវឌ្ឍប្រកបដោយចីរភាព.* ភ្នំពេញ: ក្រសួងអប់រំ យុវជន និង កីឡា។

ក្រសួងអប់រំ យុវជន និង កីឡា (២០១៤). *ស្តង់ដាអំណានថ្នាក់ទី១៖ សៀវភៅណែនាំគ្រូបង្រៀនដើម្បីពង្រឹងសមត្ថភាពអំណានដល់សិស្ស.* ភ្នំពេញ: ក្រសួងអប់រំ យុវជន និង កីឡា។

ក្រសួងអប់រំ យុវជន និង កីឡា (២០១៦). *ស្តង់ដាអំណានថ្នាក់ទី៣.* ភ្នំពេញ: ក្រសួងអប់រំ យុវជន និង កីឡា។

ក្រសួងអប់រំ យុវជន និងកីឡា. (២០១៨). *ទិដ្ឋភាពទូទៅ និង លទ្ធផលនៃកម្មវិធីអន្តរជាតិស្តីពីវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សសម្រាប់ប្រទេសកំពុងអភិវឌ្ឍ(PISA-D) និង PISA 2021 ទំព័រ ៤០ដល់ ៤៣.* ភ្នំពេញ: ក្រសួងអប់រំ យុវជន និង កីឡា។

ក្រសួងអប់រំ យុវជន និងកីឡា (២០១៦). *ក្របខ័ណ្ឌកម្មវិធីសិក្សាចំណេះទូទៅនិងអប់រំបច្ចេកទេស.* ភ្នំពេញ: ក្រសួងអប់រំ យុវជន និងកីឡា។

ក្រសួងអប់រំ យុវជន និងកីឡា (២០១៨). *កម្មវិធីសិក្សាលម្អិត ភាសាអង់គ្លេសសម្រាប់កម្រិតមធ្យមសិក្សាទុតិយភូមិ.* ភ្នំពេញ: គ្រឹះស្ថានបោះពុម្ព និង ចែកផ្សាយ។

ក្រសួងអប់រំ យុវជន និងកីឡា (២០០៤). *គោលនយោបាយសម្រាប់អភិវឌ្ឍកម្មវិធីសិក្សាចំណេះទូទៅ ២០០៥-២០០៩.* ភ្នំពេញ: ក្រសួងអប់រំ យុវជន និងកីឡា។

ក្រសួងអប់រំ យុវជន និងកីឡា (២០០៧). *ច្បាប់ស្តីពីការអប់រំ.* ភ្នំពេញ: ធនាគារអភិវឌ្ឍអាស៊ី។

ក្រសួងអប់រំ យុវជន និងកីឡា (២០១៩). *ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០១៩ ដល់ ២០២៣.* ភ្នំពេញ: ក្រសួងអប់រំ យុវជន និង កីឡា។

ធម្មនុញ្ញនៃសមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍. (២០០៧). *ធម្មនុញ្ញនៃសមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍.* សិង្ហបូរី: អាស៊ាន។

នាយកដ្ឋានបណ្តុះបណ្តាល និង វិក្រិតការ. (២០១០). *ឯកសារបំប៉នសមត្ថភាពគ្រូបង្រៀននៅអនុវិទ្យាល័យ ភាសាខ្មែរ(ទំព័រទី៤).* ភ្នំពេញ: នាយកដ្ឋានបណ្តុះបណ្តាល និង វិក្រិតការ។

នាយកដ្ឋានបណ្ដុះបណ្ដាល និង វិក្រឹតការ. (២០១៦). *ឯកសារជំនួយគ្រូឧទ្ទេសសម្រាប់បណ្ដុះបណ្ដាលគរុសិស្សនិងគ្រូ ស្ដីពី «ស្ដង់ដាអំណានថ្នាក់ទី១ ទី២ និង ទី៣».* ភ្នំពេញ: អង្គការអេប់រំពិភពលោក

នាយកដ្ឋានបណ្ដុះបណ្ដាលនិងវិក្រឹតការ. (២០១០). *ឯកសារបំប៉នគ្រូនៅអនុវិទ្យាល័យមុខវិជ្ជា ភាសាខ្មែរ( ទំព័រ៨៣ដល់៨៨).* ភ្នំពេញ: នាយកដ្ឋានបណ្ដុះបណ្ដាល និង វិក្រឹតការ។

បណ្ឌិត ឈុន ណារ៉េត. (២០១០). *អាស៊ាន និង សមាហរណកម្ម.* ភ្នំពេញ។

ប៊ុន វឌ្ឍនា. (២០១៨). *ការយល់ដឹងលើបំណិនអានភាសាអង់គ្លេសរបស់សិស្សមធ្យមសិក្សាបឋមភូមិក្នុងរាជធានីភ្នំពេញ.* ភ្នំពេញ: វិទ្យាស្ថានជាតិអប់រំ។

វិស័យអប់រំឆ្នាំ២០៣០. (២០១៥). *វិស័យអប់រំឆ្នាំ២០៣០ សេចក្ដីប្រកាសទីក្រុង អ៊ីនឈុន.* អ៊ីនឈុន: ភាពជាដៃគូក្នុងការអប់រំនៃអង្គការក្រៅរដ្ឋាភិបាល។

ហង់ជួន ណារ៉ុន, ក. ម. (២០១៦). *កំណែទម្រង់វិស័យអប់រំនៅកម្ពុជា មាគ៌ាឆ្ពោះទៅរកសង្គមពុទ្ធិ.* ភ្នំពេញ: ធនាគារអភិវឌ្ឍអាស៊ី។

. Ahmed, S. ( 2015 ). Attitude towards English language learning among EFL learners at UMSKAL. *Journal of Education and Practice* , 7.

Anderson R. C. ( 1994 ). Role of the Reader'Schema in Comprehension, Learning and Memory. *In R.B. aRuddell, M.R rudell and H. Singer( Eds ), Theoretical Model and Processes of Reading*, 469-482.

Barnett, M. A. ( 1988 ). Reading through Context. *How Real and erceived Strategies Use Affects L2 Comprehension Modern language journal*, 150-162.

Brown and Baker. (1983). *The Role of Metacognition in Reading and Studying.* New York : Routledge.

Carrell, P. L, Pharis, B. G, Liberto, J. C. (1989). Metaconitive Strategies Training for ESL Reading. *TESOL quarterly, 23*, 121.

COBUILD Advanced English Dictionary. (2020, November 5). *www.collinsdictionary.com*. Retrieved from www.collinsdictionary.com: https://www.collinsdictionary.com/dictionary/english/efl

David Crystal. (2003). *English as a Global Language.* Cambridge: Cambridge University Press.

Dechant, E. (1991). *Understanding and Teaching Reading: An Intetacting Model.* Hillsdale, New Jersey: Laurance Erlbaum Association.

Françoise Grellet, F. (2002). *Developing Reading Skills: A Practical guide to Reading Comprehension exercises, 21th printing.* Cambridge: Cambridge University Press.

Gerald Fallon and Natalei Rublik. (2012). Second-Language Education Policy in Quebec: ESL Teachers´ Perceptions of the Effects of the Policy of English as a Compulsory Subject at the Early Primary Level. *TESL Canada Journal*, 58- 73.

Hamouda, D. A. (2003). An Investigation of Listening Comprehension Problems Encountered by Saudi Student in the EL Listening Classroom. *International*

*Journal of Academic Research in Progressive Education and development*, 113-155.

Hywel Coleman, H. (2011). Dreaams and Realities: Developing Countries and English Language. *British Council*, 5-6.

IIEP. (2017). *Educational planning today.* online learning phase of the Education.

Jeremy Harmer. (1988). *How to Teach Writing.* Edinburgh.

Jeremy Harmer, J. (2002). How to teach English. *An Introductiion to the practice of English Language Teaching, 8th impresstion, Pearson Educatiion Limited*, 68-78.

Jill Hardfiekd and Charles Hadfield. (2008). *Oxford basics: Introduction to Teaching English, page 91- 104.* New York: Oxford University Press.

Jo Ann Aebersold and Mary Lee Field. (1997). *From Reader to Reading Teacher, Issues and Strategies for Second language Classroom, page 15.* Cambridge: Cambridge University Press.

Kam, H. W. (2006). English Language Teaching at East Asia Today: An Overview. *Asia Pacific Journal of Education*, 1-22.

Keshavarz. and Ashtarian. (2008). *The relationship between Iranian EFL Learners' Gender and reaing Comprehension of Three Differint Types of Text*, 98-113.

Koji Ikawa, E. L. (2008). English Language and Its Education in Cambodia, A Country in Transition. *Shitennoji University Bulletin*, 343-369.

Kumar, M. (2020, September 13). *www.google.com*. Retrieved from www.quora.com: https://www.quora.com/What-is-meant-by-writing-skills

Li, S.Y/ Munby, H. (1996). *Metacognitive Strategies in Second Language Academic Reading. AQualititative Study English for specifc purposes.*

Lydia M. Musau & Migosi Joash Abere. (2015). Teacher qualification and students' academic performance in science mathematics and technology subjects in Kenya. *Intenational Journal of Educational Administration and Policy Studies* , 83-89.

Marry Ann Cunningham Florez. (1999). *Improving Adult English Language Learners' speaking Skill.* Washington, DC: ERIC. Retrieved from ERIC.

Master Plan on ASEAN Connectivity 2025. (2017). *Master Plan on ASEAN Connectivity 2025.* Jakarta, Indonesia.: Catalogue-in-Publication Data.

Ministry of Education, Y. a. (2019). *Results of Grade 11 Student Achievement from the National Assessment in 2018.* Phnom Penh: Moeys.

MOEYS. (2015). *Curriculum Framework of General Education and Technical Education.* Phnom Penh: Department of Curriculum Development.

Neau Vira. (2003). The Teaching of Foreign Language in Cambodia: A Historical Perspective. *Language Culture and Curriculum*, 253-268.

Nordquist, R. (2019, July 1). *Thoughtco*. Retrieved from https://www.thoughtco.com: https://www.thoughtco.com/english-as-a-second-language-esl-1690599

Nuttall, C. (1996). *Teaching Reading Skills in a foreign Language.* Oxford: Heinemann.

Oxford, R.L.and Burry-stock, J.A. (1995). Assessing the use of language learning strategies worldwide with the ESL. *EFL version of the strategy inventory for language learning (SILL). System,* 1-23.

Oxford Advanced Learner's Dictionary . (2005). *Oxford Advanced Learner's Dictionary 7th edition.* Oxford New York: Oxford University Press.

Patrici L, Carrell, J Devine, DE Eskey. (1988). *Interactive Approaches to Second Languages Reading.* Cambridge: Cambridge University Press.

PL Carrell, P. (1998). Interactive approachs to second language reading. *Can reading strategies be successfully taught? ARAL*, 1-20.

Reading Skills Guide. (2020, November 5). *www.google.com*. Retrieved from Reading Skills Guide: https://www.englishclub.com/reading/guide.php

Rosie Amstutz. (2012, May 7). *www.google.com*. Retrieved from www.slideshare.net: https://www.slideshare.net/rosieamstutz/interactive-reading-model

Singapore Cooperation Programme, Traning Course. (2017). *Teaching English as a Second Language-Curriculum Planning andPedagogy (21 August-8 September).* Phompenh: Cambodia.

Thomlison, T. D. (1984). Relational Listening: Theoretical and Practical Consideration. *Paper Presented at Annual Meeting of the 5th Intetnational Listening Association*, 1-30.

Tomas S. C. Farrell. (2002). *Planning Lesson for a Reading Class.* Singapore: Singapore: SEAMEO Regional Language Centre.

Wikipedia. (2020, July 13). *en.m.wikipedia.org*. Retrieved from Wikipedia: https://en.wikipedia.org/wiki/TOEIC

Wikipedia. (2020, October 30). *Wikipedia*. Retrieved from Wikipedia: https://en.wikipedia.org/wiki/Test_of_English_as_a_Foreign_Language

Wikipedia. (2020, November 2). *www.googl.com*. Retrieved from https://en.wikipedia.org/wiki/Teaching_English_as_a_second_or_foreign_language

William Grabe. (2009). *Reading in a Second Language: Moving from Theory to Practice Cambridge Applied Linguistics, page 11-13.* Cambridge: Cambridge University Press.

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ១៖ កម្រងសំណួរបំពេញសម្រាប់លោកគ្រូ អ្នកគ្រូ

**ប្រធានបទ៖**

**«ការសិក្សាលើបំណិនអំណានក្នុងការរៀនភាសាអង់គ្លេសរបស់សិស្សនៅកម្រិតមធ្យមសិក្សាទុតិយភូមិនៅខេត្តតាកែវ »**

នាងខ្ញុំឈ្មោះ ទិព្វ សារី ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៧ នៃវិទ្យាស្ថានជាតិអប់រំ បានរៀបចំការសិក្សាស្រាវជ្រាវទៅលើប្រធានបទស្តីពី «**ការសិក្សាលើបំណិនអំណានក្នុងការរៀនភាសាអង់គ្លេសរបស់សិស្សនៅកម្រិតមធ្យមសិក្សាទុតិយភូមិនៅខេត្តតាកែវ** »។ ការស្រាវជ្រាវនេះ មានគោលបំណងសំខាន់គឺ រកឱ្យឃើញពីកម្រិតនៃការយល់ដឹងរបស់សិស្ស លើការប្រើប្រាស់វិធីសាស្ត្រនៃបំណិនអានជាភាសាអង់គ្លេស និងសិក្សាប្រៀបធៀប ការយល់ដឹងរបស់សិស្ស ចំពោះបំណិនអានជាភាសាអង់គ្លេសដោយចែកទៅតាមភេទ ចំនួនឆ្នាំដែលរៀនភាសា និងចំនួនម៉ោងដែលបានអានភាសាអង់គ្លេស ដើម្បីជាប្រយោជន៍ក្នុងការជួយឱ្យការសិក្សាភាសាអង់គ្លេសរបស់សិស្សកាន់តែប្រសើរឡើង ជាពិសេសក្នុងបំណិនអំណាន និងទុកជាឯកសារសម្រាប់អ្នកសិក្សាជំនាន់ក្រោយ។

អាស្រ័យហេតុនេះ សូមលោកគ្រូ អ្នកគ្រូ មេត្តាជួយផ្តល់ព័ត៌មានដែលពិត និងដោយស្មោះត្រង់ ដើម្បីឱ្យលទ្ធផលនៃការសិក្សាស្រាវជ្រាវនេះ មានភាពសុក្រិតដោយគ្រាន់តែលោកគ្រូ អ្នកគ្រូទាំងអស់ ចំណាយពេលប្រហែល២០ទៅ៣០នាទីដោយក្តីអនុគ្រោះ ដើម្បីបំពេញកិច្ចការនេះ។ ព័ត៌មានដែលលោកគ្រូអ្នកគ្រូបានផ្តល់ គឺពិតជាមានសារៈសំខាន់សម្រាប់ការស្រាវជ្រាវនេះ។ រាល់ចម្លើយឬព័ត៌មានរបស់លោកគ្រូ អ្នកគ្រូ ត្រូវបានយកមកប្រើសម្រាប់តែការសិក្សាស្រាវជ្រាវតែប៉ុណ្ណោះ។

សូមអរគុណលោកគ្រូ អ្នកគ្រូទុកជាមុនសម្រាប់ការចំណាយពេលវេលាដ៏មានតម្លៃក្នុងការបំពេញកម្រងសំណួរនេះ។

### I. ព័ត៌មានផ្ទាល់ខ្លួន

១. ភេទ៖ ☐ ប្រុស ☐ ស្រី

២. អាយុ៖ .................... ឆ្នាំ

៣. កម្រិតថ្នាក់ដែលបង្រៀន៖ ☐ ថ្នាក់ទី ១០ ☐ ថ្នាក់ទី ១១ ☐ ថ្នាក់ទី ១២

៤. សាលារៀន៖ ..........................................................................

៥. ឯកទេសដើម៖ .......................................................................

II. **ព័ត៌មានទូទៅទាក់ទងនឹងការបង្រៀនភាសាអង់គ្លេស**

៦. ចំនួនឆ្នាំដែលបង្រៀនភាសាអង់គ្លេស៖ ................ ឆ្នាំ

៧. តើលោកគ្រូ អ្នកគ្រូធ្លាប់បានប្រាប់ពីហេតុផលនៃការរៀនភាសាអង់គ្លេសអ្វីខ្លះដល់សិស្ស? (ចម្លើយលើស ពីមួយ)

☐. មានប្រយោជន៍ចំពោះការងាររបស់ខ្ញុំ

☐. ចង់រៀនភាសាផ្សេងៗតាមរយៈភាសាអង់គ្លេស

☐. ចង់រាប់អានមិត្តដែលជាជនជាតិដើមប្រើអង់គ្លេស

☐. ចង់ដឹងពីវប្បធម៌របស់ប្រទេសដែលប្រើភាសាអង់គ្លេស

☐. ចង់ប្រឡងចូលរៀននៅសាកលវិទ្យាល័យផ្សេងៗ

☐. ចង់មានកិត្តិយស ឬ លើកឋានៈក្នុងសង្គម

☐. ជាភាសាមួយដែលគួរឱ្យចាប់អារម្មណ៍

☐. សេចក្ដីផ្សេងៗ (សូមបញ្ជាក់)

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

៨. សមត្ថភាពផ្នែកភាសាអង់គ្លេសមានសារៈសំខាន់ចំពោះសិស្សច្រើន ឬ តិចកម្រិតណា?

☐ សំខាន់ខ្លាំងណាស់ ☐ សំខាន់ ☐ មិនសូវសំខាន់ ☐ មិនសំខាន់ទាស់តែសោះ

៩. ការវាយតម្លៃកម្រិតសមត្ថភាពភាសាអង់គ្លេសរបស់សិស្ស

| | ខ្សោយ | មធ្យម | ល្អ | ល្អប្រសើរ |
|---|---|---|---|---|
| សមត្ថភាពភាសាអង់គ្លេសទូទៅ | ☐ | ☐ | ☐ | ☐ |
| ជំនាញការអានភាសាអង់គ្លេស | ☐ | ☐ | ☐ | ☐ |

១០. តើលោកគ្រូ អ្នកគ្រូឱ្យសិស្ស ចំណាយពេលអានភាសាអង់គ្លេស ប៉ុន្មានម៉ោងក្នុងមួយថ្ងៃ?

☐ តិចជាង ១ ម៉ោង ☐ ពី ១ ទៅ ២ ម៉ោង ☐ ពី ២ ទៅ ៣ ម៉ោង ☐ ច្រើនជាង ៣ ម៉ោង

១១. តើលោកគ្រូ អ្នកគ្រូ ដាក់កិច្ចការទាក់ទងនឹងការអានដល់សិស្សញឹកញាប់កម្រិតណា?

☐ ក. ញឹកញាប់ណាស់ ☐ ខ. ញឹកញាប់ ☐ គ. ម្ដងម្កាល ☐ ឃ. មិនដែលសោះ

## III. វិធីសាស្ត្រ

១២. តើលោកគ្រូ អ្នកគ្រូបានបង្រៀនវិធីសាស្ត្រអានអ្វីខ្លះដល់សិស្ស ? ( ចម្លើយអាចលើសពីមួយ )

☐ ក. Scanning ៖ អំណានរហ័សសម្រាប់ស្វែងរកព័ត៌មានជាក់លាក់ណាមួយ ដូចជាកាលបរិច្ឆេទ លេខទូរស័ព្ទ តួលេខ ឬឆ្នាំ។

☐ ខ. Skimming ៖ អំណានរហ័សសម្រាប់ស្វែងរកគំនិតសំខាន់ ដែលភាគច្រើនមាននៅក្នុងសេចក្តីផ្តើម ឬសេចក្តីបញ្ចប់។

☐ គ. Reading to confirm Information៖ ការអានដើម្បីស្វែងរកព័ត៌មាន មកអះអាងបញ្ជាក់

☐ ឃ. Reading for Main idea៖ ការអានយ៉ាងលម្អិត ដើម្បីឱ្យយល់ពីគំនិតសំខាន់នៃអត្ថបទទាំងមូល

☐ ង. Reading for specific information ៖ ការអានយ៉ាងល្អិតល្អន់ដើម្បីពិនិត្យមើលអត្ថន័យជាក់លាក់របស់អត្ថបទទាំងមូល។

☐ ច. Reading for Detailed Comprehension ៖ ការអានលម្អិត ដើម្បីធ្វើការវិនិច្ឆ័យលើការយល់ដឹងទៅលើអត្ថបទទាំងមូល

☐ ឆ. វិធីសាស្ត្រផ្សេងពីនេះ ( សូមបញ្ជាក់ )..................................................................................

..................................................................................................................................

..................................................................................................................................

១៣. តើលោកគ្រូ អ្នកគ្រូយល់ថាសិស្សមានសមត្ថភាពយល់ដឹងលើវិធីសាស្ត្រអានខាងក្រោមកម្រិតណា ?

| ល.រ | វិធីសាស្ត្រការអាន | កម្រិតការអនុវត្ត | | | | |
|---|---|---|---|---|---|---|
| | | ច្រើនបំផុត | ច្រើន | មធ្យម | តិច | តិចបំផុត |
| ១ | Scanning | | | | | |
| ២ | Skimming | | | | | |
| ៣ | Reading to conform information | | | | | |
| ៤ | Reading for main idea | | | | | |
| ៥ | Reading for specific information | | | | | |
| ៦ | Reading for Detailed Comprehension | | | | | |

១៤. តើលោកគ្រូ អ្នកគ្រូធ្លាប់បាន ណែនាំសិស្សពីរបៀបប្រើវិធីសាស្ត្រអានទាំងនោះដែរ ឬទេ? ហេតុអ្វី?

☐ ក. ធ្លាប់ ☐ ខ. មិនធ្លាប់

ព្រោះ៖.....................................................................................................................................

.................................................................................................................................................

១៥. នៅពេលសិស្សកំពុងអាន ប្រសិនបើជួបពាក្យឬឃ្លាដែលពួកគេមិនចេះ តើលោកគ្រូ អ្នកគ្រូណែនាំពួកគេឱ្យធ្វើដូច ម្តេចខ្លះ? (ចម្លើយអាចលើសពីមួយ)

☐ ក. បើកវចនានុក្រម ☐ ឃ. ប៉ាន់ស្មានន័យដោយចំណេះដឹងមានស្រាប់

☐ ខ. រំលងចោល ☐ ង. សួរមិត្តភ័ក្តិ

☐ គ. មើលបរិបទដែលអាចបញ្ជាក់ន័យ ☐ ច. សួរគ្រូ

☐ ឆ. វិធីផ្សេងទៀត (សូមបញ្ជាក់)..........................................................................................

.................................................................................................................................................

១៦. តើលោកគ្រូ អ្នកគ្រូណែនាំឱ្យសិស្សធ្វើអ្វីខ្លះ ដើម្បីជំនួយដល់ការយល់ខ្លឹមសាររបស់អត្ថបទ? (ចម្លើយអាចលើសពីមួយ)

☐ ក.យល់ពីអត្ថន័យនៃពាក្យខ្លឹមសាររូបភាពនិងរចនាបទ

☐ ឃ. ស្មានពីខ្លឹមសារនៃអត្ថបទតាមរយៈគម្របសៀវភៅ រូបភាព និងចំណងជើង

☐ ខ. មានការយល់ដឹងលើអ្វីដែលគេកំពុងអាន

☐ ង. អានលំហាត់ ឬ កិច្ចការដែលត្រូវធ្វើ

☐ គ. ផ្តោតអារម្មណ៍លើបរិបទនៃអត្ថបទ

☐ ច.អានអត្ថបទពេញលេញ ជៀសវាងបាត់អត្ថន័យ ឬគំនិត

☐ ឆ. វិធីផ្សេងទៀត (សូមបញ្ជាក់)..........................................................................................

.................................................................................................................................................

១៧. តើនៅពេលអាន សិស្សជួបបញ្ហាលំបាកអ្វីខ្លះ? (ចម្លើយអាចលើសពីមួយ)

☐ ក. កំណត់ន័យពាក្យពិបាក ☐ ឃ. មិនមានគោលបំណងក្នុងការអាន

☐ ខ. ការបញ្ចេញសំឡេង ☐ ង. មិនដឹងប្រើវិធីសាស្ត្រអានមួយណា

☐ គ. មិនយល់រចនាសម្ព័ន្ធវេយ្យាករណ៍ ☐ ច. មិនយល់ខ្លឹមសារអត្ថបទ

☐ ឆ. បញ្ហាផ្សេងទៀត (សូមបញ្ជាក់)......................................................................................

.................................................................................................................................................

១៨. តើសិស្សទាមទារឱ្យគ្រូបកប្រែអត្ថបទជាភាសាខ្មែរញឹកញាប់ដែរ ឬ ទេ? (ចម្លើយអាចរើសបានតែមួយ)

☐ ក. ញឹកញាប់ណាស់ ☐ គ. ម្តងម្កាល

☐ ខ. ញឹកញាប់ ☐ ឃ. មិនដែលសោះ

១៩. តើគ្រូណែនាំឱ្យសិស្ស ប្រើវចនានុក្រមនៅពេលណា? (ចម្លើយអាចលើសពីមួយ)

☐ ក. ជួបពាក្យថ្មី ☐ គ. មិនអាចស្មានន័យតាមវិធីផ្សេងៗបាន

☐ ខ. ចង់ដឹងន័យផ្សេងទៀតរបស់ពាក្យ ☐ ឃ. ចង់ផ្ទៀងផ្ទាត់ន័យដែលស្មានរួច

☐ ង. ចម្លើយផ្សេងទៀត (សូមបញ្ជាក់)...........................................................................................

..........................................................................................................................................

..........................................................................................................................................

២០. តើលោកគ្រូ អ្នកគ្រូ គិតថាការបង្កើនសមត្ថភាពអានភាសាអង់គ្លេសរបស់សិស្សមានសារសំខាន់ដល់លទ្ធផលសិក្សារបស់សិស្សកម្រិតណា?

☐ ក. មានសារៈសំខាន់ណាស់ ☐ គ. មានសារៈសំខាន់តិចតួច

☐ ខ. មានសារៈសំខាន់ មធ្យម ☐ ឃ. មិនមានមានសារៈសំខាន់ទាល់តែសោះ

## IV. យោបល់ និង សំណូមពរ

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

សូមអរគុណចំពោះការសហការ និង ការចូលរួមឆ្លើយសំណួរ របស់លោកគ្រូ អ្នកគ្រូ!

## ឧបសម្ព័ន្ធ២៖ កម្រងសំណួរបំពេញសម្រាប់សិស្ស

**ប្រធានបទ៖**

«**ការសិក្សាលើបំណិនអំណានក្នុងការរៀនភាសាអង់គ្លេសរបស់សិស្សនៅកម្រិតមធ្យមសិក្សាទុតិយភូមិនៅខេត្តតាកែវ** »

នាងខ្ញុំឈ្មោះ ទិព្វ សារី ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែក គ្រប់គ្រងអប់រំ ជំនាន់ទី៧ នៃ វិទ្យាស្ថានជាតិអប់រំ បានរៀបចំការសិក្សាស្រាវជ្រាវទៅលើប្រធានបទស្តីពី «**ការសិក្សាលើបំណិនអំណានក្នុងការរៀនភាសាអង់គ្លេសរបស់ សិស្សនៅកម្រិតមធ្យមសិក្សាទុតិយភូមិនៅខេត្តតាកែវ** » ស្របទៅតាមលក្ខខណ្ឌប្រលងបញ្ចប់របស់ វិទ្យា ស្ថាន។ ការស្រាវជ្រាវនេះមានគោលបំណងសំខាន់គឺ រកឱ្យឃើញពីកម្រិតនៃការយល់ដឹងរបស់សិស្ស លើការប្រើប្រាស់ វិធីសាស្ត្រនៃបំណិនអានជាភាសាអង់គ្លេស និង សិក្សាប្រៀបធៀបការយល់ដឹងរបស់សិស្ស ចំពោះបំណិន អាន ជាភាសា អង់គ្លេសដោយចែកទៅតាមភេទ ចំនួនឆ្នាំដែលរៀនភាសា និងចំនួនម៉ោងដែលបានអានភាសាអង់គ្លេស ដើម្បីជា ប្រយោជន៍ក្នុងការជួយឱ្យការសិក្សាភាសាអង់គ្លេសរបស់សិស្សកាន់តែប្រសើរឡើង ជាពិសេសក្នុងបំណិងអំណាន និង ទុកជាឯកសារសម្រាប់អ្នកសិក្សាជំនាន់ក្រោយ។

អាស្រ័យហេតុនេះ សូមប្អូនៗ មេត្តាជួយផ្តល់ព័ត៌មានដែលពិត និង ដោយក្តីស្មោះត្រង់ ដើម្បីឱ្យលទ្ធផល នៃការ សិក្សាស្រាវជ្រាវនេះ មានភាពសុក្រិត ដោយគ្រាន់តែប្អូនៗទាំងអស់ចំណាយពេលប្រហែល២០ទៅ៣០នាទី ដោយក្តី អនុគ្រោះ ដើម្បីបំពេញកិច្ចការនេះ។ ព័ត៌មានដែលប្អូនៗ បានផ្តល់ គឺពិតជាមានសារៈសំខាន់សម្រាប់ការស្រាវជ្រាវនេះ។ រាល់ចម្លើយ ឬព័ត៌មាន របស់ប្អូនៗ ត្រូវបានយកមកប្រើសម្រាប់តែការសិក្សាស្រាវជ្រាវតែប៉ុណ្ណោះ។

សូមអរគុណប្អូនៗ ទុកជាមុនសម្រាប់ការចំណាយពេលវេលាដ៏មានតម្លៃក្នុងការបំពេញកម្រងសំណួរនេះ។

### I. ព័ត៌មានផ្ទាល់ខ្លួន

១. ភេទ៖ ☐ ប្រុស ☐ ស្រី

២. អាយុ៖ ............. ឆ្នាំ

៣. កម្រិតថ្នាក់៖ ☐ ទី ១០ ☐ ទី ១១ ☐ ទី ១២

៤. សាលារៀន៖ ..........................................................................................

## II. ព័ត៌មានទូទៅទាក់ទងនឹងការរៀនភាសាអង់គ្លេស

៥. ចំនួនឆ្នាំដែលប្អូនសិក្សាភាសាអង់គ្លេស៖

☐ តិចជាង០៣ឆ្នាំ ☐ ពី០៣ឆ្នាំដល់០៥ឆ្នាំ ☐ លើសពី០៥ឆ្នាំ

៦. ហេតុផលការរៀនភាសាអង់គ្លេស (អាចជ្រើសរើសបានលើសពីមួយ )

☐.មានប្រយោជន៍ចំពោះការងាររបស់ខ្ញុំ

☐.ចង់រៀនភាសាផ្សេងៗតាមរយៈភាសាអង់គ្លេស

☐.ចង់រាប់អានមិត្តដែលជាជនជាតិដើមនិយាយភាសាអង់គ្លេស

☐.ចង់ប្រឡងឱ្យជាប់មុខវិជ្ជានេះ

☐.ចង់ដឹងពីវប្បធម៌របស់ប្រទេសដែលនិយាយភាសាអង់គ្លេស

☐.ចង់ប្រឡងចូលរៀននៅសាកលវិទ្យាល័យផ្សេងៗ

☐. ចង់មានកិត្តិយស ឬ លើកឋានៈក្នុងសង្គម

☐.ជាភាសាមួយដែលគួរឱ្យចាប់អារម្មណ៍

☐សេចក្តីផ្សេងៗ (សូមបញ្ជាក់)...............................................................................................

....................................................................................................................................

....................................................................................................................................

៧. ចំណេះដឹងផ្នែកភាសាអង់គ្លេសមានសារៈសំខាន់ចំពោះអ្នកកម្រិតណា?

☐ សំខាន់ខ្លាំងណាស់ ☐ សំខាន់ ☐ មិនសូវសំខាន់ ☐ មិនសំខាន់ទាស់តែសោះ

៨. ការវាយតម្លៃកម្រិតសមត្ថភាពភាសាអង់គ្លេសរបស់ខ្លួនឯង

| | ខ្សោយ | មធ្យម | ល្អ | ល្អប្រសើរ |
|---|---|---|---|---|
| សមត្ថភាពភាសាអង់គ្លេសទូទៅ | ☐ | ☐ | ☐ | ☐ |
| ជំនាញការអានភាសាអង់គ្លេស | ☐ | ☐ | ☐ | ☐ |

៩. ចំនួនម៉ោងដែលចំណាយក្នុងការអានភាសាអង់គ្លេសជាទូទៅក្នុងមួយថ្ងៃៗ

☐ តិចជាង ១ ម៉ោង ☐ ពី ១ ទៅ ២ ម៉ោង ☐ ពី ២ ទៅ ៣ ម៉ោង ☐ ច្រើនជាង ៣ ម៉ោង

## III. ការអនុវត្តវិធីសាស្ត្រនៃបំណិនអាន

សូមប្អូនៗគូស ✓ ក្នុងប្រអប់ ☐ ដែលត្រូវតាម **ការពិតជាក់ស្តែង** នឹង **កំរិតនៃការអនុវត្តយុទ្ធសាស្ត្រការអាន** របស់ខ្លួន ក្នុងប្រអប់ខាងក្រោម ដោយ៖

| | | |
|---|---|---|
| ពាក្យថា «**ច្រើនបំផុត**» | មានន័យថា | ការអនុវត្តតាមខ្លឹមសារគោលគំនិតនោះ **ច្រើនបំផុត** ឬ ជាប្រចាំគ្រប់ពេលយ៉ាងទៀងទាត់ ពោលគឺក្នុងកម្រិតពី ៩១% - ១០០%។ |

| | | |
|---|---|---|
| ពាក្យថា «**ច្រើន**» | មានន័យថា | ការអនុវត្តតាមខ្លឹមសារគោលគំនិតនោះ **ច្រើន** ឬ ស្ទើរគ្រប់ពេល ពោលគឺក្នុងកម្រិតពី ៦១% - ៩០%។ |
| ពាក្យថា «**មធ្យម**» | មានន័យថា | ការអនុវត្តតាមខ្លឹមសារគោលគំនិតនោះ **មធ្យម** ឬ អនុវត្តខ្លះ មិនអនុវត្តខ្លះ ពោលគឺក្នុងកម្រិតពី ៤១% - ៦០%។ |
| ពាក្យថា «**តិច**» | មានន័យថា | ការអនុវត្តតាមខ្លឹមសារគោលគំនិតនោះ **តិច** ឬ អនុវត្តម្តងម្កាលក្នុងកម្រិតតិចតួច ពោលគឺក្នុងកម្រិតពី ១១% - ៤០% |
| ពាក្យថា «**តិចបំផុត**» | មានន័យថា | ការអនុវត្តតាមខ្លឹមសារគោលគំនិតនោះក្នុងកម្រិត **តិចបំផុត ឬ** មិនដែលធ្វើទាល់តែសោះ ពោលគឺក្នុងកម្រិតពី ០% - ១០% |

| ល.រ | យុទ្ធសាស្ត្រការអាន | កម្រិតការអនុវត្ត | | | | |
|---|---|---|---|---|---|---|
| | | ច្រើនបំផុត | ច្រើន | មធ្យម | តិច | តិចបំផុត |
| ១០. Scanning: អំណាន រហ័ស សម្រាប់ស្វែង រកព័ត៌មានជាក់លាក់ណាមួយ | ១. ខ្ញុំជ្រាបគោលបំណងនៃការអាននៅពេលខ្ញុំអានរាល់ពេល | | | | | |
| | ២. ខ្ញុំពិនិត្យមើលអត្ថបទជាមុនសិន ដោយកត់សម្គាល់អំពី លក្ខណៈពិសេសនៃអត្ថបទដូចជាចំណងជើង រូបភាព ទំហំ និង ការរៀបចំ។ | | | | | |
| | ៣. ខ្ញុំធ្វើសញ្ញាដូចជា ការគូសបន្ទាត់ពីក្រោម ឬ គូសរង្វង់លើ ព័ត៌មាននៅក្នុងអត្ថបទ ដើម្បីជួយឱ្យខ្ញុំចងចាំព័ត៌មាននោះ។ | | | | | |
| | ៤. នៅពេលអត្ថបទលំបាកខ្ញុំបន្ថែមការយកចិត្តទុកដាក់លើអ្វីដែលខ្ញុំកំពុងអាន។ | | | | | |
| | ៥. ខ្ញុំប្រើប្រាស់លក្ខណៈពិសេសនៃការរៀបចំអត្ថបទ ដូចជាអក្សរដិត និងអក្សរទ្រេតដើម្បីកំណត់ព័ត៌មានសំខាន់ៗ | | | | | |

| ល.រ | យុទ្ធសាស្ត្រការអាន | កម្រិតការអនុវត្ត | | | | |
|---|---|---|---|---|---|---|
| | | ច្រើនបំផុត | ច្រើន | មធ្យម | តិច | តិចបំផុត |
| ១១. Skimming: អំណានរហ័ស សម្រាប់ស្វែងរកគោលគំនិតសំខាន់ | ៦. ខ្ញុំអានត្រួសៗជាមុន ដើម្បីពិនិត្យមើលថា តើអត្ថបទ នោះនឹងទាក់ទងជាមួយនឹងអ្វី។ | | | | | |
| | ៧. នៅពេលដែលអត្ថបទមានការពិបាក ខ្ញុំអានឮៗ ដើម្បី ធ្វើឲ្យយល់អំពីអ្វីដែលខ្ញុំអាន។ | | | | | |
| | ៨. ខ្ញុំវិភាគមើលថា ខ្លឹមសារនៃអត្ថបទដែលខ្ញុំអានត្រូវ ជាមួយនឹងបំណងនៃការអាន របស់ ខ្ញុំដែរឬទេ។ | | | | | |
| | ៩. នៅពេលអាន ខ្ញុំសម្រេចចិត្តលើអ្វីដែលត្រូវអានឱ្យបានជិតដល់ និង អ្វីដែលត្រូវរំលងចោល។ | | | | | |
| | ១០. ខ្ញុំប្រើប្រាស់តារាងតួលេខ រូបភាពនៅក្នុងអត្ថបទ និង ចំណងជើងក្រោមរូបភាព ដើម្បីបង្កើនការយល់ដឹងរបស់ខ្ញុំ។ | | | | | |

| ល.រ | យុទ្ធសាស្ត្រការអាន | កម្រិតការអនុវត្ត | | | | |
|---|---|---|---|---|---|---|
| | | ច្រើនបំផុត | ច្រើន | មធ្យម | តិច | តិចបំផុត |
| ១២. Reading to confirm Information៖ ការអានដើម្បីស្វែងរកព័ត៌មាន មកអះអាងបញ្ជាក់ | ១១. ខ្ញុំកត់ត្រា ខណៈពេលកំពុងអាន ដើម្បីជួយឱ្យយល់ អំពីអ្វីដែលខ្ញុំអាន។ | | | | | |
| | ១២. ខ្ញុំគិតដល់អ្វីដែលខ្ញុំបានដឹងរួចហើយ ដើម្បីធ្វើឲ្យយល់អំពីអ្វីដែលខ្ញុំអាន។ | | | | | |
| | ១៣. ខ្ញុំពិនិត្យមើលការយល់ដឹងរបស់ខ្ញុំ នៅពេលខ្ញុំឃើញ ព័ត៌មានថ្មីៗ។ | | | | | |
| | ១៤. ខ្ញុំដាក់សំណួរដល់ខ្លួនឯង ដើម្បីស្វែងរកចម្លើយដែលខ្ញុំចង់បាននៅក្នុង អត្ថបទ។ | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| | ១៥. ខ្ញុំពិនិត្យមើលថាតើការប៉ាន់ស្មានរបស់ខ្ញុំ អំពី អត្ថបទ ដែលអានត្រឹមត្រូវ ឬ មិនត្រឹមត្រូវ។ | | | | | |

| ល.រ | យុទ្ធសាស្ត្រការអាន | កម្រិតការអនុវត្ត | | | | |
|---|---|---|---|---|---|---|
| | | ច្រើនបំផុត | ច្រើន | មធ្យម | តិច | តិចបំផុត |
| ១៣. Reading for Main idea ៖ ការអានយ៉ាងលម្អិត ដើម្បីឱ្យយល់ពីគំនិតសំខាន់នៃអត្ថបទទាំងមូល | ១៦. ខ្ញុំឈប់ម្តងម្កាល រួចគិតអំពីអ្វីដែលខ្ញុំកំពុងអាន។ | | | | | |
| | ១៧. ខ្ញុំប្រើប្រាស់តម្រុយនៃបរិបទ ដើម្បីជួយខ្ញុំឱ្យយល់កាន់តែប្រសើរអំពីអ្វីដែលខ្ញុំកំពុងអាន។ | | | | | |
| | ១៨. ខ្ញុំអានអត្ថបទម្តងហើយម្តងទៀត ដើម្បីស្វែងរកទំនាក់ ទំនង នៃគំនិតគោលនៅក្នុងអត្ថបទ។ | | | | | |
| | ១៩. ខ្ញុំព្យាយាមប៉ាន់ស្មានថា តើបរិបទនៃអត្ថបទនិយាយ អំពី អ្វី នៅពេលខ្ញុំអាន។ | | | | | |
| | ២០. នៅពេលអត្ថបទមានការលំបាក ខ្ញុំអានវាឡើងវិញ ដើម្បី បង្កើនការយល់ដឹងរបស់ខ្ញុំ។ | | | | | |

| ល.រ | យុទ្ធសាស្ត្រការអាន | កម្រិតការអនុវត្ត | | | | |
|---|---|---|---|---|---|---|
| | | ច្រើនបំផុត | ច្រើន | មធ្យម | តិច | តិចបំផុត |
| ១៤. Reading for Specific Information ៖ ការអានយ៉ាងល្អិតល្អន់ ដើម្បីពិនិត្យមើលអត្ថន័យជាក់លាក់របស់អត្ថបទ ទាំងមូល។ | ២១. ខ្ញុំអានយ៉ាងយឺតៗនិងប្រុងប្រយ័ត្ន ដើម្បីឱ្យប្រាកដថា ខ្ញុំ យល់អំពីអ្វី ដែលខ្ញុំកំពុងអាន។ | | | | | |
| | ២២. ខ្ញុំព្យាយាមត្រឡប់មកអានត្រង់កន្លែង ដែលខ្ញុំបាន បាត់បង់ ការផ្តោតអារម្មណ៍វិញ។ | | | | | |
| | ២៣. ខ្ញុំកែសម្រួលល្បឿនអានរបស់ខ្ញុំ យោងតាមអ្វីដែលខ្ញុំកំពុង អាន។ | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| | ២៤. ខ្ញុំប្រើប្រាស់ឯកសារយោង( ឧទាហរណ៍ វចនានុក្រម) ដើម្បី ធ្វើឱ្យខ្ញុំចងចាំព័ត៌មាននោះ។ | | | | | |
| | ២៥. ខ្ញុំព្យាយាមបង្កើតរូបភាព ឬ យល់ជារូបភាពអំពីព័ត៌មាន ដើម្បីជួយឱ្យខ្ញុំចងចាំអំពីអ្វីដែលខ្ញុំអាន។ | | | | | |

| ល.រ | យុទ្ធសាស្ត្រការអាន | កម្រិតការអនុវត្ត | | | | |
|---|---|---|---|---|---|---|
| | | ច្រើនបំផុត | ច្រើន | មធ្យម | តិច | តិចបំផុត |
| ១៥. Reading for Detailed Comprehension ៖ ការអានលម្អិត ដើម្បីធ្វើការវិនិច្ឆ័យលើការយល់ដឹងទៅលើ អត្ថបទទាំងមូល | ២៦. ខ្ញុំរៀបរៀងឃ្លា (ដោយប្រើពាក្យពេចន៍ផ្ទាល់របស់ខ្ញុំ) ដើម្បីយល់ដឹងកាន់តែប្រសើរអំពីអ្វីដែលខ្ញុំអាន។ | | | | | |
| | ២៧. ខ្ញុំវិភាគ និងវាយតម្លៃយ៉ាងល្អិតល្អន់លើព័ត៌មាន ដែល បង្ហាញនៅក្នុងអត្ថបទ។ | | | | | |
| | ២៨. នៅពេលណាខ្ញុំអាន ខ្ញុំស្មានអត្ថន័យរបស់ពាក្យ ឬ ឃ្លា ដែលខ្ញុំមិនដឹងជាមុន។ | | | | | |
| | ២៩. នៅពេលអាន ខ្ញុំបកប្រែពីភាសាអង់គ្លេសជាភាសាខ្មែរ។ | | | | | |
| | ៣០. នៅពេលអាន ខ្ញុំគិតអំពីអ្វីដែលមានជាភាសាអង់គ្លេស និង ជាភាសាខ្មែរ។ | | | | | |

## IV. ការយល់ដឹងអំពីការប្រើប្រាស់វិធីសាស្ត្រអានភាសាអង់គ្លេស

តើប្អូនប្រើវិធីសាស្ត្រខាងក្រោមនេះនៅពេលណា?

ក. Scanning ៖ ប្រើនៅពេលអានដើម្បីរក.........................................................................................

.....................................................................................................................................

.....................................................................................................................................

ខ. Skimming ៖ ប្រើនៅពេលអានដើម្បីរក……………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

គ. Reading to conform information ៖ ប្រើនៅពេលអានដើម្បីរក………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

ឃ. Reading for main idea ៖ ប្រើនៅពេលអានដើម្បីរក…………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

ង. Reading for specific information ៖ ប្រើនៅពេលអានដើម្បីរក……………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

ប. Reading for Detailed Comprehension ៖ ប្រើនៅពេលអានដើម្បីរក…………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

V. **យោបល់ និង សំណូមពរ**

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

……………………………………………………………………………………………………………

សូមអរគុណចំពោះការសហការ និង ការចូលរួមឆ្លើយសំណួរ របស់ប្អូនៗសិស្សានុសិស្ស ទាំងអស់គ្នា!